សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

UNIVERSITE ROYALE DROIT ET DES SCIENCES ECONOMIQUES

ROYAL UNIVERSITY OF LAW AND ECONOMIC


# សារណាបញ្ចប់ការសិក្សា

# ភាគីនៅក្នុងបណ្តឹងរដ្ឋប្បវេណី

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ កញ្ញា **អ៊ុំ ម៉ែនពិសី**

កញ្ញា **យិន ខាសា**

ណែនាំដោយ

លោកស្រី **សំណាង ផលដេត**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ


ដើម្បីធ្វើគារវកិច្ចក្នុងការគោរពដឹងគុណចំពោះអ្នកមានគុណទាំងអស់ ដែលបានផ្តួចផ្តើមឱ្យយើងខ្ញុំទាំងពីរនាក់មានឱកាសក្នុងការបង្ហាញនូវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ ដែលជាស្នាដៃរួមរបស់យើងខ្ញុំទាំងពីរនាក់ដោយបានធ្វើការខិតខំប្រឹងប្រែង សិក្សាស្រាវជ្រាវនូវសារណាមួយនេះ នាងខ្ញុំឈ្មោះ **អ៊ុំ ប៉ែនពិសី** និងនាងខ្ញុំឈ្មោះ **យិន ខាសា** ដែលជានិស្សិតផ្នែកនីតិសាស្ត្រ ជំនាន់ទី២៤ ឆ្នាំសិក្សា ២០២០-២០២៤ ក្រុម L4A05 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមធ្វើការលំឱនកាយគោរពដឹងគុណដ៏ធំធេង និងកត្តញ្ញូតាធម៌អស់ពីដួងចិត្ត នៅក្នុងឱកាសដ៏ថ្លៃថ្លានេះ

**សូមគោរពប្រណិប័តន៍ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

អ្នកម្តាយ **អ៊ុំ សុផន** និងបងប្រុស **អ៊ុំ ប៉ែនពិសិដ្ឋ**

លោកឪពុក **សឿង ខា** និងអ្នកម្តាយ **មុំ ស្រីរ័ត្ន**

ដែលបានផ្តល់កំណើតដល់រូបកូន ព្រមទាំងបានចំណាយកម្លាំងកាយ និងកម្លាំងចិត្តដោយមិនខ្លាចនឿយហត់ ទោះនៅឆ្ងាយជិត ក្នុងការមើលថែ ថ្នាក់ថ្នម ថែរក្សាបីបាច់ និងបានផ្គត់ផ្គង់រាល់តម្រូវការគ្រប់បែបយ៉ាង ព្រមទាំងអាណិតស្រលាញ់ បណ្តុះបណ្តាលអប់រំទូន្មានដល់រូបកូន និងបានធ្វើឱ្យកូនទទួលបានការសិក្សាតាំងពីថ្នាក់បឋមរហូតដល់ថ្នាក់បរិញ្ញាប័ត្រនេះ កូនៗសូមក្រាបប្រណិប័តន៍ថ្លែងអំណរគុណនូវគុណនូបការៈមិនអាចកាត់ថ្លៃរបស់ព្រះរស់ទាំងពីរមកលើកូន ។

សូមគោរពថ្លែងអំណរគុណចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ** ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យ មន្ត្រី និងបុគ្គលិកគ្រប់ផ្នែកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានដឹកនាំ គ្រប់គ្រង បង្ហាត់បង្រៀន លះបង់កម្លាំងកាយ ប្រាជ្ញាស្មារតីក្នុងការបណ្តុះបណ្តាលមូលធនបញ្ញាដល់យើងខ្ញុំទាំងពីរ និងបានជួយសម្របសម្រួលដល់យើងខ្ញុំឱ្យទទួលបាននូវពុទ្ធិ និងបទពិសោធន៍ជាច្រើននៅក្នុងវិស័យនីតិសាស្ត្រ។

សូមគោរពអរគុណដល់សាស្ត្រាចារ្យ **សំណាង ផលដេត** ដែលបានណែនាំ កែលម្អ សម្របសម្រួល និងចង្អុលបង្ហាញ ផ្តល់ដំបូន្មាន និងអនុសាសន៍ល្អៗ ព្រមទាំងជួយពន្យល់អំពីវិធីសាស្ត្រក្នុងការស្រាវជ្រាវឯកសារ របៀបតាក់តែង និងកែប្រែចំណុចខ្វះខាត ដើម្បីធ្វើការរៀបចំសរសេរសារណាមួយនេះឱ្យលេចចេញជារូបរាងឡើង តាំងពីចាប់ផ្តើមរហូតបានសម្រេចជាស្ថាពរប្រកបដោយជោគជ័យ។

ជាចុងបញ្ចប់ កូនទាំងពីរសូមប្រសិទ្ធិពរជ័យសិរីមង្គលវិបុលសុខ បួងសួងដល់វត្ថុសក្តិសិទ្ធិទាំងអស់ក្នុងលោកនេះឱ្យជួយបីបាច់ថែរក្សាដល់លោកអ្នកមានគុណទាំងទ្វេរ ឯកឧត្តមសាកលវិទ្យាធិការ លោក លោកស្រីសាស្ត្រាចារ្យ មន្ត្រី និងបុគ្គលិកទាំងអស់សូមឱ្យជួបប្រទះតែពុទ្ធិពរជ័យទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំទាំងពីរពិតជាមានសេចក្ដីរីករាយដែលទទួលបានឱកាសក្នុងការស្រាវជ្រាវលើប្រធានបទមួយស្ដីពីភាគីនៅក្នុងបណ្ដឹងរដ្ឋប្បវេណី។ ចំពោះកិច្ចការស្រាវជ្រាវនេះបានលេចចេញឡើងពីការខិតខំព្យាយាមរបស់យើងខ្ញុំទាំងពីរ ដោយស្ថិតនៅក្រោមការណែនាំដោយយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់បំផុតពីសំណាក់ សាស្ត្រាចារ្យ **សំណាង ផលដេត**។ ក្នុងការស្រាវជ្រាវមួយនេះ យើងខ្ញុំបានធ្វើការប្រមូលនូវឯកសារនានា ដែលបានពាក់ព័ន្ធជាមួយនឹងសារណានេះ ព្រមទាំងទទួលបាននូវចំណេះដឹងអំពីសាស្ត្រាចារ្យ បូករួមនឹងការស្វែងយល់នូវចំណេះដឹងទូទៅ បន្ថែមដោយខ្លួនឯងធ្វើឱ្យស្នាដៃស្រាវជ្រាវនេះបានលេចចេញជារូបរាងឡើងក្នុងពេលនេ។ រីឯការស្រាវជ្រាវទៅលើប្រធានបទ ភាគីនៅក្នុងបណ្ដឹងរដ្ឋប្បវេណី វាពិតជាមិនមានភាពងាយស្រួលនោះទេ ព្រោះវាទាមទារនូវការស្វែងយល់ ចំពោះឯកសារដែលមានប្រភពច្បាស់លាស់ត្រឹមត្រូវអាចជឿទុកចិត្តបាន ដើម្បីធ្វើការតាក់តែងជាលាយលក្ខណ៍អក្សរ។ ហើយនេះជាឱកាសដ៏ពិសេសមួយចំពោះយើងខ្ញុំបានបញ្ចេញសមត្ថភាពដែលបានខិតខំប្រឹងប្រែងរៀនសូត្រក្នុងរយៈពេល៤ឆ្នាំកន្លងមកនេះ តាមរយៈការសរសេរសារណាបញ្ចប់ការសិក្សានេះផងដែរ។

គោលបំណងដែលយើងខ្ញុំដែលបានជ្រើសរើសយកប្រធានបទនេះមកធ្វើការសិក្សាស្រាវជ្រាវ ដោយហេតុថាភាគីនៅក្នុងបណ្ដឹងរដ្ឋប្បវេណី ក៏មានភាពលក្ខណៈស្មុគស្មាញ ព្រមទាំងមិនទាន់បានយល់ ច្បាស់ទូលំទូលាយនៅឡើយទេ ទាំងនិស្សិតសិក្សាផ្នែកនីតិសាស្ត្រផ្ទាល់ រួមទាំងប្រជាពលរដ្ឋទូទៅផងដែរ។ ដើម្បីជួយសម្រួលដល់ការសិក្សាស្រាវជ្រាវដល់ប្អូនៗជំនាន់ក្រោយ យើងខ្ញុំបានព្យាយាមធ្វើការស្រាវជ្រាវប្រធានបទនេះតាមលទ្ធភាព ដែលអាចធ្វើទៅបាន ដោយបានស្វែងរកឯកសារពាក់ព័ន្ធសំខាន់ៗមករៀបចំចងក្រងតម្កល់ទុកឱ្យនិស្សិតជំនាន់ក្រោយធ្វើការសិក្សា និងស្វែងយល់ ក៏ដូចជាយើងខ្ញុំផ្ទាល់បានបញ្ចេញសមត្ថភាពឱ្យអស់ពីលទ្ធភាពក្នុងការពង្រីកបន្ថែមនូវពុទ្ធិផ្នែកច្បាប់ និងពង្រឹងសមត្ថភាពឱ្យបានទូលំទូលាយ។ ទោះជាយ៉ាងណាក្ដីការសរសេរសារណាមួយនេះ ប្រាកដជាមានចំណុចខ្វះខាតជាក់ជាពុំខាន អាស្រ័យហេតុនេះយើងខ្ញុំសូមមេត្តាយោគយល់ អធ្យាស្រ័យ អភ័យទោសទុកជាមុនពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យមិត្តអ្នកអាននានា ក្នុងករណីកិច្ចការស្រាវជ្រាវនេះមានកំហុសឆ្គងណាមួយទាំងខ្លឹមសារ និងអក្ខរាវិរុទ្ធ ឬចំណុចផ្សេងៗដោយអចេតនាក្នុងស្នាដៃស្រាវជ្រាវមួយនេះ។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរនាក់មានសេចក្ដីសោមនស្សរីករាយនូវក្នុងការទទួលមតិរិះគន់ក្នុងន័យស្ថាបនាពីគ្រប់មជ្ឈដ្ឋាន និងផ្ដល់យោបល់ផ្សេងៗ ដើម្បីកែលម្អចំណុចខ្វះខាតនៃអត្ថបទស្រាវជ្រាវមួយនេះឱ្យមានលក្ខណៈល្អប្រសើរជាងមុនបន្ថែមទៀត ។

# មាតិកា


**សេចក្តីផ្តើម** ............ ១
១.លំនាំនៃការស្រាវជ្រាវ ............ ១
២.ចំណោទបញ្ហា ............ ២
៣. គោលបំណងនៃការស្រាវជ្រាវ ............ ២
៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ ............ ៣
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ............ ៣
៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ............ ៣

**ជំពូកទី១**

**សញ្ញាណទូទៅនៃគោលការណ៍នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដែលទាក់ទងទៅនឹងភាគី**

១.១ គោលការណ៍ជាមូលដ្ឋាន ............ ៥
១.២ គោលការណ៍ស្វ័យភាពឆន្ទៈបុគ្គលឯកជន ............ ៥
១.៣ គោលការណ៍ធានានូវសិទ្ធិទាមទារសវនាការ ............ ៦
១.៤ គោលការណ៍ចំពោះមុខ ............ ៦
១.៥ គោលការណ៍ទទួលខុសត្រូវភាគី ............ ៧
១.៦ ភាសាដែលភាគីត្រូវប្រើ ............ ៩

**ជំពូកទី២**

**ភាគីតាមផ្លូវបណ្តឹង**

២.១ និយមន័យភាគី និងសមត្ថភាពភាគី ............ ១១
២.២ សកម្មភាពភាគីនៅក្នុងបណ្តឹង និងសមត្ថភាពភាគីនៅក្នុងបណ្តឹង ............ ១៤
២.២.១ សកម្មភាពភាគីនៅក្នុងបណ្តឹង ............ ១៤
២.២.២ សមត្ថភាពភាគីនៅក្នុងបណ្តឹង ............ ១៤
២.៣ ជនកម្រិតសកម្មភាពក្នុងការធ្វើសកម្មភាពបណ្តឹង ............ ១៥
២.៣.១ អនីតិជន ............ ១៦
២.៣.២ ជននៅក្រោមអាណាព្យាបាលទូទៅ ............ ១៧
២.៣.៣ ជននៅក្រោមហិតូបត្ថម្ភ ............ ១៨
២.៤ នីតិបុគ្គល ............ ១៩

២.៤.១ នីតិបុគ្គលសាធារណៈ ...................................................... ១៩
២.៤.២ នីតិបុគ្គលឯកជន ...................................................... ២០
២.៥ រូបវន្តបុគ្គល ...................................................... ២០

## ជំពូកទី៣

## អ្នកតំណាងតាមផ្លូវបណ្តឹង

៣.១ អ្នកតំណាងតាមផ្លូវបណ្តឹង និងលក្ខណៈសម្បត្តិរបស់អ្នកតំណាង ...................................................... ២១
៣.១.១ អ្នកតំណាងតាមច្បាប់សារធាតុ ...................................................... ២២
៣.១.២ លក្ខណៈសម្បត្តិរបស់អ្នកតំណាងតាមច្បាប់សារធាតុ ...................................................... ២២
៣.២ អ្នកតំណាងពិសេស ...................................................... ២៣
៣.២.១ លក្ខណៈសម្បត្តិនៃអ្នកតំណាងពិសេស ...................................................... ២៤
៣.៣ អ្នកតំណាងដោយអាណត្តិ ...................................................... ២៤
៣.៣.១ លក្ខណៈសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ ...................................................... ២៥
៣.៤ ផលវិបាកនៃវិធានបញ្ញាត្តិស្តីពីអ្នកតំណាង ...................................................... ២៨
៣.៥ ទំនាក់ទំនងអ្នកតំណាងតាមផ្លូវបណ្តឹង និងភាគី ...................................................... ២៩
៣.៥.១ ទំនាក់ទំនងភាគី និងអ្នកតំណាងដោយអាណត្តិ ...................................................... ២៩
៣.៥.២ ការធ្វើសកម្មភាពភាគីនៅក្នុងបណ្តឹងជំនួសភាគី ...................................................... ៣០
សេចក្តីសន្និដ្ឋាន ...................................................... ៣២
អនុសាសន៍ ...................................................... ៣៤
ឯកសារយោង
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំនៃការស្រាវជ្រាវ

ប្រទេសកម្ពុជានៅមុនឆ្នាំ ១៩៩៣ ប្រព័ន្ធច្បាប់ និងបទដ្ឋានគតិយុត្តទាំងអស់ត្រូវបានបំផ្លិចបំផ្លាញដោយមហន្តរាយសង្គ្រាម ( របបកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩ ) ពោលគឺគ្មានការអនុវត្តច្បាប់ណាមួយ ដែលអាចគ្រប់គ្រងដោះស្រាយវិវាទដោយប្រព័ន្ធតុលាការឡើយ។ រហូតមកដល់ឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញថ្មីស្រឡាងមួយរបស់ប្រទេសកម្ពុជាបានចាប់បដិសន្ធិឡើងតាមរយៈកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ពេលនោះហើយដែលបទដ្ឋានគតិយុត្តផ្សេងៗបានបង្កើតឡើង តួយ៉ាងដូចជា ៖ ក្រមរដ្ឋប្បវេណី ត្រូវបានប្រកាសឱ្យប្រើដោយព្រះមហាក្សត្រនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ និងក្រមនីតិវិធីរដ្ឋប្បវេណីនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។ សារៈសំខាន់ឯកសារច្បាប់នៅក្នុងការស្រាវជ្រាវបង្កើតច្បាប់សម្រាប់ការអភិវឌ្ឍសង្គម ក៏ដូចជាការចូលរួមចំណែកក្នុងការកសាងសង្គមកម្ពុជាឱ្យទៅជានីតិរដ្ឋដែលប្រជាជនកម្ពុជាទាំងមូលកំពុងត្រូវការជាចាំបាច់នូវពាក្យថា នីតិរដ្ឋ។ ជាពិសេសបញ្ហាសិទ្ធិមនុស្ស ជាផ្នែកមួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសង្គមឱ្យក្លាយទៅជានីតិរដ្ឋ ដែលសង្គមមួយបានផ្តល់នៅភាពសុខដុមរមនាជូនដល់ប្រជាពលរដ្ឋ។ ប្រទេសកម្ពុជា បានប្រកាន់យកប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស និងរបបរាជានិយមដោយអាស្រ័យរដ្ឋធម្មនុញ្ញ ពោលគឺប្រទេសដែលមាននីតិរដ្ឋដោយការគោរពច្បាប់ សិទ្ធិ និងសេរីភាពជាពិសេសសេរីភាពក្នុងការធ្វើសកម្មភាពពាណិជ្ជកម្ម ឧស្សាហកម្ម និងសកម្មភាពទាំងឡាយរបស់ប្រជាពលរដ្ឋ។ ព្រោះនៅក្នុងសង្គមសេដ្ឋកិច្ចទីផ្សារ បុគ្គលឯកជនម្នាក់ៗដែលជាសមាជិកសង្គមនោះ ត្រូវចូលរួមក្នុងជីវភាពសេដ្ឋកិច្ចទៅតាមរយៈការដោះដូរទំនិញ និងសេវាដោយប្រើរូបិយវត្ថុជាចម្បង ហើយជាធម្មតាការដោះដូរទំនិញ និងសេវាត្រូវបានធ្វើឡើងតាមរយៈកិច្ចសន្យា ឬការសន្យារវាងបុគ្គលម្នាក់និងបុគ្គលម្នាក់ទៀត។ នៅក្នុងករណីច្រើន បុគ្គលនានាប្រតិបត្តិតាមកិច្ចសន្យា គោរពសិទ្ធិរបស់ភាគីម្ខាងទៀត ហើយអនុវត្តករណីយកិច្ចរបស់ខ្លួន ដោយសេចក្តីសុចរិត។ វាជាការធម្មតា ដែលប្រជាពលរដ្ឋរស់នៅក្នុងប្រទេសនីតិរដ្ឋត្រូវតែគោរពច្បាប់។ ក៏ដូចគ្នាផងដែរបុគ្គលនានាតាំងចិត្តគោរពការសន្យារបស់ខ្លួនដោយបុព្វហេតុនៃទំនុកចិត្តលើសង្គម ឬដោយបុព្វហេតុសាសនា។ អាស្រ័យហេតុនេះហើយទើបបង្កើតឱ្យភាគី និងអ្នកតំណាងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីជាពិសេសភាគី និងអ្នកតំណាងដែលជាបុគ្គលមានសិទ្ធិនិងកត្តាកិច្ចអាចធ្វើបណ្តឹង ឬកិច្ចសន្យាដែលជាបុគ្គលមានលក្ខណៈអាចយល់ដឹងអំពីច្បាប់ដែលជារឿងគតិយុត្ត។ នីតិឯកជន គឺជាវិធានទាំងឡាយសំដៅធានាការគ្រប់គ្រងទំនាក់ទំនងរវាងបុគ្គល និងបុគ្គល រវាងនីតិបុគ្គលឯកជន និងនីតិបុគ្គលឯកជន។ នៅក្នុងនីតិជាតិឯកជន គេបានរាប់បញ្ចូលនីតិ៤ ធំៗគឺ ៖ នីតិរដ្ឋប្បវេណី នីតិការងារ នីតិនិរភ័យសង្គម នីតិពាណិជ្ជកម្ម។ ក្នុងចំណោមនីតិទាំង៤ ខាងលើយើងឃើញថា នីតិរដ្ឋប្បវេណី គឺនីតិមួយដែលបានគ្រប់ដណ្តប់លើជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ហើយក្រមរដ្ឋប្បវេណីទៀតសោត គឺជាក្រមមួយប្រភេទដែលបានគ្រប់ដណ្តប់ដល់ជីវភាព

និងជីវិតបុគ្គលឯកជន។ ក្រមរដ្ឋប្បវេណីមានមុខងារ ២ សំខាន់ៗ គឺ ( ១ ) បទដ្ឋានសម្រាប់ធ្វើការសម្រេចសេចក្តី ( បទដ្ឋានសម្រាប់ចេញសាលក្រម ) គឺមានន័យថា សម្រេចតាមការបញ្ញត្តិដែលក្រមរដ្ឋប្បវេណីបានចែង។ ( ២ ) បទដ្ឋានសម្រាប់ធ្វើសកម្មភាព។ នៅប្រទេសកម្ពុជាក្នុងវិស័យរដ្ឋប្បវេណីនេះ យើងឃើញមានក្រមរដ្ឋប្បវេណី ជាច្បាប់សារធាតុដែលគ្រប់គ្រងទំនាក់ទំនងជាលក្ខណៈសារធាតុ និងក្រមនីតិវិធីរដ្ឋប្បវេណី គឺជាវិធានដែលបានចែងពីសកម្មភាពបណ្តឹង។ ចំណែកឯបណ្តឹងរដ្ឋប្បវេណី គឺជាសិទ្ធិមួយដែលច្បាប់ទទួលស្គាល់សម្រាប់បុគ្គលឯកជនអាចជារូបវន្តបុគ្គល ឬជានីតិបុគ្គល ក្នុងការធ្វើបណ្តឹងទៅស្ថាប័នតុលាការឲ្យជួយដោះស្រាយនូវបញ្ហា ដែលកើតមានឡើងក្នុងគោលបំណងទាមទារឲ្យតុលាការចេញសាលក្រមតាមការទាមទារដោយផ្អែកទៅតាមភស្តុតាង និងគតិច្បាប់។ ម្យ៉ាងវិញទៀតអាចហៅបានបណ្តឹងរដ្ឋប្បវេណី គឺជាលិខិតលាយល័ក្ខណ៍អក្សរដែលរៀបចំឡើងដោយភាគី ដែលភាគីម្ខាងជាម្ចាស់បណ្តឹងធ្វើការអះអាងអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិទាមទារតាមច្បាប់សារធាតុចំពោះភាគីម្ខាងទៀតជាអ្នកដែលត្រូវគេប្តឹង ហើយដើម្បីឲ្យបុគ្គលណាម្នាក់បានដឹងថាខ្លួនជាបុគ្គលដើមបណ្តឹង ឬចុងចម្លើយ គឺត្រូវតែស្វែងយល់ជាមុនសិនអំពីភាគី និងអ្នកតំណាងនៅក្នុងគោលការណ៍ច្បាប់។

## ២. ចំណោទបញ្ហា

តើអ្វីទៅដែលជាភាគីនៅក្នុងបណ្តឹងរដ្ឋប្បវេណី? ត្រូវបំពេញលក្ខខណ្ឌគតិយុត្តអ្វីខ្លះក្នុងការអនុវត្តភាគីនៅក្នុងបណ្តឹងរដ្ឋប្បវេណី? និងថាតើលំហូរនីតិវិធីនៃភាគីនៅក្នុងបណ្តឹងរដ្ឋប្បវេណី ប្រព្រឹត្តទៅយ៉ាងដូចម្តេចនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសកម្ពុជា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវក្នុងការសរសេរសារណានេះ ធ្វើឡើងក្នុងគោលបំណងដើម្បីធ្វើការពង្រឹង និងពង្រីកនូវចំណេះដឹងផ្នែកច្បាប់បន្ថែមពាក់ព័ន្ធជាមួយនីតិវិធី នៃភាគីនៅក្នុងបណ្តឹងរដ្ឋប្បវេណី។ ដោយហេតុថានីតិវិធីនេះមានលក្ខណៈស្មុគស្មាញ លក្ខណៈបច្ចេកទេស ពិបាកក្នុងការសិក្សាស្វែងយល់ជាងនីតិវិធីផ្សេងៗទៀត និងមានឧបសគ្គមួយចំនួនដែលពិបាកក្នុងការអនុវត្ត ទើបយើងខ្ញុំធ្វើការសិក្សាស្រាវជ្រាវដើម្បីស្រាយចម្ងល់ និងស្វែងយល់បន្ថែមឱ្យកាន់តែច្បាស់ និងងាយស្រួលក្នុងការអនុវត្តផងដែរ។ ម្យ៉ាងទៀតនីតិវិធីអនុវត្តដែលមានបញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦នេះ គឺជាសញ្ញាណទ្រឹស្តីនៃនីតិវិធីមានលក្ខណៈថ្មីមួយ បើធៀបជាមួយនឹងសញ្ញាណទ្រឹស្តីនៃនីតិវិធីដែលមានបញ្ញត្តិនៅក្នុងប្រទេសកម្ពុជាតាំងពីសម័យមុនៗមក ដូចមានចែងក្នុងច្បាប់ស្តីអំពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណីដែលត្រូវបានប្រកាសឱ្យប្រើដោយក្រឹត្យលេខ៥១ ក.រ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ១៩៩២។

## ៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ

គួរឱ្យកត់សម្គាល់ចំពោះការបង្ហាញពីប្រធានបទដែលបានលើកឡើងខាងលើនេះ គឺធ្វើការស្រាវជ្រាវតែភាគី និងអ្នកតំណាងនៅក្នុងបណ្តឹងនីតិវិធីរដ្ឋប្បវេណី តែនៅក្នុងករណីប្រទេសកម្ពុជា និងធ្វើការស្រាវជ្រាវចំពោះតែភាគី និងអ្នកតំណាងនៅក្នុងបណ្តឹងនីតិវិធីរដ្ឋប្បវេណីត្រឹមតែសាលាដំបូងតែប៉ុណ្ណោះ ដែលមានដែនកំណត់ស្ថិតក្រោមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងប្រធានបទដែលបានលើកឡើងក្នុងចំណោមបញ្ហាខាងលើនេះមក ចំពោះការសិក្សាស្រាវជ្រាវក្នុងការសរសេរសារណានេះ យើងខ្ញុំបានដកស្រង់ស្រាវជ្រាវដោយផ្អែកលើឯកសារច្បាប់ និងបទប្បញ្ញត្តិដែលចូលជាធរមាន និងបានធ្វើការប្រមែប្រមូលឯកសារមកពីគ្រប់ប្រភពផ្សេងៗដូចជា ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមរដ្ឋប្បវេណី សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី និងមេរៀនផ្សេងៗដែលពាក់ព័ន្ធនឹងប្រធានបទខាងលើ របាយការណ៍សិក្សា និងឯកសារផ្សេងៗ របស់លោក-លោកស្រីសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រដែលចងក្រងចេញជាសៀវភៅ ឯកសារសិក្ខាសាលាផ្សេងៗ និងតាមបណ្តាញប្រព័ន្ធអ៊ិនធឺណិត ព្រមទាំងមានការចូលរួមកែសម្រួលពីលោកគ្រូសាស្ត្រាចារ្យណែនាំ សិស្សច្បង និងមិត្តរួមថ្នាក់។ បន្ថែមពីនេះទៀត ក៏បានចូលសិក្សាស្រាវជ្រាវនៅបណ្ណាល័យ ដើម្បីជាប្រយោជន៍ក្នុងការស្វែងយល់ឱ្យកាន់តែច្បាស់ពីប្រធានបទសារណានេះ ក៏ដូចជាការបំពេញបន្ថែមទៀតផងដែរ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីជ្រាបឱ្យកាន់តែច្បាស់ទៅលើប្រធានបទ និងបានជាទឡ្ហីករណ៍ក្នុងការសិក្សាឈ្វេងយល់ និងឈានដល់ការបកស្រាយនូវខ្លឹមសារទាំងមូលឱ្យបានក្បោះក្បាយ និងស៊ីជម្រៅ យើងខ្ញុំនឹងធ្វើការឆ្លើយតបទៅនឹងសំណួរដូចបានលើកឡើងខាងលើដោយធ្វើការបកស្រាយអំពីខ្លឹមសារនៃប្រធានបទខាងលើនៅក្នុងប្រធានបទសារណានេះដែលបានធ្វើការបែងចែកនូវខ្លឹមសារដូចខាងក្រោម៖

- **ជំពូកទី១ ៖ សញ្ញាណទូទៅនៃគោលការណ៍នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដែលពាក់ព័ន្ធទៅនឹងភាគី**
- **ជំពូកទី២ ៖ ភាគីតាមផ្លូវបណ្តឹង**
- **ជំពូកទី៣ ៖ អ្នកតំណាងតាមផ្លូវបណ្តឹង**

# ជំពូកទី១

# សញ្ញាណទូទៅនៃគោលការណ៍
# នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី
# ដែលទាក់ទងទៅនឹងភាគី

## ជំពូកទី១

## សញ្ញាណទូទៅនៃគោលការណ៍នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដែលទាក់ទងទៅនឹងភាគី

ក្រមនីតិវិធីរដ្ឋប្បវេណីបញ្ញត្តអំពីគោលការណ៍ទូទៅ ដែលបានទាក់ទងទៅនឹងទំនាក់ទំនងគតិយុត្ត ផ្នែករដ្ឋប្បវេណី និងគោលការណ៍ជាមូលដ្ឋាន គឺការធានាសេចក្ដីថ្លៃថ្នូររបស់បុគ្គលភាពស្មើគ្នារវាងបុរស នារី និងសិទ្ធិលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ។ ក្រមរដ្ឋប្បវេណី គឺជាវិធានមួយដែលបានស្ថិតក្នុងប្រព័ន្ធនៃនិតិរដ្ឋបានបញ្ញត្តិនៅរាល់ទំនាក់ទំនងសង្គមមានលក្ខណៈពេញលេញដែលមានទំនាក់ទំនងញាតិ និងគ្រួសារដែលជាប្រធាននៃទំនាក់ទំនងចូលរួមដោយសមភាព និងជាមូលដ្ឋាននៃនីតិឯកជន។ ក្រមនីតិវិធីរដ្ឋប្បវេណីជាសមិទ្ធិផលផ្នែកបញ្ញាស្មារតីរបស់ប្រជាពលរដ្ឋកម្ពុជាដែលមានអានុភាពទៅលើរាល់ទំនាក់ទំនងសង្គម នៅក្នុងដំណាក់កាលនៃការដោះស្រាយបណ្តឹងផ្នែករដ្ឋប្បវេណីជាទូទៅ[1]។ គ្រប់សកម្មភាព នៅក្នុងកិច្ចការតាក់តែងក្រមនេះត្រូវបានប្រព្រឹត្តទៅដោយផ្អែកលើស្ថានភាពពិតនៃសង្គមកម្ពុជា និងតម្រូវការចាំបាច់របស់សង្គមនៅក្នុងពេលបច្ចុប្បន្ន និងអនាគត។ គោលបំណងនៃបណ្ដឹងរដ្ឋប្បវេណី ពាក់ព័ន្ធសិទ្ធិពឹងពាក់តុលាការដើម្បីឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណីដោយផ្អែកទៅលើច្បាប់ ដើម្បីការពារសិទ្ធិបុគ្គលឯកជន និងដើម្បីឱ្យជនគ្រប់រូបត្រូវបានធានាសិទ្ធិពឹងពាក់។ ប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីមានគោលបំណងការពារសិទ្ធិស្របច្បាប់របស់បុគ្គលឯកជន តាមរយៈការដោះស្រាយវិវាទដោយបង្ខំ។ នៅក្នុងគោលបំណងនេះ[2]ក្រមនីតិវិធីរដ្ឋប្បវេណី ( ចាប់ពីត្រង់នេះទៅ មាត្រាទាំងឡាយណាដែលត្រូវបានលើកឡើងដោយមិនបញ្ជាក់ពីឈ្មោះច្បាប់ គឺបានសំដៅទៅលើមាត្រានៃក្រមនីតិវិធីរដ្ឋប្បវេណី ) បានចែងថា បណ្ដឹងរដ្ឋប្បវេណីមានគោលបំណងឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណីដោយផ្អែកទៅលើច្បាប់ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន។ បណ្ដឹងរដ្ឋប្បវេណីដោះស្រាយវិវាទរវាងភាគីដោយបង្ខំ និងភាគីដោយផ្ទាល់ ឱ្យគោរពទៅតាមសេចក្ដីសម្រេចរបស់តុលាការ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ រដ្ឋបង្កើតប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីនេះឡើង មិនមែនក្នុងគោលបំណងធ្វើការដោះស្រាយវិវាទនោះឯងទេ តែគឺដើម្បីធ្វើការទទួលស្គាល់តាមរយៈតុលាការថា បុគ្គលម្នាក់មានសិទ្ធិស្របច្បាប់ និងដើម្បីការពារសិទ្ធិរបស់បុគ្គលនោះដោយបញ្ចប់នូវវិវាទ។ ហេតុដូច្នេះហើយវាមិនមែនមានន័យថា ការដោះស្រាយវិវាទអាចនាំឱ្យកើតជាលទ្ធផលអ្វីដល់ភាគីនោះទេ។

---

[1] ហ៊ី សោភា, សៀវភៅស្ដីអំពី នីតិវិធីរដ្ឋប្បវេណី ។

[2] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២ កថាខណ្ឌទី ១។

## ១.១ គោលការណ៍ជាមូលដ្ឋាន

គោលការណ៍ជាមូលដ្ឋាន គឺជាគោលគំនិតឆន្ទៈនយោបាយសាធារណៈរបស់រដ្ឋដែលមានលក្ខណៈចាប់បង្ខំចង្អុលបង្ហាញ និងចង្អុលចំពោះប្រព័ន្ធនៃបណ្ដាបទប្បញ្ញត្តិនៃនីតិវិធី និងស្ដែងឡើងនូវលក្ខណៈពិសេសនៃក្រមនីតិវិធីរដ្ឋប្បវេណីដោយផ្ដើមចេញពីទស្សនៈឆន្ទៈរបស់រដ្ឋចំពោះស្ថានភាពរបស់សង្គមជាក់ស្ដែងតាមបណ្ដាបទដ្ឋានគតិយុត្តដែលមានតម្លៃខ្ពស់បំផុត គឺរដ្ឋធម្មនុញ្ញច្បាប់ដែលជាបទដ្ឋានជាន់ខ្ពស់ដូចជាច្បាប់ចាត់តាំងតុលាការជាអាទិ៍ច្បាប់ដែលពាក់ព័ន្ធដទៃទៀត គោលនយោបាយឯកជន រួមទាំងតម្រូវការ និងការទាមទាររបស់សង្គមជាតិ និងអន្តរជាតិផងដែរ[3]។ និយាយដោយឡែកគោលការណ៍ជាមូលដ្ឋានអាចចាត់ទុកជាគ្រោងឆ្អឹងនៃច្បាប់ ដែលទ្រទ្រង់ប្រព័ន្ធច្បាប់ទាំងមូលឱ្យមានជំហររឹងប៉ឹង និងមានចលនារស់រវើកនៅពេលដែលច្បាប់នោះបានចូលអនុវត្ត។ ក្រមនីតិវិធីរដ្ឋប្បវេណី ពឹងផ្អែកទៅលើគោលការណ៍ជាមូលដ្ឋានមួយចំនួនដូចខាងក្រោម ហើយគោលការណ៍ដែលជាគោលការណ៍មូលដ្ឋាននៃនីតិរដ្ឋប្រជាធិបតេយ្យផងដែរ។

## ១.២ គោលការណ៍ស្វ័យភាពឆន្ទៈបុគ្គលឯកជន

គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន គឺអាចបង្កើតទំនាក់ទំនងគតិយុត្តនានាទៅតាមឆន្ទៈរបស់ខ្លួននៅក្នុងរឿងរដ្ឋប្បវេណី។ សេរីភាពនៃឆន្ទៈរបស់បុគ្គល និងបញ្ញត្តិអំពីទំនាក់ទំនងគតិយុត្តប្រកបដោយសមភាពរវាងបុគ្គលឯកជនដោយរួមបញ្ចូលគ្នាទាំងនីតិបុគ្គល។ នីតិបុគ្គលសាធារណៈដែលនៅក្នុងទំនាក់ទំនងនៃការជួញដូរត្រូវចាត់ទុកថាជាបុគ្គលឯកជន[4]។ មានន័យថាក្រមរដ្ឋប្បវេណីចាត់ទុកថា បុគ្គលនីមួយៗមានសមភាពរវាងគ្នាទៅវិញទៅមក។ ប៉ុន្តែតាមការជាក់ស្ដែងនៅក្នុងសង្គមយើងផ្ទាល់ដោយបុគ្គលមិនអាចចាត់ទុកថាមានភាពស្មើគ្នាបានទេ គឺមានភាពមិនស្មើគ្នានៅក្នុងសង្គម។ ហេតុដូចនេះហើយ ទើបមានការបង្កើតឲ្យមាននៅច្បាប់ពិសេស។

ឧទាហរណ៍៖ រវាងនិយោជក និងនិយោជិត មានឋានៈខុសគ្នា និងមានតម្លៃខុសគ្នា។ ច្បាប់ការងារគោរពទៅតាមផលប្រយោជន៍របស់អ្នកធ្វើការងារច្រើន។ ច្បាប់ខ្លះមានការការពារផលប្រយោជន៍របស់អ្នកប្រើប្រាស់ច្រើនជាងផលិតករ មានន័យថាគេឱ្យទទួលខុសត្រូវច្រើនក្នុងការធ្វើការងារផលិតកម្ម។ ដោយឡែកក្រមរដ្ឋប្បវេណីជាច្បាប់ទូទៅហើយចែងពីគោលការណ៍មូលដ្ឋាន ដូចច្នេះហើយទោះបីជាមិនមានភាពស្មើគ្នាក៏

[3] ហ៊ឺ សោភា, សៀវភៅស្ដីអំពី នីតិវិធីរដ្ឋប្បវេណី។

[4]ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣។

ដោយក៏ច្បាប់នេះចាត់ទុកថាមានភាពស្មើគ្នាផងដែរ ដោយមានការបែងចែក ពីការបញ្ញត្តិជានៃគោលការណ៍ជាមូលដ្ឋាននៃសិទ្ធិចាត់ចែង និងគោលការណ៍ជាមូលដ្ឋាននៃបុគ្គលនីមួយៗ។ មានន័យថា បុគ្គលនីមួយៗអាចចាត់ចែងគ្រប់គ្រងសិទ្ធិដោយផ្អែកលើសេរីភាពផ្ទាល់របស់ខ្លួនឯងបាន។

## ១.៣ គោលការណ៍ធានានូវសិទ្ធិទាមទារសវនាការ

ការធានានូវសិទ្ធិទាមទារសវនាការដោយសារថាភាគីនៃបណ្ដឹងរដ្ឋប្បវេណី ត្រូវអនុវត្តតាមសេចក្ដីសម្រេចរបស់តុលាកា រហេតុនេះហើយប្រសិនបើសេចក្ដីសម្រេចនោះមិនមានភាពត្រឹមត្រូវនោះទេវាអាចនឹងបំពានលើសិទ្ធិរបស់បុគ្គលឯកជនដោយមិនសមហេតុផល។ ហេតុដូចនេះហើយទើបក្រមនីតិវិធីរដ្ឋប្បវេណីផ្ដល់ការធានាដល់សិទ្ធិនីតិវិធីយ៉ាងច្រើនរបស់ភាគីនៃបណ្ដឹងរដ្ឋប្បវេណីដើម្បីឱ្យពួកគេអាចចូលរួមនៅក្នុងដំណើរការរឿងក្ដី និងអាចការពារផលប្រយោជន៍របស់ខ្លួនបាន[5]។ សិទ្ធិដែលមានសារៈសំខាន់ជាមូលដ្ឋាននៅក្នុងចំណោមសិទ្ធិនីតិវិធីនានាទាំងអស់នោះអាចហៅបានជារួមថា "សិទ្ធិមូលដ្ឋាននៃនីតិវិធី" ។ ក្នុងចំណោមសិទ្ធិមូលដ្ឋាននៃនីតិវិធីដែល មានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី សិទ្ធិនីតិវិធីដែលសំខាន់ជាងគេបំផុតនោះ គឺសិទ្ធិទាមទារឱ្យសាកសួរ។ សិទ្ធិទាមទាមឱ្យសាកសួរ គឺជាសិទ្ធិទាមទារឱ្យមានការធានានូវឱកាសក្នុងការបញ្ចេញមតិយោបល់របស់ខ្លួនដែលពាក់ព័ន្ធទៅនឹងបញ្ហាដែលត្រូវសម្រេចសេចក្ដីដោយតុលាការនៅក្នុងនីតិវិធីរដ្ឋប្បវេណី និងនៅក្នុងការឆ្លើយតបទៅនឹងមតិយោបល់របស់ភាគីម្ខាងទៀត។ រដ្ឋត្រូវបានបង្កើតឲ្យមាននូវនីតិវិធីរដ្ឋប្បវេណីដែលធានានូវឱកាសបែបនេះទៅដល់ភាគី។ ហើយជាគោលការណ៍ ឱកាសក្នុងការបញ្ចេញមតិយោបល់របស់ខ្លួន និងមានឱកាសក្នុងការឆ្លើយតបទៅនឹងយោបល់របស់ភាគីម្ខាងទៀតត្រូវតែផ្ដល់ឲ្យភាគីនៅមុនការសម្រេចសេចក្ដី[6] ប៉ុន្តែនៅក្នុងករណីពិសេសបន្ទាន់ការសម្រេចសេចក្ដីអាចត្រូវធ្វើឡើងជាមុន ហើយក្រោយមកទើបអនុញ្ញាតឱ្យស្ដាប់យោបល់របស់ភាគីដែលបានទទួលរងនូវរាល់ការខូចខាតនៅផលប្រយោជន៍ ដោយសារការសម្រេចសេចក្ដីបែបនេះបាន[7]។

## ១.៤ គោលការណ៍ចំពោះមុខ

ដើម្បីធានានូវសិទ្ធិទាមទារឱ្យសាកសួរ ហើយប្រសិទ្ធិភាព ការជម្រះក្ដីត្រូវតែធ្វើឡើងដោយការកោះហៅភាគីទាំងសងខាងឱ្យមកបង្ហាញខ្លួនទៅតាមកាលបរិច្ឆេទតែមួយ ហើយត្រូវឱ្យមានភាគីប្រឈមមុខដាក់គ្នាដោយផ្ទាល់។ ប្រសិនបើអនុញ្ញាតឱ្យតុលាការកោះហៅភាគីតែម្ខាង ហើយស្ដាប់ការអះអាងរបស់ភាគីនោះដោយ

[5] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ ( នីតិវិធីបណ្ដឹង )។

[6]ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/ រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣ កថាខណ្ឌទី១។

[7]ក្រមរដ្ឋប្បវេណី, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា២៣២ កថាខណ្ឌទី១ និងមាត្រា៥៤៨ កថាខណ្ឌទី៥។

ពុំមានវត្តមានរបស់ភាគីម្ខាងទៀត នោះអាចនឹងមានការប៉ះពាល់ដល់ទំនុកចិត្តរបស់ភាគីទៅលើភាពយុត្តិធម៌នៃការវិនិច្ឆ័យ។

ហេតុនេះហើយ បានជាមានបញ្ញត្តិចែងថាជាគោលការណ៍តុលាការត្រូវវិនិច្ឆ័យដោយគោរពគោលការណ៍ចំពោះមុខ ពោលគឺត្រូវកោះហៅភាគីទាំងសងខាងឱ្យភាគីទាំងសងខាងថ្លែងអំពីអំណះអំណាងរបស់ខ្លួន និងធ្វើការជជែកតតាំងគ្នាទៅវិញទៅមក[8]។ គោលការណ៍ចំពោះមុខត្រូវបានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ក្នុងគោលបំណងធានានូវភាពយុត្តិធម៌ និងទំនុកចិត្តរបស់ភាគី ក៏ដូចជាពលរដ្ឋទូទៅ ចំពោះប្រព័ន្ធដោះស្រាយនីតិវិធីនៃបណ្តឹង។ ទោះបីជាបែបនេះក៏ដោយ ក៏មានករណីលើកលែងខ្លះត្រូវបានទទួលស្គាល់ថាជាករណីពិសេសផងដែរ ដូចជាក្នុងករណីដែលការសម្រេចសេចក្តីដោយសាលក្រមកំបាំងមុខដើមចោទ[9] សាលក្រមកំបាំងមុខចុងចម្លើយ[10] និងការចេញដីការ សម្រេចដាស់តឿនជាអាទិ៍[11]។

## ១.៥ គោលការណ៍ទទួលខុសត្រូវនាគី

នៅក្នុងរបបបណ្តឹងរដ្ឋប្បវេណីភាគីត្រូវបានទទួលស្គាល់ថាមានសេរីភាព និងមានសិទ្ធិចាត់ចែងក្នុងបណ្តឹងរដ្ឋប្បវេណីដើម្បីផលប្រយោជន៍របស់ខ្លួន ពោលគឺការទទួលបាននូវសាលក្រមដែលសម្រេចឱ្យខ្លួនឈ្នះក្តី។ ក៏ប៉ុន្តែភាគីមិនត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពដោយទុច្ចរិត និងមិនស្មោះត្រង់ចំពោះភាគីម្ខាងទៀតបានឡើយ។ សកម្មភាពដែលផ្ទុយទៅនឹងភាពសុចរិតស្មោះត្រង់ត្រូវបានវិនិច្ឆ័យដោយបានយោងទៅតាមករណីជាក់ស្តែងនីមួយៗ និងយោងទៅតាមបទបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីដែលបានបញ្ញត្តិនឹងចាត់ទុកថាសកម្មភាពមួយចំនួនរបស់ភាគី គឺជាសកម្មភាពដែលផ្ទុយទៅនឹងភាពសុចរិតស្មោះត្រង់ ហើយដែលលទ្ធផលរបស់សកម្មភាពទាំងនោះនឹង នាំមកនូវការខូចខាតប្រយោជន៍របស់ភាគីដែលបានធ្វើសកម្មភាពមិនត្រឹមត្រូវ[12] ។

សិទ្ធិចាត់ចែងរបស់ភាគី គឺជាការសម្រេចអំពីកម្មវត្ថុ និងទំហំនៃការជំនុំជម្រះ និងការសម្រេចលើកម្មវត្ថុនៃការជំនុំជម្រះ និងការចេញសាលក្រមនៅក្នុងបណ្តឹង គឺជាការទាមទារតាមផ្លូវបណ្តឹង។ បណ្តឹងដែលបានធ្វើ

[8] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣ កថាខណ្ឌទី២។

[9] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា២០០។

[10] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា២០១។

[11] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, ៣២៣។

[12] សកម្មភាពដែល នីតិវិធីរដ្ឋប្បវេណីចាត់ទុកថាជួយនឹងភាពសុចរិត ស្មោះត្រង់ដូចជា ការលើកចោលមធ្យោបាយតទល់ ឬការការពារខ្លួនដែលបានដាក់ដោយយឺតយ៉ាវ (មាត្រា៩៤) អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (មាត្រា១០៨) អានុភាពនៅក្នុងករណីដែលភាគីមិនអនុវត្តតាមដីកាសម្រេចបង្គាប់ឱយផ្តល់ឯកសារជាអាទិ៍ (មាត្រា១៥៣)។

ឡើងដោយដើមចោទតាមរយៈការដាក់ពាក្យបណ្ដឹង តុលាការអាចចាប់ផ្ដើមធ្វើការជំនុំជម្រះបាន តែនៅពេលណាដែលទទួលបានពាក្យបណ្ដឹងរបស់ដើមចោទប៉ុណ្ណោះ។

តុលាការមិនអាចចាប់ផ្ដើមនីតិវិធីនៃបណ្ដឹងបានឡើយ ប្រសិនបើពុំមានពាក្យបណ្ដឹងពីភាគីនោះទេ។ ម្យ៉ាងវិញទៀត ជាគោលការណ៍នៅពេលដែលមានការដាក់ពាក្យបណ្ដឹងហើយ ការជំនុំជម្រះត្រូវបានចាប់ផ្ដើមចំណុចដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង ឬការទាមទារនៅក្នុងបណ្ដឹងអាចត្រូវបានជំនុំជម្រះ និងចេញសាលក្រមតែត្រឹមទំហំដែលបានសុំតែប៉ុណ្ណោះ។

ឧទាហរណ៍៖ ក្នុងករណីដែលដើមចោទប្ដឹងទារប្រាក់ចំនួន ៨ លានរៀលក្នុងចំណោម ១០ លានរៀល តុលាការមិនអាចចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយសងប្រាក់លើសពី ៨ លានរៀលបានទេ បើទោះបីជាតុលាការយល់ឃើញថាដើមចោទមានសិទ្ធិទាមទារប្រាក់រហូតដល់ ១០ លានរៀលក៏ដោយ។ នេះមានន័យថាភាគីមានសិទ្ធិសម្រេចអំពីកម្មវត្ថុ និងទំហំនៃការជំនុំជួយ និងការចេញសាលក្រមនៅក្នុងបណ្ដឹង[13] ។

ការបញ្ចប់បណ្ដឹងដោយផ្អែកទៅលើឆន្ទៈរបស់ភាគី ម្យ៉ាងវិញទៀតទោះបីជានីតិវិធីនៃបណ្ដឹងត្រូវបានចាប់ផ្ដើមហើយក៏ដោយ ដើមចោទអាចដកពាក្យបណ្ដឹង និងបញ្ចប់ពាក្យបណ្ដឹងបាន ក៏ប៉ុន្តែក្នុងករណីជាក់លាក់មួយចំនួនចាំបាច់ត្រូវមានការយល់ព្រមពីចុងចម្លើយ។ លើសពីនេះទៀត ភាគីអាចបញ្ចប់បណ្ដឹង ដោយមិនចាំបាច់រង់ចាំសាលក្រមចុងក្រោយបាន តាមរយៈការលះបង់ការទទួលស្គាល់នូវការទាមទារ ឬតាមរយៈការផ្សះផ្សាលើបណ្ដឹង។

គោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី និងមូលដ្ឋាននៃសិទ្ធិដូចបានពន្យល់ខាងលើ គោលការណ៍ដែលអនុញ្ញាតឱ្យភាគីធ្វើការសម្រេចចិត្ត( ការចាត់ចែង )ដោយផ្អែកលើឆន្ទៈរបស់ខ្លួន អំពីការចាប់ផ្ដើមបណ្ដឹង អំពីកម្មវត្ថុបណ្ដឹង ទំហំនៃការជំនុំជម្រះ ការចេញសាលក្រម និងការបញ្ចប់បណ្ដឹងគេហៅថាគោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី។

មូលដ្ឋាននៃការកំណត់យកគោលការណ៍នៃសិទ្ធិចាត់ចែងមកដាក់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនេះ គឺដោយសារ ផ្អែកលើគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន។ មានន័យថាសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលជាកម្មវត្ថុនៃណ្ដឹង រដ្ឋប្បវេណីអាចត្រូវបានចាត់ចែងដោយសេរីដោយផ្អែកតាមឆន្ទរបស់ភាគី។ ប្រសិនបើតុលាការដែលជាស្ថាប័នរដ្ឋ ចាប់ផ្ដើមបណ្ដឹង ហើយចេញសាលក្រមលើសពីទំហំដែលភាគីទាមទារ នោះត្រូវចាត់ទុកថាជាការរំលោភបំពានទៅលើគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន។ ប៉ុន្តែ ភាគីត្រូវតែអនុវត្តបណ្ដឹងដោយភាព

[13]ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៨២ កថាខណ្ឌទី២។

ស្មោះត្រង់ និងសុចរិត[14]។ សកម្មភាពបណ្តឹងដែលត្រូវបានចាត់ទុកថា មិនមានភាពស្មោះត្រង់ត្រូវកំណត់តាមករណីជាក់ស្តែងនីមួយៗ។ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីមានបញ្ញត្តិពាក់ព័ន្ធនឹងអានុភាពមិនអំណោយផលមួយចំនួនដែលកើតចេញពីការមិនគោរពកាតព្វកិច្ចអនុវត្តសកម្មភាពបណ្តឹងដោយស្មោះត្រង់ និងសុចរិត។

## ១.៦ ភាសាដែលភាគីត្រូវប្រើ

ភាសា និងអក្សរដែលប្រើជាផ្លូវការ គឺភាសាខ្មែរ និងអក្សរខ្មែរ[15]។ នៅក្នុងនាមជារដ្ឋមួយដែលប្រកបដោយអធិបតេយ្យភាព ឯករាជ្យភាព និងមិនអាចបំបែកបានទេ ព្រះរាជាណាចក្រកម្ពុជាមានភាសា និងអក្សររបស់ជាតិខ្លួននោះគឺ ភាសា និងអក្សរខ្មែរ ដែលត្រូវបានប្រើប្រាស់ជាផ្លូវការនៅក្នុងសកម្មភាពគ្រប់គ្រងរដ្ឋ។ តុលាការជាស្ថាប័នមួយដែលទទួលអនុវត្តអំណាចមួយនៅក្នុងចំណោមអំណាចទាំងបីរបស់ រដ្ឋពោលគឺអំណាចតុលាការ ដូចនេះភាសាដែលត្រូវប្រើក្នុងតុលាការត្រូវតែជាភាសាខ្មែរ។ ក្រមនីតិវិធីរដ្ឋប្បវេណីបានបញ្ញត្តិយកភាសាខ្មែរ ជាភាសាដែលត្រូវប្រើប្រាស់នៅក្នុងតុលាការ[16]។ ភាគីដែលមិនអាចយល់ភាសាខ្មែរ អាចស្នើសុំរកអ្នកបកប្រែភាសាដែលអាចយល់បាន។ សិទ្ធិទាមទារឱ្យសាកសួរសវនាការ និងគោលការណ៍ចំពោះមុខ ព្រមទាំងភាពយុត្តិធម៌ក្នុងការសម្រេចសេក្តី និងមិនត្រូវបានធានាឡើយ ប្រសិនបើភាគីណាមួយពុំអាចយល់បាននូវភាសាខ្មែរបាននោះទេ ដូចនេះសិទ្ធិទាមទារអោយមានការបកប្រែភាសារបស់ភាគីត្រូវបានទទួលស្គាល់ ថាជាគោលការណ៍មូលដ្ឋានមួយ នៅក្នុងចំណោមគោលការណ៍ជាមូលដ្ឋានផ្សេងទៀតនៃក្រមនីតិវិធីរដ្ឋប្បវេណី ហើយបញ្ហារកអ្នកបកប្រែ គឺជាបន្ទុករបស់រដ្ឋនៅក្នុងករណីដែលភាគីមិនមានលទ្ធភាពរកអ្នកបកប្រែដោយខ្លួនឯងបាន។

---

[14]ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤។

[15] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៥។

[16]ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥ កថាខណ្ឌទី១។

# ជំពូកទី២

# ភាគីតាមផ្លូវបណ្តឹង

# ជំពូកទី២
# ភាគីតាមផ្លូវបណ្ដឹង

## ២.១ និយមន័យភាគី និងសមត្ថភាពភាគី

បុគ្គលទាំងឡាយណាដែលអាចមានលក្ខណៈសម្បត្តិជាភាគីទៅបាន[17]លុះត្រាតែមានសិទ្ធិ និងករណីយកិច្ចតាមច្បាប់សារធាតុ ( ក្រមរដ្ឋប្បវេណី និងច្បាប់ផ្សេងទៀត )។ ភាគីនៃបណ្ដឹង គឺអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល។ នៅក្នុងសំណុំរឿងអង្គសេចក្ដី ភាគីដែលបានដាក់បណ្ដឹងហៅថា « ដើមចោទ » ហើយចំណែកភាគីម្ខាងទៀតហៅថា « ចុងចម្លើយ »។ នៅក្នុងសំណុំរឿងអនុវត្តដោយបង្ខំ ភាគីដែលបានដាក់ពាក្យសុំហៅថា « ម្ចាស់បំណុលនៃការអនុវត្ត » ហើយភាគីម្ខាងទៀតហៅថា « កូនបំណុលនៃការអនុវត្ត »។ នៅក្នុងសំណុំរឿងរក្សាការពារ ភាគីដែលបានដាក់ពាក្យសុំហៅថា « ម្ចាស់បំណុល » ហើយភាគីម្ខាងទៀតហៅថា « កូនបំណុល »។ ការកំណត់អំពីភាគីនៃបណ្ដឹង មានភាពចាំបាច់ពីព្រោះភាគីនៃបណ្ដឹង គឺជាបុគ្គលដែលប្ដឹងគេ ឬត្រូវបានគេប្ដឹង ហើយដើម្បីឱ្យបណ្ដឹងមានអានុភាពចងភាគី ដូចនេះហើយយើងត្រូវគិតអំពីសមត្ថភាពភាគីជាមុនសិន។ ច្បាប់ទទួលស្គាល់ថា មានតែបុគ្គលដែលមានលក្ខណៈសម្បត្តិដែលនោះទេដែលអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចប៉ុណ្ណោះទេទើបមានសមត្ថភាពជាភាគីនៃបណ្ដឹង ( សមត្ថភាពទទួលសិទ្ធិ )។ ប្រសិនបើជាភាគីនោះពុំមានសមត្ថភាពយល់ដឹងអំពីគោលបំណង ឬអានុភាពនៃសកម្មភាពបណ្ដឹង នៅពេលដែលបានធ្វើ ឬទទួលនូវសកម្មភាពបណ្ដឹងជាក់ស្ដែងបាននោះទេ បុគ្គលនោះមិនអាចការពារផលប្រយោជន៍របស់ខ្លួនតាមផ្លូវបណ្ដឹងបានឡើយ ហើយអាចបាត់បង់នូវផលប្រយោជន៍ច្រើន ហេតុនេះហើយបានជាច្បាប់ទទួលស្គាល់ថា ក្រៅពីសមត្ថភាពជាភាគីនៃបណ្ដឹង បុគ្គលនោះត្រូវមានសមត្ថភាពនៅក្នុងការធ្វើការសកម្មភាពបណ្ដឹងបន្ថែមទៀតផងដែរ។ បុគ្គលដែលមានលក្ខណៈសម្បត្តិជាភាគី រាប់បញ្ចូលទាំងអនីតិជន និងជននៅក្រោមអាណាព្យាបាលទូទៅ ជាអាទិ៍ ប៉ុន្តែជនទាំងនោះមិនអាចធ្វើសកម្មភាពបណ្ដឹងតាមផ្លូវតុលាការនោះទេ គឺត្រូវតែមានការទាមទារឱ្យមានអ្នកតំណាងដែលច្បាប់បានកំណត់ជាអាទិ៍ សម្រាប់ធ្វើសកម្មភាពបណ្ដឹងជំនួស ( សកម្មភាពបណ្ដឹងតាមផ្លូវតុលាការ )។

សមត្ថភាពភាគី គឺជាលក្ខណៈសម្បត្តិទូទៅដែលបានទទួលស្គាល់ដោយច្បាប់សារធាតុ ( ក្រមរដ្ឋប្បវេណី និងច្បាប់ផ្សេងទៀត ) ចំពោះបុគ្គលដែលអាចមានសិទ្ធិ និងកាតព្វកិច្ចតាមច្បាប់នេះគឺអាចជាដើមចោទ ឬចុងចម្លើយនៅក្នុងបណ្ដឹងរដ្ឋប្បវេណី។ រឿងក្ដីរដ្ឋប្បវេណី គឺជារបបមួយដើម្បីដោះស្រាយវិវាទរវាងបុគ្គលឯកជន តាម

[17] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២ កថាខណ្ឌទី១។

រយៈការកំណត់អំពីសិទ្ធិ និងកាតព្វកិច្ចតាមផ្លូវច្បាប់នៃនីតិឯកជន ឬអត្ថិភាព នត្ថិភាពនៃទំនាក់ទំនងគតិយុត្ត ដូចនេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណីដែលបានធ្វើការកំណត់ដោយផ្អែកលើប្រធាននៃទំនាក់ទំនងសិទ្ធិ និងកាតព្វកិច្ចតាមច្បាប់នៃនីតិឯកជនជាការត្រឹមត្រូវមួយ។ ដូចនេះហើយបានជារូបវន្តបុគ្គល និងនីតិបុគ្គល មានសមត្ថភាពជាភាគីនៅក្នុងបណ្តឹងរដ្ឋប្បវេណី។ ករណីពិសេស ទារកក្នុងគភ៌មានសមត្ថភាពទទួលសិទ្ធិស្តីពីការប្តឹងទាមទារសំណង នៃការខូចខាតដោយផ្អែកលើអំពើនីត្យានុកូល ឬបណ្តឹងពាក់ពន្ធ័នឹងសន្តតិកម្ម និងអច្ច័យទានផងដែរ។ ម្យ៉ាងទៀតនីតិបុគ្គល មានសមត្ថភាពទទួលសិទ្ធិក្នុងបណ្តឹង ដែលមានគោលបំណងជម្រះបញ្ជី ទោះបីជានីតិបុគ្គលនោះបានរំលាយហើយក៏ដោយ ដូចនេះនីតិបុគ្គលដែលបានរំលាយក៏មានសមត្ថភាពជាភាគីដែរ។

សមត្ថភាពភាគីក្នុងការធ្វើសកម្មភាពបណ្តឹង គឺជាលក្ខណៈដែលភាគី ឬបុគ្គលដែលបានពាក់ពន្ធ័នៅក្នុងនីតិវិធីនៃបណ្តឹងអាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងដោយមានអានុភាព ឬអាចទទួលសកម្មភាពបណ្តឹងរបស់តុលាការ ឬភាគីម្ខាងទៀតបាន។ មានន័យថា ភាគីមានសមត្ថភាពយល់ដឹងអំពីសកម្មភាព លទ្ធផលផ្នែកគតិយុត្តដែលបានកើតចេញ ពីសកម្មភាពរបស់ភាគីផ្សេងទៀតរួមទាំងអានុភាពតាមផ្លូវច្បាប់ដែលកើតចេញពីសកម្មភាពរបស់ខ្លួន ឬអាចយល់អំពីសកម្មភាពរបស់ភាគីផ្សេងទៀត រួមទាំងអានុភាពតាមផ្លូវច្បាប់ដែលបានកើតចេញពីសកម្មភាពទាំងនោះផងដែរ។ ដើម្បីការពារផលប្រយោជន៍របស់ជនដែលមានសមត្ថភាពជាភាគី ឬមានលក្ខណៈសម្បត្តិជាទូទៅជាភាគី ប៉ុន្តែពុំអាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងបាន នោះក្រមនីតិវិធីរដ្ឋប្បវេណីបានហាមឃាត់បុគ្គលមួយចំនួនមិនឱ្យមានការធ្វើសកម្មភាពបណ្តឹង ឬសកម្មភាពនៃបណ្តឹងរបស់បុគ្គលនោះមិនមានសុពលភាពបានឡើយ ប្រសិនបើសកម្មភាពមិនត្រូវបានធ្វើដោយអ្នកតំណាងដែលច្បាប់បានកំណត់។ របបធ្វើសកម្មភាពបណ្តឹងត្រូវបានផ្អែកទៅលើរបបនៃសកម្មភាពរបស់ប្រធាននៃសិទ្ធិ និងកាតព្វកិច្ច ដែលត្រូវបានកំណត់តាមច្បាប់សារធាតុ ( ច្បាប់រដ្ឋប្បវេណី ឬច្បាប់នៃនីតិឯកជនផ្សេងទៀត )។

ក្នុងក្របខណ្ឌនៃច្បាប់ទម្រង់ សមត្ថភាពគឺជាលក្ខខណ្ឌមួយនៅក្នុងចំណោមលក្ខខណ្ឌផ្សេងទៀតនៃបណ្តឹងដែលកំណត់ថា ដើម្បីក្លាយជាភាគីនៃបណ្តឹង លុះត្រាតែបុគ្គលនោះអាចមានសិទ្ធិ និងករណីយកិច្ចតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងច្បាប់ផ្សេងទៀតទើបអាចធ្វើជាដើមចោទ ឬជាចុងចម្លើយនៅក្នុងបណ្តឹងរដ្ឋប្បវេណីបាន យើងហៅថា សមត្ថភាពជាភាគីនៃបណ្តឹង[18] ។

[18]ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២ កថាខណ្ឌទី១។

ឧទាហរណ៍៖ លោក ក ម្ចាស់បំណុល បានឱ្យប្រាក់ទៅលោក ខ កូនបំណុល ខ្ចីចំនួន $10,000។ កំណត់សងបានមកកាន់លោក ខ មិនបានសងប្រាក់មកលោក ក នោះទេ ទោះបីជាលោក ក បានធ្វើការដាស់តឿនឱ្យសងក៏ដោយ។ ហេតុនេះលោក ក បានប្តឹង លោក ខ មកសាលាដំបូងរាជធានីភ្នំពេញ ដើម្បីទាមទារប្រាក់ $10,000។

ក្នុងករណីនេះលោក ក និងលោក ខ សុទ្ធតែជាបុគ្គលដែលមានសិទ្ធិ ( សិទ្ធិទាមទារប្រាក់កម្ចី ) ហើយនិងមានករណីយកិច្ច( ករណីយកិច្ចសងប្រាក់កម្ចី )តាមក្រមរដ្ឋប្បវេណី នាំឱ្យលោក ក និងលោក ខ អាចក្លាយទៅជាដើមចោទ និងចុងចម្លើយ។

ជាគោលការណ៍បុគ្គល( រូបវន្តបុគ្គល ឬនីតិបុគ្គល )ទទួលបានសិទ្ធិ ឬករណីយកិច្ចតាមច្បាប់សារជាតុជាបុគ្គលដែលមានលក្ខណៈសម្បត្តិ អាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច[19]ហៅថា « សមត្ថភាពទទួលសិទ្ធិ » ប៉ុន្តែទោះបីជាទារកក្នុងគភ៌ ក៏មានសមត្ថភាពទទួលសិទ្ធិផងដែរ ក្នុងករណីទាមទារសំណងនៃការខូចខាតផ្អែកលើអំពើអនីត្យានុកូល ឬបណ្តឹងពាក់ព័ន្ធនឹងសន្តតិកម្ម ឬអច្ច័យទាន[20] ។

ឧទាហរណ៍ ៖ ខ បានបើករថយន្តបុក ក ដែលពេលនោះកំពុងតែពរពោះកូន គ ហើយបណ្តាលឱ្យទារកក្នុងពោះនោះពិការភាពនៅពេលចាប់កំណើតមក។ ក្នុងករណីនេះផងដែរ គ អាចទាមទារសំណងការខូចខាតពីអំពើអនីត្យានុកូលដែល ខ បានបង្កចំពោះខ្លួន ( ពិការភាព ) បានក្រោយពេលដែល គ បានចាប់កំណើត។

ម្យ៉ាងវិញទៀត នីតិបុគ្គលដែលត្រូវបានជម្រះបញ្ជីដោយមូលហេតុក្ស័យធន នីតិបុគ្គលនោះត្រូវបានចាត់ទុកថា មានអត្ថិភាពរហូតទៅដល់ពេលដែលជម្រះបញ្ជីបានសម្រេចជាស្ថាពរនៅក្នុងទំហំនៃគោលបំណងដើម្បីជម្រះបញ្ជី[21] ។ ហេតុនេះបុគ្គលដែលមានលក្ខណៈសម្បត្តិក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច ជាបុគ្គលដែលមានសិទ្ធិតាមច្បាប់ និងមានសមត្ថភាពជាភាគីនៃបណ្តឹង។

ឧទាហរណ៍៖ ច ជាក្រុមហ៊ុនលក់សម្ភារៈសំណង់ ដែលបានចុះបញ្ជីនៅរាជធានីភ្នំពេញ ប៉ុន្តែក្រុមហ៊ុននេះ រកស៊ីខាតនាំឱ្យក្ស័យធន បានដាក់ពាក្យសុំប្រកាសក្ស័យធន និងជម្រះបញ្ជីតាមផ្លូវតុលាការ។ នៅក្នុងនីតិវិធីនៃការជម្រះតាមផ្លូវតុលាការនេះត្រូវចាត់ទុកថា ក្រុមហ៊ុន ច មានអត្ថិភាពបន្តទៀតរហូតដល់ពេលដែលនីតិវិធីនៃការជម្រះបញ្ជីត្រូវបានបញ្ចប់។

[19]ក្រមរដ្ឋប្បវេណី, លេខ នស/ រកម/ ១២០៧/ ០៣០, ០៨ ធ្នូ ២០០៧, មាត្រា៦ និង៨៦។
[20]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩។
[21]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៦៦។

## ២.២ សកម្មភាពភាគីនៅក្នុងបណ្តឹង និងសមត្ថភាពភាគីនៅក្នុងបណ្តឹង

### ២.២.១ សកម្មភាពភាគីនៅក្នុងបណ្តឹង

ភាគីមានសកម្មភាពយ៉ាងសកម្ម និងចម្បងបំផុតនៅក្នុងការធ្វើបណ្តឹង ឬរងបណ្តឹងនៅចំពោះមុខតុលាការរដ្ឋប្បវេណីដោយហេតុថាតុលាការរដ្ឋប្បវេណីជាតុលាការអកម្ម ដែលតម្រូវឱ្យភាគីត្រូវយល់ និងដឹងអំពីរបៀបអនុវត្តសិទ្ធិ ឬការពារសិទ្ធិតាមផ្លូវតុលាការ។ ភាគីដើរតួនាទីជាប្រធាននៃបណ្តឹងដោយបណ្តឹងអាចត្រូវបានចាត់ការ ឬសម្រេចតាមការចង់បាន ឬយ៉ាងណាអាស្រ័យទៅលើភាគី ដោយតុលាការជាតួរអង្គដែលបាជួយសម្របសម្រួលនូវសិទ្ធិរបស់ភាគី ប្រសិនបើការទាមទារ ឬការអះអាងនោះត្រឹមត្រូវតាមច្បាប់សារជាតុដោយមានភស្តុតាងបញ្ជាក់ ជាអាទិ៍។

### ២.២.២ សមត្ថភាពភាគីនៅក្នុងបណ្តឹង

សមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹង គឺជាលក្ខណៈសម្បត្តិដែលភាគី ឬបុគ្គលផ្សេងដែលពាក់ព័ន្ធក្នុងនីតិវិធីបណ្តឹងអាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងបានឱ្យមានអានុភាព ឬអាចទទួលនូវរាល់សកម្មភាពបណ្តឹងរបស់តុលាការ និងភាគីម្ខាងទៀតបាន។ ទោះជាភាគីមានសមត្ថភាពក៏ដោយ តែប្រសិនបើសាមីខ្លួនពុំមានសមត្ថភាពអាចយល់បាននូវគោលគំនិត ឬអានុភាពនៃសកម្មភាពនៅពេលដែលធ្វើ ឬទទួលសកម្មភាពបណ្តឹងជាក់ស្តែងបានទេ បុគ្គលនោះមិនអាចការពារផលប្រយោជន៍របស់ខ្លួនតាមបណ្តឹងបានទេ ហើយអាចបាត់បង់នូវផលប្រយោជន៍ច្រើនបាន។

ឧទាហរណ៍៖ អាចមានករណីដែលភាគីពុំមានសមត្ថភាពគ្រប់គ្រាន់អាចឆ្លើយតបភ្លាមៗចំពោះការអះអាងរបស់ភាគីម្ខាងទៀត ឬដាក់ភស្តុតាងដើម្បីបញ្ជាក់ការអះអាងរបស់ខ្លួនបានទេ ហើយដែលភាគីនោះនឹងចាញ់បណ្តឹង ដែលតាមការពិតសាមីខ្លួនអាចឈ្នះបាន។ ដូច្នេះដើម្បីការពារជនដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអះអាង និងការពារផលប្រយោជន៍របស់ខ្លួនតាមបណ្តឹងបាន ច្បាប់បង្កើតនូវរបបនៃសមត្ថភាពក្នុងការធ្វើបណ្តឹងដោយចាត់ទុកថា ជនទាំងនោះពុំមានលក្ខណៈសម្បត្តិធ្វើសកម្មភាពក្នុងការធ្វើបណ្តឹង ហើយឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ធ្វើសកម្មភាពបណ្តឹងជំនួសជននោះ។ របបនេះមានគោលគំនិតដូចគ្នានឹងរបបនៃសកម្មភាពក្នុងការធ្វើសកម្មភាព ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីដែរ[22] ។

បណ្តឹង គឺជានីតិវិធីកំណត់ជាស្ថាពរនូវអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ និងកាតព្វកិច្ច ឬទំនាក់ទំនងគតិយុត្តតាមក្រមរដ្ឋប្បវេណី ឬច្បាប់សារធាតុផ្សេងទៀត ហើយលទ្ធផលនៃបណ្តឹង គឺដូចជាការចាត់ចែងសិទ្ធិ និង

[22]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣២ កថាខណ្ឌទី២ និង ទី៣។

កាតព្វកិច្ច ឬ ទំនាក់ទំនងគតិយុត្តដែរ ហេតុនេះហើយជាគោលការណ៍ វិសាលភាពនៃជនដែលមានសមត្ថភាពក្នុងការធ្វើបណ្ដឹង ត្រូវបានសម្រេចដោយយកវិសាលភាពនៃជនដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាពតាមច្បាប់សារធាតុមកធ្វើជាបទដ្ឋាន។ ដូច្នេះ បុគ្គលទាំងឡាយដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាពយោងតាមបញ្ញត្តិនៃច្បាប់សារធាតុ ដូចជាក្រមរដ្ឋប្បវេណី ជាអាទិ៍ នឹងមានសមត្ថភាពក្នុងការធ្វើបណ្ដឹង[23]។ ខ អនីតិជន និងជននៅក្រោមអាណាព្យាបាលទូទៅស្ថិតក្នុងចំណោមជនដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព[24] អនីតិជន និងជនដែលនៅក្រោមអាណាព្យាបាលទូទៅជាគោលការណ៍ពុំមានសមត្ថភាពក្នុងការធ្វើបណ្ដឹងនោះទេ ហើយអាចធ្វើសកម្មភាពបណ្ដឹងសុពលបានលុះត្រាតែត្រូវបានធ្វើតាមអ្នកតំណាងដែលច្បាប់បានកំណត់[25]។ សកម្មភាពបណ្ដឹងដែលអនីតិជន និងជនដែលនៅក្រោមអាណាព្យាបាលទូទៅបានធ្វើមិនត្រឹមតែអាចលុបចោលទេ[26]។ ទោះជាមានការយល់ព្រមពីជនដែលមានសិទ្ធិអំណាចមេបា ឬពីអ្នកអាណាព្យាបាលក៏ដោយក៏ចាត់ទុកមោឃៈដែរ។ ក៏ប៉ុន្តែ ទោះបីជាអនីតិជនក៏ដោយតែក្នុងករណីដែលជននោះត្រូវបានចាត់ទុកថាដល់នីតិភាព ដោយសារអាពាហ៍ពិពាហ៍[27] ជននោះមានសមត្ថភាពនៅក្នុងការធ្វើបណ្ដឹងជាទូទៅ ម្យ៉ាងទៀតក្នុងករណីដែលអនីតិជនត្រូវបានអនុញ្ញាតឱ្យចាត់ចែងចំពោះទ្រព្យសម្បត្តិជាក់លាក់ពិសេស ឬត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម ហើយមានសមត្ថភាពក្នុងការធ្វើសកម្មភាពត្រឹមទំហំនោះ[28]ជននោះមានសមត្ថភាពនៅក្នុងការធ្វើបណ្ដឹង ចំពោះបណ្ដឹងដែលទាក់ទងនឹងទ្រព្យសម្បត្តិនោះ ឬអាជីវកម្មនោះ[29] ។

## ២.៣ ជនកម្រិតសកម្មភាពក្នុងការធ្វើសកម្មភាពបណ្ដឹង

ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្ដឹងរួមមាន អនីតិជន និងជននៅក្រោមអាណាព្យាបាលទូទៅ។ ជាគោលការណ៍អនីតិជន និងជននៅក្រោមអាណាព្យាបាលទូទៅពុំមានសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្ដឹងដោយខ្លួនឯងឡើយ ទោះបីជាមានការយល់ព្រម ឬក៏គ្មានការយល់ព្រមពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលទូទៅ( តំណាងដែលច្បាប់បានកំណត់ )ក៏សកម្មភាពបណ្ដឹងនោះមិនមានសុពលភាពឡើយ។ សកម្មភាពបណ្ដឹងដែលមានភាគីជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅអាចមានសុពលភាពបានលុះត្រាតែត្រូវបានធ្វើឡើងដោយអ្នកតំណាងដែលច្បាប់បានកំណត់។ ប៉ុន្តែនៅក្នុងករណី

[23]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣២ កថាខណ្ឌទី២។

[24]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១៦។

[25]ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២ កថាខណ្ឌទី៣ វាក្យខណ្ឌទី១។

[26]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១៨។

[27]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៨។

[28]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១៩ និង២០។

[29]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣២ កថាខណ្ឌទី៣ វាក្យខណ្ឌទី២។

ដែលអនីតិជន ត្រូវបានចាត់ទុកជានីតិជនដោយសារការរៀបអាពាហ៍ពិពាហ៍ ឬដោយសារត្រូវបានអនុញ្ញាតឱ្យចាត់ចែងពាក់ពន្ធ័នឹងទ្រព្យពិសេស ឬត្រូវបានអនុញ្ញាតឱ្យធ្វើអាជីវកម្ម នោះអនីតិជននេះមានសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្ដឹងពាក់ព័ន្ធទៅនឹង បណ្ដឹងស្ដីពីទ្រព្យសម្បត្តិ ឬអាជីវកម្មនោះ។

ចំណែកឯទាក់ទងទៅ នឹងករណីជនបរទេសនោះវិញ គឺជនបរទេសមានសមត្ថភាពក្នុងការធ្វើបណ្ដឹងដោយយោងទៅតាមបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ទោះបីជាជនបរទេសនោះពុំមានសមត្ថភាពក្នុងការធ្វើបណ្ដឹងដោយយោងតាមច្បាប់នៃប្រទេសរបស់ជននោះក៏ដោយក៏ត្រូវចាត់ទុកថាមានសមត្ថភាពក្នុងការធ្វើបណ្ដឹងនៅកម្ពុជាបានដែរ [30] ។

## ២.៣.១ អនីតិជន

អនីតិជន គឺសំដៅលើជនដែលមានអាយុក្រោម ១៨ ( ដប់ប្រាំបី ) ឆ្នាំ[31] ឬជនដែលមិនទាន់គ្រប់អាយុទៅតាមច្បាប់កំណត់ ហើយអនីតិជនត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព។

សកម្មភាពរបស់អនីតិជនត្រូវបានកម្រិតដោយទៅតាមការយល់ព្រម ឬសច្ចានុមតិ ( ការទទួលស្គាល់ដោយប្រតិសកម្ម ) របស់អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ទៅលើសកម្មភាពណាដែលមានការប៉ះពាល់ដល់ផលប្រយោជន៍របស់អនីតិជន ហើយសកម្មភាពដែលអនីតិជនបានធ្វើដោយឆន្ទៈរបស់ខ្លួនគ្មានការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលទូទៅសម្រាប់អនីតិជន អាចធ្វើការលុបចោលសកម្មភាពនោះបាន[32] ។

ប៉ុន្តែនូវក្នុងសកម្មភាពបណ្ដឹងក៏ត្រូវបានកម្រិតផងដែរចំពោះអនីតិជន លើកលែងតែអនីតិជនដែលត្រូវទទួលបានអត្តាធីនភាព។ អនីតិជនដែលត្រូវទទួលបានអត្តាធីនភាពត្រូវចាត់ទុកថាបានដល់នីតិភាព នៅក្នុងនោះល័ក្ខខ័ណ្ឌនៃអត្តាធីនភាពត្រូវចែកចេញជា ២ គឺ ៖ អនីតិជនដែលបានដល់អាយុ ១៦ ( ដប់ប្រាំមួយ ) ឆ្នាំ អាចមានសមត្ថភាពទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ[33] នោះតុលាការអាចប្រកាសនូវអត្តាធីនភាពទៅតាមពាក្យសុំរបស់អនីតិជននោះបាន និងអនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ត្រូវទទួលអត្តាធីនភាពដោយមិនចាំបាច់មានការប្រកាសដោយតុលាការនោះទេ។

---

[30]ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៤។

[31]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១៦។

[32]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១៨។

[33]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា២០។

### ២.៣.២ ជននៅក្រោមអាណាព្យាបាលទូទៅ

ជននៅក្រោមអាណាព្យាបាលទូទៅ គឺជាជនស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ខ្វះសមត្ថភាពនៅក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារតែមានវិបត្តិខាងផ្នែកបញ្ញាស្មារតី ( វិបល្លាសស្មារតី ជនវិកលចរិតជាអាទិ៍ )។ ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទៅត្រូវប្រកាសដោយតុលាការតាមពាក្យស្នើសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ ( បួន ) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាលបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវបានយកអនុវត្តនោះឡើយ ចំពោះករណីដែលជននោះមិនទាន់ដល់អាយុ ១៥ ( ដប់ប្រាំ ) ឆ្នាំ នៅពេលដាក់ពាក្យសុំ [34]។ នៅក្នុងន័យនេះផងដែរ ជននៅក្រោមអាណាព្យាបាលទូទៅមិនមានសមត្ថភាពក្នុងការធ្វើកិច្ចសន្យា ឬធ្វើបណ្តឹងបានទេ ដោយហេតុថាជននោះពុំមានការយល់ដឹងនូវសកម្មភាពរបស់ខ្លួនដែលបានធ្វើជាមួយភាគីម្ខាងទៀត បើសិនជាជននោះមិនបានប្រកាសចាប់ផ្តើមអាណាព្យបាលទូទៅ។

សកម្មភាពដែលធ្វើឡើងដោយជនក្រោមអាណាព្យាបាលទូទៅ ត្រូវកម្រិតដោយការយល់ព្រមរបស់អាណាព្យាបាលទូទៅ ឬការផ្តល់សច្ចានុមតិ លើកលែងតែសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់ជននៅក្រោមអាណាព្យាបាលទូទៅ។ ឧទាហរណ៍ ៖ ការទិញរបស់ប្រើប្រាស់ ឬរបស់ហូបដើម្បីបំពេញក្រពះជាប្រចាំថ្ងៃ។ ក្រៅពីការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ជននៅក្រោមអាណាព្យាបាលទូទៅ ក៏ត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯង ដោយឱ្យតម្រូវមានអ្នកតំណាងដែលច្បាប់កំណត់ គឺជាអ្នកអាណាព្យាបាលទូទៅ[35] ។

ម៉្យាងវិញទៀត សកម្មភាពបណ្តឹងទាក់ទងនឹងការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ ឬការទទួលស្គាល់នូវការទាមទារ ការដកពាក្យបណ្តឹងឧទ្ធរណ៍ ឬការដកពាក្យបណ្តឹងសាទុក្ខ ជាប្រភេទសកម្មភាពបណ្តឹង ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់ជននៅដែលបានក្រោមហិតូបត្ថម្ភ ច្បាប់តម្រូវឱ្យមានការប្រគល់សិទ្ធិជាពិសេសពីហិតូបត្ថម្ភកៈ។ សរុបមកអ្នកតំណាងដែលច្បាប់បានកំណត់សម្រាប់អនីតិជន គឺអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ចំណែកសម្រាប់ជនដែលនៅក្រោមអាណាព្យាបាលទូទៅ គឺអ្នកអាណាព្យាបាលទូទៅ។ រីឯហិតូបត្ថម្ភកៈ មិនមែនជាអ្នកតំណាងដែលច្បាប់បានកំណត់របស់ជននៅក្រោមហិតូបត្ថម្ភនោះទេ។

[34]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា២៤។

[35]ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២ កថាខណ្ឌទី៣។

**កំណត់សម្គាល់** ៖ ទោះបីជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ គឺជាជនដែលត្រូវបានចាត់ទុកថាមិនអាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងក៏ដោយ នៅក្នុងបណ្តឹងឋានៈបុគ្គល គឺត្រូវធ្វើសកម្មភាពដោយផ្អែកទៅលើឆន្ទៈរបស់សាមីខ្លួនមិនមែនអ្នកតំណាងនោះទេ ដូចនេះ គឺមានសមត្ថភាពក្នុងការធ្វើបណ្តឹង។ ប៉ុន្តែបើតាមការពិតអាចបណ្តាលឱ្យខូចផលប្រយោជន៍ពួកគេ ដូចនេះតុលាការអាចជ្រើសតាំងមេធាវីធ្វើជាអ្នកតំណាងដោយអាណត្តិឱ្យភាគីតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិ[36] ។

## ២.៣.៣ ជននៅក្រោមហិតូបត្ថម្ភ

ជននៅក្រោមហិតូបត្ថម្ភ គឺជាជនដែលមានសមត្ថភាពតិចតួចក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ដូចជាជនមានជំងឺទាក់ទងនឹងប្រព័ន្ធប្រសាទ ជាអាទិ៍ អាចដាក់ពាក្យសុំចាប់ផ្តើមហិតូបត្ថម្ភទៅតុលាការដើម្បីប្រកាសរបបនេះ។

ជនដែលបានទទួលការប្រកាសចាប់ផ្តើមរបបហិតូបត្ថម្ភហៅថា « ជននៅក្រោមហិតូបត្ថម្ភ » ហើយត្រូវស្ថិតនៅក្រោមការថែរក្សាដោយ « ហិតូបត្ថម្ភកៈ » [37]។

ទោះបីជាជននៅក្រោមហិតូបត្ថម្ភ ត្រូវបានចាត់ទុកថាជាជនដែលមានវិបត្តិខាងបញ្ញាស្មារតីមិនអាចវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនក៏ដោយ ប៉ុន្តែជននោះមានការយល់ដឹងច្រើនជាងជននៅក្រោមអាណាព្យាបាលទូទៅ ដូចនេះហើយសិទ្ធិនៃការលុបចោលនូវសកម្មភាពដែលធ្វើឡើងដោយជននៅក្រោមហិតូបត្ថម្ភ ដោយពុំមានការយល់ព្រមពីហិតូបត្ថម្ភកៈអាចត្រូវបានលុបចោលតែសកម្មភាពដែលច្បាប់បានកំណត់ប៉ុណ្ណោះ ដូចជាសកម្មភាពទទួល ឬប្រើប្រាស់ទុន ការខ្ចីទ្រព្យ ឬការធានា ការធ្វើសកម្មភាពដែលមានគោលបំណងទទួលបាន ឬធ្វើឱ្យបាត់បង់សិទ្ធិទាក់ទងនឹងអចលនវត្ថុ ឬទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀត និងការធ្វើសកម្មភាពបណ្តឹង ជាអាទិ៍ ។

ជាគោលការណ៍ ច្បាប់សារធាតុកម្រិតសកម្មភាពបណ្តឹងរបស់ជននៅក្រោមហិតូបត្ថម្ភមានន័យថា ជននៅក្រោមហិតូបត្ថម្ភមិនអាចធ្វើសកម្មភាពដោយពុំមានការយល់ព្រមពីហិតូបត្ថម្ភកៈឡើយ បើពុំដូច្នេះទេសកម្មភាពនោះអាចត្រូវបានមោឃៈ។ ក៏ប៉ុន្តែ បើយើងគិតបែបនេះបុគ្គលដែលមានបំណងក្នុងការធ្វើបណ្តឹងប្រឆាំងនឹងជននៅក្រោមហិតូបត្ថម្ភ មិនអាចធ្វើបណ្តឹងចំពោះជននោះបានទេបើមិនមានការយល់ព្រមពីហិតូបត្ថម្ភកៈ។

[36]ច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ២៦ មេសា ២០១០, មាត្រា៨ កថាខណ្ឌទី២។

[37]ក្រមរដ្ឋប្បវេណី, លេខ នស/ រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា២៨ និង២៩។

ម្យ៉ាងវិញទៀត ហិតូបត្ថម្ភកៈមិនមែនជាអ្នកតំណាងដែលច្បាប់បានកំណត់របស់ជននៅក្រោមហិតូបត្ថម្ភ នោះទេនាំឱ្យមិនអាចធ្វើសកម្មភាព តំណាងឱ្យជនជននៅក្រោមហិតូបត្ថម្ភបានឡើយ។

ដើម្បីសង្គ្រោះអលទ្ធភាពរបស់បុគ្គលដែលមានបំណងធ្វើបណ្តឹង ប្រឆាំងទៅនឹងជននៅក្រោមហិតូបត្ថម្ភ ច្បាប់ទម្រង់បានអនុញ្ញាតឱ្យបុគ្គលនានាអាចធ្វើការប្តឹងជននៅក្រោមហិតូបត្ថម្ភ និងអាចធ្វើសកម្មភាពបណ្តឹង បានដោយពុំចាំបាច់ត្រូវមានការយល់ពីហិតូបត្ថម្ភកៈ ឬអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ ឬការប្រគល់សិទ្ធិផ្សេងទៀត ឡើយ។ ក៏ប៉ុន្តែ ប្រសិនបើជននៅក្រោមហិតូបត្ថម្ភមានបំណងប្តឹងបុគ្គលណាម្នាក់ទាមទារឱ្យមានការយល់ព្រមពី ហិតូបត្ថម្ភកៈ[38]។

## ២.៤ នីតិបុគ្គល

នីតិបុគ្គល គឺជាក្រុមមនុស្ស ឬទ្រព្យសម្បត្តិដែលមាននូវបុគ្គលភាពគតិយុត្ត ហើយដែលច្បាប់បានកំណត់ ទទួលស្គាល់ថាមានសិទ្ធិ និងកាតព្វកិច្ចដូចរូបវន្តបុគ្គលដែរ។ នីតិបុគ្គល គឺមានភាពខុសពីរូបវន្តបុគ្គល ពោលគឺ នីតិបុគ្គល គឺជាក្រុមហ៊ុន ឬស្ថាប័នរដ្ឋ ឯកជន ជាអាទិ៍។ ចំណែកឯរូបវន្តបុគ្គលគេងាយកំណត់បាន ពីព្រោះជា មនុស្សមានរូបរាងសុទ្ធសាធតែម្តង។ ជាមួយគ្នានេះផងដែរ នីតិបុគ្គលមានសិទ្ធិប្តឹងទៅតុលាការ មានសិទ្ធជជែក តវ៉ា ការពារដូចជារូបវន្តបុគ្គលដែរ ទោះបីជានីតិបុគ្គលនោះមានសមាសភាពមនុស្សច្រើននាក់ក៏ដោយ។

### ២.៤.១ នីតិបុគ្គលសាធារណៈ

នីតិបុគ្គលសាធារណៈ សំដៅទៅដល់រដ្ឋ និងគ្រឹះស្ថានសាធារណៈរបស់រដ្ឋ។ រដ្ឋ គឺជានីតិបុគ្គលដែល ធំជាងគេដែលមានធាតុផ្សំចំនួនបួនគឺ៖ ទឹកដី ប្រជាជន រដ្ឋាភិបាល និងអធិបតេយ្យភាព។ ចំណែកគ្រឹះស្ថាន សាធារណៈជានីតិបុគ្គលសាធារណៈ ដែលគ្រប់គ្រងសេវាសាធារណៈប្រកបដោយស្វ័យភាពហិរញ្ញវត្ថុ។

ក្នុងនោះផងដែរ ព្រះរាជាណាចក្រកម្ពុជាមានច្បាប់ស្តីពីគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈរដ្ឋបាល ជា នីតិបុគ្គលនៃនីតិសាធារណៈដែលទទួលបន្ទុកចម្បងនូវផ្នែកសេវាសាធារណៈ ដែលមានលក្ខណៈជារដ្ឋបាល សង្គម សុខាភិបាល វប្បធម៌ វិទ្យាសាស្ត្របច្ចេកទេស។ល។ ឧទាហរណ៍៖ ព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរអប្សរា ដែល មានគ្រឹះស្ថានសាធារណៈរបស់រដ្ឋដើម្បីថែរក្សាការពារ និងរៀបចំតំបន់អង្គរ[39] និងព្រះរាជក្រឹត្យស្តីពីការដាក់ដំណើរការ សាលាឧទ្ទរណ៍តំបន់ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ទរណ៍តំបន់ត្បូងឃ្មុំ ក៏ជាគ្រឹះស្ថានសាធារណៈផងដែរ។

[38]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣០។
[39] ព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរ អប្សរា អនុម័តនៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៥។

## ២.៤.២ នីតិបុគ្គលឯកជន

នីតិបុគ្គលឯកជនចែកចេញជាពីរប្រភេទគឺ ៖ នីតិបុគ្គលស្វែងរកប្រាក់ចំណេញ និងនីតិបុគ្គលមិនស្វែងរកប្រាក់ចំណេញ។

នីតិបុគ្គលដែលស្វែងរកប្រាក់ចំណេញ គឺសំដៅដល់ក្រុមហ៊ុន និងសហគ្រាសទាំងឡាយដែល បង្កើតឡើងមានគោលបំណងស្វែងរកនូវប្រាក់ចំណេញ និយាយជារួមមក ក្រុមហ៊ុន ឬសហគ្រាសមួយត្រូវបានបង្កើតឡើងដោយមនុស្សពីរនាក់ ឬច្រើននាក់ តាមរយៈការព្រមព្រៀងគ្នា ដាក់ទ្រព្យសម្បត្តិ ចំណេះដឹង បច្ចេកទេស ឬជំនាញរបស់ពួកគេ ដើម្បីជាទុនក្នុងការបង្កើតក្រុមហ៊ុន ឬសហគ្រាសរួមមួយ ក្នុងគោលបំណងស្វែងរកប្រាក់ចំណេញដែលបានមកពី ក្រុមហ៊ុន ឬសហគ្រាសនោះ។

រីឯនីតិបុគ្គលមិនបានស្វែងរកប្រាក់ចំណេញវិញ គឺជាអង្គការ សមាគមន៍ សហជីពវិជ្ជាជីវៈទាំងឡាយណាដែលបានបង្កើតឡើងនៅក្នុងគោលបំណងបម្រើផលប្រយោជន៍ទៅដល់សាធារណៈជន ដោយមិនបានទទួលប្រាក់កម្រៃពីអង្គការសមាគមន៍ សហជីពវិជ្ជាជីវៈទាំងនោះឡើយ។ ឧទាហរណ៍៖ កាកបាទក្រហមកម្ពុជា និងសហភាពសហព័ន្ធយុវជនកម្ពុជា (សសយក)។

ម្យ៉ាងវិញទៀត នីតិបុគ្គលដែលត្រូវជម្រះបញ្ជី[40]ដោយមូលហេតុក្ស័យធន នីតិបុគ្គលនោះត្រូវបានចាត់ទុកថាមានអត្ថិភាពរហូតដល់ពេលជម្រះបញ្ជីនោះបានសម្រេចជាស្ថាពរ នៅក្នុងទំហំនៃគោលបំណងដើម្បីជម្រះបញ្ជី។ ហេតុនេះ បុគ្គលដែលមានលក្ខណៈសម្បត្តិក្លាយជាប្រធានសិទ្ធិ និងកាតព្វកិច្ច ជាបុគ្គលដែលមានសិទ្ធិតាមច្បាប់ និងមានសមត្ថភាពជាភាគីនៃបណ្តឹង។

## ២.៥ រូបវន្តបុគ្គល

សំដៅទៅដល់មនុស្សដែលមានសាច់ មានឈាម មានជីវិត មានរូបរាងកាយអាចប៉ះបាន និងមានការគិតពិចារណាហើយត្រូវបានការពារដោយច្បាប់ បន្ថែមពីនេះទៅទៀតរូបវន្តបុគ្គលទាំងអស់ត្រូវបានគាំពារពីប្រព័ន្ធច្បាប់ទាំងអស់ ជាក់ស្តែងជនទាំងអស់មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយមិនមានការរើសអើង វណ្ណៈ ភេទ អាយុ មុខរបរ សាសនា ទាំងអស់នេះហៅថាគោលការណ៍ទទួលបានសិទ្ធិ និងកាតព្វកិច្ចតាមការកំណត់របស់ច្បាប់។ បន្ថែមពីនេះទៅទៀត រូបវន្តបុគ្គលម្នាក់ៗមានសមត្ថភាពទទួលសិទ្ធិនៅពេលចាប់កំណើត ហើយបាត់បង់នូវសមត្ថភាពទទួលសិទ្ធិនេះនៅពេលទទួលមរណភាព។

[40] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៦៦។

# ជំពូកទី៣

# អ្នកតំណាង

# តាមផ្លូវបណ្តឹង

# ជំពូកទី៣

# អ្នកតំណាងតាមផ្លូវបណ្ដឹង

## ៣.១ អ្នកតំណាងតាមផ្លូវបណ្ដឹង និង លក្ខណៈសម្បត្តិរបស់អ្នកតំណាង

អ្នកតំណាងតាមផ្លូវបណ្ដឹង គឺជាបុគ្គលដែលមានសិទ្ធិស្របច្បាប់ ក្នុងការធ្វើសកម្មភាព ឬកិច្ចនីតិវិធីនីមួយៗក្នុងនាមភាគី ( ដើមចោទ ឬចុងចម្លើយ ) នៅចំពោះមុខតុលាការរដ្ឋប្បវេណី ហើយសកម្មភាពដែលអ្នកតំណាងតាមផ្លូវបណ្ដឹងបានធ្វើ ចាត់ទុកថាជាសកម្មភាពរបស់ភាគី។ អានុភាពនៃសកម្មភាពដែលអ្នកតំណាងតាមផ្លូវបណ្ដឹងធ្វើឱ្យមានចំណងតាមផ្លូវច្បាប់ចំពោះភាគី លើកលែងតែក្នុងករណីដែលភាគីបានបដិសេធភ្លាមៗ ប្រសិនបើភាគីមានវត្តមាន ឬប្រសិនបើភាគីគ្មានវត្តមាន គឺកាលបរិច្ឆេទបន្ទាប់នៃកិច្ចនីតិវិធីនោះ។

អ្នកតំណាងតាមផ្លូវបណ្ដឹង មានភាពចាំបាច់សម្រាប់សម្របសម្រួល កិច្ចនីតិវិធីឱ្យប្រព្រឹត្តិទៅបានល្អតាមការកំណត់នៃច្បាប់ទម្រង់ នៅក្នុងករណីដែលភាគីគឺជាជនដែលត្រូវបានកម្រិតសមត្ថភាពជាអាទិ៍។ ច្បាប់សារធាតុទទួលស្គាល់ថាបុគ្គលគឺជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចប៉ុន្តែមិនមែនគ្រប់បុគ្គលទាំងអស់មានសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្ដឹងនោះទេ ហេតុនេះដើម្បីកុំឱ្យមានការកេងចំណេញ ឬខូចប្រយោជន៍ដល់បុគ្គលដែលមិនមានសមត្ថភាពពេញលេញក្នុងការវិនិច្ឆ័យ ឬយល់ដឹងអំពីលទ្ធផលនៃសកម្មភាពបណ្ដឹងចាំបាច់តម្រូវឱ្យមានអ្នកតំណាងតាមផ្លូវបណ្ដឹង។

- **តួនាទីរបស់អ្នកតំណាងតាមផ្លូវបណ្ដឹង**

អ្នកតំណាងតាមផ្លូវបណ្ដឹងតាមតួនាទីសំខាន់ៗ ដូចខាងក្រោម ៖

- ការពារផលប្រយោជន៍ស្របច្បាប់របស់ភាគីដែលខ្លួនតំណាង
- ធ្វើសកម្មភាពនានាដែលច្បាប់តម្រូវក្នុងនាមជាភាគី
- បំពេញកិច្ចនីមួយៗដែលតុលាការបង្គាប់ឱ្យធ្វើ

- **ប្រភេទនៃអ្នកតំណាងតាមផ្លូវបណ្ដឹង**

អ្នកតំណាងតាមផ្លូវបណ្ដឹងត្រូវបានបែងចែកជា ( បី ) ប្រភេទ ៖

- អ្នកតំណាងតាមច្បាប់សារធាតុ
- អ្នកតំណាងពិសេស
- អ្នកតំណាងដោយអាណត្តិ

រីឯលក្ខណៈសម្បត្តិរបស់អ្នកតំណាងតាមផ្លូវបណ្ដឹង គឺជាអ្នកដែលអាចធ្វើសកម្មភាពបណ្ដឹង ឬបាន ទទួលនូវសកម្មភាពបណ្ដឹងរបស់តុលាការ ឬភាគីម្ខាងទៀតដោយបានផ្អែកលើឆន្ទៈរបស់ខ្លួនក្នុងនាមជាភាគី ឬ ជំនួសភាគី ហើយអានុភាពនៃការធ្វើសកម្មភាពបណ្ដឹង ឬទទួលនូវសកម្មភាពបណ្ដឹងនោះនឹងមានទៅលើភាគី។ អានុភាពនៃសកម្មភាពរបស់អ្នកតំណាងមានទៅលើសាមីខ្លួន ដោយសារតែអ្នកតំណាងមានសិទ្ធិតំណាង។ ចំពោះអ្នកតំណាងតាមផ្លូវបណ្ដឹង មានអ្នកតំណាងតាមច្បាប់សារធាតុ អ្នកតំណាងពិសេស និងអ្នកតំណាង ដោយអាណត្តិ។ ច្បាប់សារធាតុទទួលស្គាល់ថា បុគ្គលគឺជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច។ ដូច្នេះហើយទើប បែងចែងអំពីលក្ខណៈសម្បត្តិរបស់ អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកតំណាងពិសេស និងអ្នកតំណាង ដោយអាណត្តិ។

### ៣.១.១ អ្នកតំណាងតាមច្បាប់សារធាតុ

អ្នកតំណាងតាមច្បាប់សារធាតុ គឺជាអ្នកតំណាងដែលមិនត្រូវបានជ្រើសតាំងផ្អែកតាមឆន្ទៈរបស់ភាគី នោះទេ គឺជាការកំណត់របស់ច្បាប់សារធាតុ ដោយសារស្ថានភាពរបស់បុគ្គលនោះ ( ជនដែលត្រូវបានកម្រិត សមត្ថភាព )។ អ្នកតំណាងតាមច្បាប់សារធាតុ គឺជាអ្នកតំណាងចំពោះជនដែលត្រូវបានកម្រិតសមត្ថភាព ហេតុ នេះបើអនីតិជនត្រូវធ្វើសកម្មភាពតាមផ្លូវតុលាការ អ្នកតំណាងអនីតិជន គឺជាអ្នកមានអំណាចមេបា ឬអ្នកអាណា ព្យាបាលសម្រាប់អនីតិជន។

បើជននៅក្រោមអាណាព្យាបាលទូទៅត្រូវធ្វើសកម្មភាពតាមផ្លូវតុលាការ អ្នកតំណាងរបស់ជននៅក្រោម អាណាព្យាបាល គឺអ្នកអាណាព្យាបាលទូទៅ។

ចំពោះជននៅក្រោមហិតូបត្ថម្ភ អាចធ្វើសកម្មភាពបណ្ដឹងបានដោយខ្លួនឯង លើកលែងតែសកម្មភាព មួយចំនួនដែលតម្រូវឱ្យមានការយល់ព្រមពីហិតូបត្ថម្ភកៈ ឬស្ថានភាពជាក់លាក់មួយចំនួនទៀតដែលតម្រូវឱ្យ មានការប្រគល់សិទ្ធិពិសេស ហេតុនេះហើយហិតូបត្ថម្ភកៈមិនមែនជាអ្នកតំណាងតាមច្បាប់សារធាតុចំពោះជន នៅក្រោមហិតូបត្ថម្ភនោះទេ។

### ៣.១.២ លក្ខណៈសម្បត្តិរបស់អ្នកតំណាងតាមច្បាប់សារធាតុ

ការកំណត់ថា អ្នកមានអំណាចមេបាជាអាទិ៍ ជាអ្នកតំណាងតាមច្បាប់សារធាតុសម្រាប់អនីតិជននៅ ចំពោះមុខតុលាការដោយអាចដើរតួនាទី ឬធ្វើសកម្មភាពបណ្ដឹងជំនួសអនីតិជនដែលជាភាគី គឺជាការកំណត់ នៅក្នុងច្បាប់សារធាតុ ដូចករណីអនីតិជនដែលមានកំណត់នៅក្នុងមាត្រា ១០៥៣ នៃក្រមរដ្ឋប្បវេណី ឬករណី

ជននៅក្រោមអាណាព្យាបាលទូទៅ មានកំណត់នៅក្នុងមាត្រា ១១១៤ នៃក្រមរដ្ឋប្បវេណី។ ដោយឡែក ចំពោះហិតូបត្ថម្ភកៈ នៅក្នុងច្បាប់សារធាតុមិនមានកំណត់ ឬទទួលស្គាល់នោះទេ។

ឧទាហរណ៍ ៖ អ្នកមានអំណាចមេបាជាអាទិ៍ ជាអ្នកតំណាងតាមច្បាប់សារធាតុចំពោះភាគីជាអនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ជាអ្នកតំណាងតាមច្បាប់សារធាតុ ចំពោះជននៅក្រោមអាណាព្យាបាលទូទៅ។

## ៣.២ អ្នកតំណាងពិសេស

អ្នកតំណាងពិសេស ជាអ្នកតំណាងជំនួសឱ្យអ្នកតំណាងតាមច្បាប់កំណត់ដែលបានរៀបរាប់ខាងលើ ក្នុងករណីដែលគ្មានអ្នកតំណាង ឬអ្នកតំណាងមិនអាចប្រតិបត្តិនូវសិទ្ធិតំណាងនោះបាន ដូច្នេះបុគ្គលដែលមានបំណងធ្វើសកម្មភាពបណ្តឹងជំនួសបុគ្គលដែលគ្មានសមត្ថភាពធ្វើបណ្តឹងអាចដាក់ពាក្យស្នើសុំទៅតុលាការដើម្បីក្លាយជាអ្នកតំណាងពិសេស។

តុលាការអាចជ្រើសតាំងព្រះរាជអាជ្ញាជាអ្នកតំណាងពិសេសបាន ដើម្បីធ្វើសកម្មភាពបណ្តឹង ហើយអ្នកតំណាងពិសេសត្រូវចាំបាច់មានការប្រគល់សិទ្ធិជាអ្នកតំណាង។ អ្នកតំណាងពិសេស គឺជាអ្នកតំណាងជំនួសអ្នកតំណាងដែលច្បាប់កំណត់ ដូច្នេះអាចប្រើប្រាស់សិទ្ធិអំណាចដូចអ្នកតំណាងដែលច្បាប់បានកំណត់ដែរ[41]។

នៅប្រទេសជប៉ុន នៅពេលដែលតុលាការជ្រើសរើសអ្នកតំណាងពិសេស តុលាការតែងតែជ្រើសរើសតំណាងអយ្យការ ធ្វើជាអ្នកតំណាងពិសេស [42]។

ឧទាហរណ៍៖ កូនជាអនីតិជនដាក់ពាក្យបណ្តឹងបដិសេធបិតុភាព ប៉ុន្តែគ្មានអ្នកអនុវត្តអំណាចមេបា ហេតុនេះត្រូវជ្រើសតាំងអ្នកតំណាងពិសេស។

មួយវិញទៀត ជាគោលការណ៍ ភាគីដែលដាក់ពាក្យសុំឱ្យថែរក្សាការពារភស្តុតាងត្រូវកំណត់បុគ្គលដែលជាភាគីម្ខាងទៀត ប៉ុន្តែក្នុងករណីដែលមិនដឹងថានរណាជាភាគីម្ខាងទៀត តុលាការអាចជ្រើសតាំងអ្នកតំណាងពិសេស ធ្វើជាអ្នកតំណាងឱ្យភាគីម្ខាងទៀត[43]។

ឧទាហរណ៍៖ ជនរងគ្រោះជួបគ្រោះថ្នាក់ចរាចរណ៍ បណ្តាលឱ្យស្លាប់គ្រួសារជនរងគ្រោះបានស្នើសុំទៅតុលាការឱ្យធ្វើនីតិវិធីថែរក្សាការពារភស្តុតាងនៅទីតាំងកើតហេតុ ដោយគ្រួសារជនរងគ្រោះមិនស្គាល់ចារី ហេតុ

[41]ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៦។

[42]ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៩១ កថាខណ្ឌទី២។

[43] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៦៦។

នេះ តុលាការនឹងចេញដីកាសម្រេចថែរក្សាការពារភស្តុតាង ហើយភាគីម្ខាងទៀតដែលមិនស្គាល់នោះ ត្រូវជំនួសដោយអ្នកតំណាងពិសេស។

### ៣.២.១ លក្ខណៈសម្បត្តិនៃអ្នកតំណាងពិសេស

អ្នកតំណាងពិសេស ប្រសិនបើក្នុងករណីគ្មានអ្នកតំណាងតាមច្បាប់សារធាតុ ឬអ្នកតំណាងតាមច្បាប់សារធាតុមិនអាចអនុវត្តសិទ្ធិតំណាងបាន បុគ្គលដែលមានបំណងធ្វើសកម្មភាពបណ្តឹងចំពោះបុគ្គលដែលគ្មានសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹងអាចដាក់ពាក្យសុំទៅតុលាការដែលទទួលបណ្តឹងឱ្យជ្រើសតាំងអ្នកតំណាងពិសេស។ អ្នកតំណាងពិសេស គឺជាអ្នកតំណាងជំនួសឱ្យអ្នកតំណាងតាមច្បាប់សារធាតុ ហេតុនេះមានសិទ្ធិដូចអ្នកតំណាងតាមច្បាប់សារធាតុ។

## ៣.៣ អ្នកតំណាងដោយអាណត្តិ

ជាគោលការណ៍ជនដែលអាចក្លាយទៅជាអ្នកតំណាងដោយអាណត្តិមានតែមេធាវីទេ ( គោលការណ៍នៃការតំណាងដោយមេធាវី[44])។ នេះជាការធ្វើឡើងដើម្បីការពារផលប្រយោជន៍ឱ្យសាមីភាគីដែលជាអ្នកបានពឹងពាក់។ ហេតុនេះហើយ ក្នុងករណីដែលជនក្រៅពីមេធាវីបានធ្វើសកម្មភាពបណ្តឹងក្នុងនាមជាអ្នកតំណាងដោយអាណត្តិ ជាគោលការណ៍គឺជាអំពើខុសនឹងច្បាប់ ហើយតុលាការត្រូវបំបាត់ចោលនូវការពាក់ព័ន្ធរបស់អ្នកនោះក្នុងបណ្តឹង។ សកម្មភាពដែលអ្នកនោះបានធ្វើពុំមានសុពលភាពទេ ក៏ប៉ុន្តែប្រសិនបើភាគីណាបានផ្តល់សច្ចានុមតិសកម្មភាពនោះនឹងមានសុពលភាព។

ករណីពិសេសស្តីអំពីករណីដែលអាចជ្រើសតាំងជន ក្រៅពីមេធាវីធ្វើអ្នកតំណាងដោយអាណត្តិ ក្រមនីតិវិធីរដ្ឋប្បវេណីបានទទួលស្គាល់ករណីដូចជា ៖

១. ករណីដែលទទួលស្គាល់ឱ្យតតិយជន ក្រៅពីមេធាវីធ្វើសកម្មភាពបណ្តឹងជំនួសភាគី[45] ។

២. ករណីដែលរដ្ឋ ឬស្ថាប័នរដ្ឋជាអាទិ៍ជាភាគីហើយមានការកំណត់ឱ្យមន្ត្រីស្ថាប័ននោះ ធ្វើជាអ្នកតំណាងស្ថាប័ននោះជាអាទិ៍[46] ។

[44] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣ កថាខណ្ឌទី១។

[45] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣ កថាខណ្ឌទី១ ចំណុចក។

[46] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣ កថាខណ្ឌទី១ ចំណុចខ។

៣. ករណីដែលអនុញ្ញាតឱ្យតតិយជនពិសេសក្រៅពីមេធាវីធ្វើជាអ្នកតំណាងក្នុងរឿងក្ដីដែលទឹកប្រាក់នៃកម្មវត្ថុនៃបណ្ដឹងនោះតិចជាង ១ លានរៀល[47]។ ករណីនេះ គឺជាករណីដែលទឹកប្រាក់សេដ្ឋកិច្ចនៃសិទ្ធិ និងកាតព្វកិច្ចដែលត្រូវកំណត់ដោយបណ្ដឹងនេះមានតិចតួច ដូច្នេះហើយទោះបីជាបុគ្គលនោះមិនមែនជាមេធាវីក៏ដោយ ឱ្យតែមានការទទួលស្គាល់ដោយភាគី និងមានការទុកចិត្តហើយតុលាការយល់ឃើញថាអត់មានបញ្ហាដែរធ្វើជាអ្នកតំណាងដោយអាណត្តិបាន។

### ៣.៣.១ លក្ខណៈសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ

#### ក. លក្ខណៈសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ

ជាគោលការណ៍ បុគ្គលដែលមានលក្ខណៈសម្បត្តិក្លាយជាអ្នកតំណាងដោយអាណត្តិ គឺមេធាវី (អ្នកវិជ្ជាជីវៈដែលមានចំណេះដឹងផ្នែកច្បាប់ ក្នុងការការពារផលប្រយោជន៍ស្របច្បាប់របស់ភាគី )។

ប្រសិនបើជ្រើសតាំងអ្នកតំណាងដោយអាណត្តិ ដែលមិនមែនជាមេធាវី លុះត្រាតែះ

- បុគ្គលនោះត្រូវបានច្បាប់ទទួលស្គាល់ឱ្យធ្វើសកម្មភាពបណ្ដឹងជំនួសភាគី ( ក្រមនីតិវិធីរដ្ឋប្បវេណី ឬច្បាប់ដទៃកំណត់ )
- ភាគីជាស្ថាប័នរដ្ឋ ឬរដ្ឋជាអាទិ៍ អាចចាត់តាំងមន្ត្រីរបស់ខ្លួនជាអ្នកតំណាង
- រឿងក្ដីដែលមានកម្មវត្ថុនៃការទាមទារតិចជាងមួយលានរៀល និងមានការអនុញ្ញាតពីតុលាការ

ឧទាហរណ៍ ៖ បុគ្គលនោះត្រូវបានច្បាប់ទទួលស្គាល់ឱ្យធ្វើសកម្មភាព បណ្ដឹងជំនួសភាគីបានកំណត់ថា នរណាក៏អាចធ្វើជាអ្នកតំណាងដោយអាណត្តិបានដែរមិនកម្រិតតែជាមេធាវីនោះទេ ប៉ុន្តែបើមិនមែនជាមេធាវី អាចធ្វើជាអ្នកតំណាងដោយអាណត្តិក្នុងសំណុំរឿងអនុវត្តដោយបង្ខំបានលុះត្រាតែទទួលបានការអនុញ្ញាតពីតុលាការ។

ឧទាហរណ៍ ៖ ភាគីជាស្ថាប័នរដ្ឋ ឬរដ្ឋជាអាទិ៍ អាចចាត់តាំងមន្ត្រីរបស់ខ្លួនធ្វើជាអ្នកតំណាង។ ក្នុងករណីដែលស្ថាប័នរដ្ឋ ជាក្រសួងកិច្ចការនារីជាអាទិ៍ ប្ដឹងទាមទារសំណងពី ក ជាអាទិ៍ ទៅតុលាការ។ ករណីនេះ រដ្ឋមន្ត្រីក្រសួង កិច្ចការនារី អាចចាត់តាំងមន្ត្រីក្រសួង ឱ្យធ្វើជាអ្នកតំណាងឱ្យក្រសួងបាន។

[47] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣ កថាខណ្ឌទី១ និងកថាខណ្ឌទី៣។

ឧទាហរណ៍ ៖ រឿងក្តីដែលមានកម្មវត្ថុនៃការទាមទារតិចជាងមួយលានរៀល និងមានការអនុញ្ញាតពីតុលាការ នរណាក៏អាចធ្វើជាអ្នកតំណាងដោយអាណត្តិបានដែរ មិនមែនកម្រិតតែជាមេធាវីនោះទេ ប៉ុន្តែបើមិនមែនជាមេធាវី តុលាការអាចលុបចោលការអនុញ្ញាតពេលណាក៏បាន។

**ខ. ការប្រគល់សិទ្ធិតំណាងដោយអាណត្តិ**

ដើម្បីធ្វើសកម្មភាពតាមផ្លូវបណ្តឹង អ្នកតំណាងដោយអាណត្តិត្រូវមានលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ជាលាយលក្ខណ៍អក្សរ[48]។

**គ. ឋានៈរបស់អ្នកតំណាងដោយអាណត្តិ**

សកម្មភាពដែលធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ និងបង្កើតអានុភាពតាមផ្លូវច្បាប់ចំពោះភាគី ប៉ុន្តែអ្នកតំណាងដោយអាណត្តិ មិនមែនជាភាគីនោះទេ ហេតុនេះមិនទទួលអានុភាពនៃសេចក្តីសម្រេច ( ដីកាសម្រេច សាលក្រម ឬសាលដីកា ) របស់តុលាការឡើយ[49]។

ទោះបីជា ភាគីបានជ្រើសតាំងអ្នកតំណាងដោយអាណត្តិក៏ដោយ ភាគីក៏អាចចូលរួមក្នុងសកម្មភាពបណ្តឹងបានផងដែរ ហើយការអះអាងរបស់ភាគីមានអានុភាពជាងអ្នកតំណាងដោយអាណត្តិ និងអាចស្នើសុំកែតម្រូវ ឬលុបចោលនូវការអះអាងរបស់អ្នកតំណាងដោយអាណត្តិបាន។

**ឃ. សិទ្ធិរបស់អ្នកតំណាងដោយអាណត្តិ**

តំណាងដោយអាណត្តិអាចធ្វើសកម្មភាពបណ្តឹងដូចជា ដាក់ពាក្យបណ្តឹង ឆ្លើយដោះសារចំពោះពាក្យបណ្តឹង ធ្វើបណ្តឹងតប ប្តឹងឧទ្ធរណ៍ ប្តឹងទាស់ ប្តឹងតវ៉ា ប្តឹងជំទាស់ ឬចាត់តាំងអនុតំណាងជាមេធាវី ជាអាទិ៍។

បើអ្នកតំណាងដោយអាណត្តិជាមេធាវី ភាគីមិនអាចកម្រិតនូវសិទ្ធិតំណាងដោយអាណត្តិបានឡើយ លើកលែងតែសកម្មភាពមួយចំនួនដូចជា ការដកពាក្យបណ្តឹង ការលះបង់ការទាមទារ ការទទួលស្គាល់ការទាមទារ ឬការផ្សះផ្សា ប៉ុន្តែប្រសិនបើមានការព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរអំពីសិទ្ធិរបស់អ្នកតំណាង គឺអនុវត្តតាមការព្រមព្រៀងនោះ[50]។

[48] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៥ កថាខណ្ឌទី៣។

[49] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣ កថាខណ្ឌទី៣ និងទី២។

[50] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤ កថាខណ្ឌទី៣។

បើអ្នកតំណាងដោយអាណត្តិមិនមែនជាមេធាវី សិទ្ធិតំណាងនោះមានត្រឹមកម្រិតនៃសិទ្ធិដែលបានព្រមព្រៀងជាលាយលក្ខណ៍អក្សរ[51]។

**ខ. ការរលត់សិទ្ធិតំណាងដោយអាណត្តិ**

- មរណភាពរបស់អ្នកតំណាងដោយអាណត្តិ
- ការបាត់បង់លក្ខណសម្បត្តិជាអ្នកតំណាងដោយអាណត្តិ (ឧ. មេធាវីរូបនោះត្រូវបានហាមឃាត់ក្នុងការប្រកបវិជ្ជាជីវៈ ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីនៃគណៈមេធាវីជាអាទិ៍)
- ការបញ្ចប់កិច្ចការអាណត្តិ ( ឧ. ការប្រគល់សិទ្ធិតំណាងដោយអាណត្តិរវាងដើមចោទ និងមេធាវី គឺត្រឹមកម្រិតនៃបណ្តឹងអង្គសេចក្តីនៅដំណាក់កាលសាលាដំបូង ហេតុនេះហើយនៅពេលដែលបញ្ចប់នីតិវិធីនៅសាលាដំបូង ឮនាំឱ្យសិទ្ធិតំណាងត្រូវរលត់ )
- ភាគីដកសិទ្ធិតំណាងដោយអាណត្តិ
- អ្នកតំណាងដោយអាណត្តិលាឈប់ធ្វើជាអ្នកតំណាង។

**ច. ការចាត់ចែងក្នុងករណីខ្វះសិទ្ធិតំណាងដោយអាណត្តិ**

ករណីមានការសង្ស័យអំពីកង្វះសិទ្ធិតំណាង តុលាការអាចស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ឬតាមពាក្យសុំរបស់បុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ទោះស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ។

បើខ្វះសិទ្ធិតំណាង តុលាការត្រូវណែនាំឱ្យកែតម្រូវ ឬអ្នកមានសិទ្ធិអាចផ្តល់សច្ចានុមតិក្នុងអំឡុងពេលដែលតុលាការកំណត់។ បើអ្នកមានសិទ្ធិបានផ្តល់សច្ចានុមតិ ចាត់ទុកថាសកម្មភាពដែលគ្មានសិទ្ធិ នឹងក្លាយជាមានសិទ្ធិដោយមានអានុភាពប្រតិសកម្ម[52] ។

ក្នុងករណីបណ្តឹងត្រូវបានធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិដែលគ្មានសិទ្ធិ សកម្មភាពបណ្តឹងនោះ ត្រូវចាត់ទុកជាមោឃៈ ហើយតុលាការត្រូវ លើកបណ្តឹងនោះចោលដោយសាលក្រម ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ដោយមូលហេតុថាបណ្តឹងនោះផ្ទុយច្បាប់ ហើយមិនអាចកែតម្រូវបាន[53]។

[51] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣ កថាខណ្ឌទី២។
[52] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៧។
[53] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៨១។

ក៏ប៉ុន្តែបើតុលាការបានចេញសាលក្រមរួចហើយ បុគ្គលដែលមានផលប្រយោជន៍ ក្នុងការលើកឡើងអំពីកង្វះសិទ្ធិតំណាង អាចទាមទារឱ្យលុបចោលសាលក្រម ឬសាលដីកានោះ តាមរយៈបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខជាអាទិ៍[54] ។

បើសាលក្រម ឬសាលដីកានោះបានចូលជាស្ថាពរ អាចទាមទារឱ្យលុបចោល តាមរយៈបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី[55]។

## ៣.៤ ផលវិបាកនៃវិធានបញ្ញត្តិស្តីពីអ្នកតំណាង

បទប្បញ្ញត្តិស្តីពីអ្នកតំណាង រួមទាំងសិទ្ធិអំណាចរបស់អ្នកតំណាងក្នុងការធ្វើសកម្មភាពបណ្តឹង នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីបានលុបបំបាត់ទាំងស្រុងនូវទស្សនៈ ដែលមានការភន្តច្រឡំ និងមិនមានភាពច្បាស់លាស់ដោយបញ្ញត្តិច្បាប់ជាធរមាន និងការអនុវត្តនាពេលបច្ចុប្បន្ន។ ភាពមិនច្បាស់លាស់នោះរួមមានទស្សនៈ អំពីអ្នកតំណាង ដែលច្បាប់បានកំណត់ និងអ្នកតំណាងដោយអាណត្តិ ឋានៈរបស់អ្នកតំណាង អានុភាពនៃសកម្មភាពរបស់អ្នកតំណាងទំហំនៃសិទ្ធិអំណាចរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកតំណាងដោយអាណត្តិរួមទាំងបាតុភូតអកម្មមួយចំនួនដែលកើតមានឡើង ហើយធ្វើឱ្យខូចខាតធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់ភាគីដែលត្រូវបានគេ តំណាង ឬបានប្រគល់សិទ្ធិតំណាង ។

នៅក្នុងការអនុវត្តជាក់ស្តែងបានបង្ហាញឱ្យឃើញថា មានការភ័ន្តច្រឡំគ្នា និងមិនបានចែកឱ្យច្បាស់លាស់អំពីភាគី និងអ្នកតំណាងដោយច្បាប់កំណត់ដោយហេតុថា នៅក្នុងសកម្មភាពនៃបណ្តឹងដែលភាគីជាអនីតិជន ឬជាជននៅក្រោមអាណាព្យាបាល ( ដែលមិនបានសរសេរបញ្ជាក់ច្បាស់លាស់នៅក្នុងបណ្តឹង និងក្នុងសេចក្តីសម្រេចរបស់តុលាការ ) នោះអ្នកតំណាងដែលច្បាប់បានកំណត់អាចធ្វើសកម្មភាពដូចជាភាគី។ ប៉ុន្តែគេពុំបានគិតដល់អានុភាពនៃសាលក្រម ឬសាលដីកាស្ថាពរ ដែលពុំមានទៅលើអ្នកតំណាងដែលច្បាប់បានកំណត់ ដែលបានធ្វើសកម្មភាពបណ្តឹងឡើយ។

ដោយឡែកបាតុភូតអសកម្មមួយចំនួនបានកើតមាន ដោយសារសកម្មភាពរបស់អ្នកតំណាងដោយអាណត្តិ បានប្រព្រឹត្តហួសពីព្រំដែននៃសិទ្ធិនៃអ្នកតំណាងដោយអាណត្តិ ហើយតែងតែបង្កឱ្យមានការខូចខាតដល់ប្រយោជន៍របស់ភាគី ដូចជាការដកពាក្យបណ្តឹង ការផ្សះផ្សាសះជា ការទទួលស្គាល់ការទាមទារជាដើម ដោយពុំមានការយល់ ព្រមពីភាគីដែលប្រគល់សិទ្ធិមកឱ្យខ្លួននោះទេ។

---

[54]ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៧៩ កថាខណ្ឌទី១ ចំណុចខ និងមាត្រា២៨១ កថាខណ្ឌទី១ ចំណុចឃ។

[55] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣០៧ កថាខណ្ឌទី១ ចំណុចគ។

មួយវិញទៀត ការកំណត់អំពីលក្ខណៈសម្បត្តិរបស់អ្នកតំណាងដោយអាណត្តិ ដោយផ្អែកលើមុខងារជាមេធាវី មកធ្វើជាមូលដ្ឋាននឹងបានផ្តល់នូវផលប្រយោជន៍យ៉ាងសំខាន់សម្រាប់ធានាដល់សិទ្ធិរបស់បុគ្គលឯនជន ( ភាគី ) និងជួយសម្រួលដល់ការអនុវត្តគោលការណ៍ដោះស្រាយរឿងក្តីដោយយុត្តិធម៌ និងឆាប់រហ័ស។

ទោះបីយ៉ាងនេះក្តី ក៏បញ្ហាដែលជាឧបសគ្គនឹងអាចកើតមានឡើងខ្លះ ដោយស្ថានភាព បរិមាណ និងកន្លែង តាំងនៅរបស់មេធាវីអាចមិនទាន់ឆ្លើយតបបាននឹងតម្រូវការនៃច្បាប់នោះ។ ប៉ុន្តែស្ថានភាពនេះនឹងត្រូវជំនះបាននាពេលអនាគតដ៏ខ្លីដោយសារបរិមាណមេធាវីត្រូវបានបង្កើនជារៀងរាល់ឆ្នាំ។

## ៣.៥ ទំនាក់ទំនងអ្នកតំណាងតាមផ្លូវបណ្តឹង និងភាគី

ទំនាក់ទំនងអ្នកតំណាងតាមផ្លូវបណ្តឹង គឺជាសកម្មភាពដែលច្បាប់បានផ្តល់ទៅឱ្យរូបវន្តបុគ្គលណាម្នាក់មានសិទ្ធិនៅក្នុងការធ្វើសកម្មភាពបណ្តឹងជំនួសជនទាំងឡាយណាដែលមានវិវាទ។ នៅក្នុងផ្នែកនេះដែរយើងនិងធ្វើការបកស្រាយ ទាក់ទងទៅនឹងទំនាក់ទំនងភាគី និងអ្នកតំណាងដោយអាណត្តិ និងផ្តោតទៅលើការធ្វើសកម្មភាពបណ្តឹងជំនួសភាគី។

### ៣.៥.១ ទំនាក់ទំនងភាគី និងអ្នកតំណាងដោយអាណត្តិ

ជាគោលការណ៍នៅក្នុងរឿងក្តីរដ្ឋប្បវេណី ជនដែលអាចក្លាយទៅជាអ្នកតំណាងដោយអាណត្តិ គឺមានតែមេធាវីតែប៉ុណ្ណោះ[56]។ ការកំណត់នេះ ធ្វើឡើងដើម្បីការពារផលប្រយោជន៍ដល់ភាគី។ នៅក្នុងនោះ ភាគីណាដែលត្រូវការសេវាមេធាវី ឬអ្នកច្បាប់ដើម្បីពិភាក្សា និងផ្តល់យោបល់ដល់ខ្លួន ភាគីអាចជ្រើសរើសអ្នកតំណាងដោយឆន្ទៈរបស់ខ្លួនឯងបាន។ ក្នុងនោះយើងអាចឃើញថា ទំនាក់ទំនងមេធាវី និងភាគី ជាទំនាក់ទំនងតាមកិច្ចសន្យាអាណត្តិ ( ត្រូវបានប្រើប្រាស់ក្នុងទម្រង់ជាលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ )។ បញ្ជាក់ឱ្យឃើញថា កិច្ចសន្យានេះមានប្រភពពីទំនៀមទម្លាប់ និងការព្រមព្រៀងគ្នាទៅវិញទៅមក[57] ។

បន្ថែមពីនេះទៅទៀត ក្រៅពីករណីខាងលើក៏មានករណីពិសេសមួយទៀតដែរ គឺគេអាចជ្រើសតាំងជនដែលមិនមែនជាមេធាវី ធ្វើជាអ្នកតំណាងដោយអាណត្តិបាន។ ដោយផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណី បានទទួលស្គាល់ករណី ចំនួន ៣ គឺជាករណីដែលទទួលស្គាល់ឱ្យតតិយជនក្រៅពីមេធាវី ធ្វើសកម្មភាពបណ្តឹងជំនួសភាគីដោយបានយោងតាមច្បាប់[58], ករណីរដ្ឋ ឬស្ថាប័នរដ្ឋ ហើយមានការកំណត់ឱ្យមន្ត្រីស្ថាប័ននោះធ្វើជាអ្នកតំណាង

[56] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣ កថាខណ្ឌទី១។
[57] ក្រមសីលធម៌នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២ មាត្រា១៨។
[58] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣ កថាខណ្ឌទី១ ចំណុច ក។

ស្ថាប័ននោះ ជាអាទិ៍[59] ឧទាហរណ៍៖ ករណីស្ថាប័នរដ្ឋជាក្រសួងរ៉ែ និងថាមពល ជាអាទិ៍ ប្ដឹងទាមទារសំណងពីលោក ក ទៅតុលាការ។ ក្នុងករណីនេះ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពលអាចចាត់តាំងមន្ត្រីក្រសួង ធ្វើជាអ្នកតំណាងឱ្យក្រសួងបាន។ ករណីចុងក្រោយដែលអនុញ្ញាតឱ្យតតិយជន ពិសេសក្រៅពីមេធាវីធ្វើជាអ្នកតំណាងក្នុងរឿងក្ដីដែលទឹកប្រាក់នៃកម្មវត្ថុនៃបណ្ដឹងនោះតិចជាង ១ លានរៀល[60] ក្នុងន័យនេះគេចង់សំដៅទៅលើទឹកប្រាក់សេដ្ឋកិច្ចនៃសិទ្ធិ និងកាតព្វកិច្ចដែលត្រូវកំណត់ដោយបណ្ដឹងនេះមានតិចតួច ដូច្នេះទោះជាមិនមែនជាមេធាវីក៏ដោយក៏គេទទួលស្គាល់ឱ្យជនដែលភាគីមានការទុកចិត្ត ហើយតុលាការយល់ឃើញថាអត់មានបញ្ហាដែរនោះ គឺគាត់អាចធ្វើអ្នកតំណាងដោយអាណត្តិបាន។ ក៏ប៉ុន្តែ ប្រសិនបើអ្នកតំណាងដែលមិនមែនជាមេធាវីមានសមត្ថភាពក្នុងការធ្វើបណ្ដឹងជំនួសភាគីក៏ពិតមែនតែគាត់មិនមានសមត្ថភាពផ្នែកច្បាប់នោះទេ តុលាការយល់ឃើញថាមិនចាំបាច់ឱ្យមានអ្នកតំណាង ដូច្នេះតុលាការអាចលុបចោលការអនុញ្ញាតឱ្យមានអ្នកតំណាងនេះបាន[61] ។

ដោយឡែកក្នុងបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល សកម្មភាពទាក់នឹងឋានៈបុគ្គលមិនត្រូវធ្វើឡើងដោយអ្នកតំណាងនោះទេ គឺធ្វើឡើងដោយផ្អែកតាមឆន្ទៈរបស់សាមីខ្លួន ហេតុដូចនេះហើយអនីតិជន និងជននៅក្រោមអាណាព្យាបាលទូទៅមានសមត្ថភាពក្នុងការធ្វើបណ្ដឹង[62]។ គួរបញ្ជាក់ថាការធ្វើសកម្មភាព បណ្ដឹងនេះដោយជនដែលកម្រិតសមត្ថភាព អាចបណ្ដាលឱ្យខូចផលប្រយោជន៍របស់ខ្លួនបាន អាស្រ័យហេតុនេះហើយតុលាការអាចជ្រើសតាំងមេធាវីឱ្យជនដែលត្រូវបានកម្រិតសមត្ថភាពនោះបាន[63]។

### ៣.៥.២ ការធ្វើសកម្មភាពភាគីនៅក្នុងបណ្ដឹងជំនួសភាគី

ផ្អែកទៅតាមគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិ ស្ដីពីតួនាទីរបស់មេធាវីនៅកម្ពុជាមានតួនាទីយ៉ាងសំខាន់ក្នុងការធានានីតិរដ្ឋ និងការពារសិទ្ធិរបស់ប្រជាពលរដ្ឋ[64]។ ដូច្នេះហើយទើបមេធាវីជាវិជ្ជាជីវៈសេរី គ្មានការរឹតត្បិត ឬជ្រៀតជ្រែកណាមួយឡើយ។

ម៉្យាងវិញទៀតមេធាវីគឺជាអ្នកតំណាងដោយអាណត្តិឱ្យភាគី អាស្រ័យហេតុនេះហើយមេធាវីត្រូវប្រើចំណេះ ជំនាញរបស់ខ្លួន ដើម្បីការពារសិទ្ធិរបស់កូនក្ដីរបស់ខ្លួន។ តាមរយៈការផ្ដល់សេវាផ្នែកច្បាប់នេះផងដែរ

---

[59] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣ កថាខណ្ឌទី១ ចំណុច ខ។

[60] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣ កថាខណ្ឌទី១ ចំណុច គ។

[61] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣ កថាខណ្ឌទី៣។

[62] ច្បាប់ស្ដីពីនីតិវិធីនៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា៧ កថាខណ្ឌទី១។

[63] ច្បាប់ស្ដីពីនីតិវិធីនៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា៧ កថាខណ្ឌទី២។

[64] UN, (1990). Basic Principle on the Role of Lawyer.

អ្នកតំណាងដោយអាណត្តិ ស្វែងរកអង្គច្បាប់ឱ្យមានភាពស៊ីចង្វាក់ជាមួយនឹងអង្គហេតុដើម្បីពន្យល់ ផ្តល់ដំបូន្មានផ្សេងៗទៅដល់កូនក្តីរបស់ខ្លួនអំពីអត្ថិភា និងនត្ថិភាពនៃសិទ្ធិ។ លើសពីនេះទៅទៀតអ្នកតំណាងដោយអាណត្តិអាចធ្វើបាននូវរាល់សកម្មភាព ដែលចាំបាច់នៅក្នុងការបន្តនីតិវិធីមានដូចជា ការសសេរពាក្យបណ្តឹង ការដាក់ពាក្យបណ្តឹង ការធ្វើសេចក្តីថ្លែងការណ៍ឆ្លើយដោះសារចំពោះបណ្តឹង ការប្តឹងតប ការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ បង្ហាញភស្តុតាងដែលខ្លួនបានគិតថាមានប្រយោជន៍ដល់ភាគីដែលខ្លួនបានតំណាងចំពោះមុខតុលាការ ដើម្បីឱ្យតុលាការពិចារណា និងបំពេញកិច្ចនីមួយៗដែលតុលាការបានបង្គាប់ឱ្យធ្វើ។ ក្រមនេះអ្នកតំណាងដោយអាណត្តិមានសិទ្ធិចាត់ចែងរឿងក្តីបានដោយសេរី ( តាមរយៈលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ) ដោយពុំបានចាំបាច់មានវត្តមានកូនក្តីរបស់ខ្លួនឡើយ លើកលែងតែរឿងក្តីលែងលះ ឬបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ព្រោះថារឿងក្តីប្រភេទនេះមានការទាក់ទងទៅនឹងអារម្មណ៍ មនោសញ្ចេតនារបស់ភាគី ដែលមិនមានតតិយជនណាអាចតំណាង ឬជំនួសបានឡើយ តែអ្នកតំណាងអាចនៅអមជាមួយនឹងភាគីបាន។

ចំពោះជនដែលកម្រិតសមត្ថភាពវិញ តុលាការអាចជ្រើសតាំងមេធាវីធ្វើជាអ្នកតំណាងឱ្យជនដែលកម្រិតសមត្ថភាពនោះបាន[65]ទោះមានពាក្យសុំ ឬមិនមានពាក្យសុំ ក៏តុលាការអាចបង្គាប់ឱ្យជនដែលកម្រិតសមត្ថភាពជ្រើសតាំងមេធាវីជាអ្នកតំណាង ឬអាចជ្រើសតាំងមេធាវីធ្វើជាអ្នកតំណាងតាមឆន្ទានុសិទ្ធិបាន[66]។ សកម្មភាពគតិយុត្តនេះដែរមិនមែនមានន័យថាចំបាច់ត្រូវតែធ្វើឡើងដោយខ្លួនឯងផ្ទាល់ទើបមានអានុភាពនោះទេ ជាងនេះទៅទៀតច្បាប់ក៏មានការទទួលស្គាល់ផងដែរថា បុគ្គលម្នាក់អាចសុំស្នើឱ្យតតិយជនធ្វើសកម្មភាពគតិយុត្តជំនួសម្ចាស់សិទ្ធិបាន។

[65] ច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ២៦ មេសា ២០១០, មាត្រា៧ កថាខណ្ឌទី២។

[66] ច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ២៦ មេសា ២០១០, មាត្រា៧ កថាខណ្ឌទី៣។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីរួមមក ភាគី គឺជាប្រធាននៃបណ្តឹងរដ្ឋប្បវេណី និងជាជនដែលបានទាមទារនូវសាលក្រម ឬសាលដីកាក្នុងនាមរបស់ខ្លួន ដើម្បីដោះស្រាយវិវាទព្រមទាំងជនដែលត្រូវបានទាមទារឱ្យចង្អុលឈ្មោះនៅក្នុង សាលក្រម ឬសាលដីកានោះក្នុងនាមជាភាគីម្ខាងទៀត។ ភាគី នៅក្នុងរឿងក្តីរដ្ឋប្បវេណី គឺជារូបវន្តបុគ្គល និង នីតិបុគ្គលដែលមានសមត្ថភាពភាគី ហើយសមត្ថភាពភាគី គឺជាលក្ខណៈសម្បត្តិទូទៅដែលទទួលស្គាល់ដោយ ច្បាប់សារធាតុរួមមានក្រមរដ្ឋប្បវេណី និងច្បាប់ឯកជនផ្សេងទៀត។  បុគ្គលដែលមានសមត្ថភាពធ្វើសកម្មភាព ដោយខ្លួនឯងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងច្បាប់ផ្សេងទៀតអាចដាក់ពាក្យបណ្តឹងដោយខ្លួនឯងដោយតាំង ខ្លួនជាដើមចោទ ឬអាចឆ្លើយដោះសារចំពោះបណ្តឹង ដោយតាំងខ្លួនជាចុងចម្លើយ ឬអាចធ្វើសកម្មភាពបណ្តឹង ផ្សេងទៀតដែលជាចាំបាច់។ ដោយឡែកជនដែលត្រូវបានច្បាប់កម្រិតសមត្ថភាពក្នុងការធ្វើបណ្តឹងខ្លះមានដូច ជា អនីតិជន និងជននៅក្រោមអាណាព្យាបាលទូទៅអាចធ្វើសកម្មភាពបណ្តឹងសុពលបាន លុះត្រាតែត្រូវបាន ធ្វើដោយអ្នកតំណាងដែលច្បាប់បានកំណត់លើកលែង ករណីដែលអនីតិជនអាចធ្វើសកម្មភាពដោយឯករាជ្យ។ ក្នុងនោះអ្នកតំណាងអាចធ្វើសកម្មភាពជាច្រើនជំនួសឱ្យភាគី ក្នុងករណីចាំបាច់នៅក្នុងការបន្តនីតិវិធីបណ្តឹង ឬ បំពេញកិច្ចការដែលតុលាការបានកំណត់ ជាអាទិ៍។ ចំពោះអ្នកតំណាងដោយអាណត្តិ ភាគីអាចជ្រើសរើសបាន តាមឆន្ទៈរបស់ខ្លួន។ ថ្វីត្បិតតែ ជ្រើសតាំងដោយឆន្ទៈខ្លួនក៏ពិតមែន ភាគីអាចបញ្ឈប់សិទ្ធិតំណាងរបស់អ្នក តំណាងដោយអាណត្តិនៅពេលណាក៏បាន ចំណែកឯអ្នកតំណាងដោយអាណត្តិក៏មានសិទ្ធិឈប់តំណាង នូវ រឿងក្តីដែលខ្លួនបានទទួលនៅពេលណាក៏បានដូចគ្នា។ ផ្ទុយទៅវិញ នូវក្នុងករណីដែលជនត្រូវបានគេកម្រិត សមត្ថភាពចង់ធ្វើសកម្មភាពបណ្តឹង ក៏អាចធ្វើបានដូចទៅនឹងជនទូទៅផងដែរ គ្រាន់តែជនត្រូវបានកម្រិតសមត្ថ ភាពមិនអាចធ្វើសកម្មភាពបណ្តឹងបានដោយឯករាជ្យ ដូច្នេះហើយជននោះត្រូវការអ្នកតំណាងតាមច្បាប់កំណត់ ដើម្បីការពារផលប្រយោជន៍ដល់ជនដែលត្រូវបានកម្រិតសមត្ថភាព ជៀងវាងខូចប្រយោជន៍ ឬក៏ខាតបង់ដោយ ប្រការណាមួយជាដើម។

ឆ្លងតាមការបកស្រាយខាងលើនេះមកយើងខ្ញុំបានឃើញថា ភាគីក្នុងរឿងក្តីរដ្ឋប្បវេណី គឺជាតួអង្គដ៏ សំខាន់ ក្នុងកិច្ចដំណើរការនីតិវិធីរដ្ឋប្បវេណី ពិសេសគឺជាជនដែលត្រូវទទួលសិទ្ធិ ឬត្រូវបានបំពេញកាតព្វកិច្ច ក្នុងសាលក្រម ឬសាលដីកាដែលតុលាការសម្រេចតាមបញ្ញត្តិនៃច្បាប់ ហេតុនេះការកំណត់ពីសមភាពភាគី ឬ យល់ដឹងពីភាគីក្នុងរឿងក្តីរដ្ឋប្បវេណី គឺជាការចាំបាច់បំផុតក្នុងនាមជាអ្នកប្រកបវិជ្ជាជីវៈច្បាប់ ពិសេសជានិស្សិត ផ្នែកនីតិសាស្ត្រសម្រាប់ជាប្រយោជន៍ក្នុងការអនុវត្ត និងស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងបានចងក្រងនូវអត្ថបទសារណានេះរួចមក ធ្វើឱ្យយើងខ្ញុំមានការយល់ដឹងបន្ថែមកាន់តែច្រើនអំពី ភាគីនៅក្នុងបណ្ដឹងរដ្ឋប្បវេណី និងអ្នកតំណាងតាមផ្លូវបណ្ដឹង ដែលបានចែងតាមច្បាប់ព្រះរាជាណាចក្រកម្ពុជា ដែលជារឿយៗយើងតែងតែបានឃើញនៅក្នុងសង្គម និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ហើយដែលសុទ្ធសឹងមានទំនាក់ទំនងទៅនឹងរឿងក្ដីរដ្ឋប្បវេណី និងក្នុងកិច្ចដំណើរការនីតិវិធីរដ្ឋប្បវេណី។

យើងបានដឹងរួចមកហើយថាភាគី មានសកម្មភាពយ៉ាងសកម្ម និងចម្បងបំផុតនៅក្នុងការធ្វើបណ្ដឹង ឬរងបណ្ដឹងនៅចំពោះមុខតុលាការរដ្ឋប្បវេណី ហើយបុគ្គលទាំងឡាយដែលអាចមានលក្ខណៈសម្បត្តិជាភាគីទៅបានលុះត្រាតែមានសិទ្ធិ និងករណីយកិច្ចតាមច្បាប់សារធាតុ ការកំណត់អំពីភាគីនៃបណ្ដឹង មានភាពចាំបាច់ពីព្រោះភាគីនៃបណ្ដឹង គឺជាបុគ្គលដែលប្ដឹងគេ ឬត្រូវបានគេប្ដឹង ហើយដើម្បីឱ្យបណ្ដឹងមានអានុភាពចងភាគីយើងត្រូវគិតអំពីសមត្ថភាពភាគីជាមុនសិន។ ច្បាប់ទទួលស្គាល់ថា មានតែបុគ្គលដែលមានលក្ខណៈសម្បត្តិដែលអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចប៉ុណ្ណោះទេដែលមានសមត្ថភាពជាភាគីនៃបណ្ដឹង។ បុគ្គលដែលមានលក្ខណៈសម្បត្តិជាភាគី រាប់បញ្ចូលទាំងអនីតិជន និងជននៅក្រោមអាណាព្យាបាលទូទៅ ជាអាទិ៍ ប៉ុន្តែជនទាំងនោះមិនអាចធ្វើសកម្មភាពបណ្ដឹងតាមផ្លូវតុលាការនោះទេ គឺត្រូវទាមទារឱ្យមានអ្នកតំណាងដែលច្បាប់បានកំណត់ជាអាទិ៍ សម្រាប់ធ្វើសកម្មភាពបណ្ដឹងជំនួស។

ជាការពិតណាស់ ក្នុងនីតិវិធីនេះវាពិតជាមានការស្មុគស្មាញក្នុងការស្វែងយល់ ដោយមានលំហូរនីតិវិធីជាបន្តបន្ទាប់ចាប់តាំងពីភាគីធ្វើការសុំ ហើយទទួលបានសាលក្រម ឬសាលដីកា វាពិតជាមានភាពស្មុកស្មាញសម្រាប់នីតិវិធីមួយនេះ ដូច្នេះតម្រូវឱ្យមានភាពច្បាស់លាស់ និងមានប្រសិទ្ធភាពខ្ពស់ជាទំនុកចិត្ត និងយុត្តិធម៌ទៅដល់ភាគីផងដែរ។ ព្រោះកន្លងមកនីតិវិធីដែលទាក់ទងទៅនឹងភាគី និងអ្នកតំណាងតាមផ្លូវបណ្ដឹង សម្រាប់ការយល់ដឹង ហើយប្រសិទ្ធភាពដែលចេញមក គឺនៅមានកម្រិតនៅឡើយ និងមានបញ្ហាខ្លះៗ នៅក្នុងពេលដែលអនុវត្តចំពោះភាគី វាក៏ជាកត្តាមួយដែលនាំឲ្យខាតបង់ពេលវេលា និងថវិការ បាត់បង់ទំនុកចិត្តដល់ភាគីអនុវត្ត ក៏ដូចជាប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានបាត់បង់ជំនឿ និងទំនុកចិត្តក្នុងការពឹងពាក់លើវិស័យយុត្តិធម៌នេះផងដែរ។ ហេតុនេះហើយទើបតម្រូវឱ្យអ្នកច្បាប់មានដូចជា តុលាការអនុវត្ត ព្រះរាជអាជ្ញា អាជ្ញាសាលា មេធាវី សាការី ភាគីអនុវត្ត និងប្រជាពលរដ្ឋគ្រប់រូបគួរតែធ្វើការស្វែងយល់បន្ថែមឱ្យកាន់តែស៊ីជម្រៅច្បាស់លាស់ ជាក់លាក់ ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួន ជាពិសេសអ្នកអនុវត្តច្បាប់តែម្ដង កន្លងមកមានការបកស្រាយផ្សេងៗគ្នា និងមិនស្របគ្នា

ទៀតផងចំពោះនីតិវិធីនេះដោយមានការស្មុកស្មាញច្រើន។ ដូច្នេះ តម្រូវឱ្យមានភាពសុក្រិត ងាយស្រួល និងសាមញ្ញដើម្បីសម្រួលដល់ការអនុវត្តនេះឱ្យប្រព្រឹត្តិទៅបានរលូន និងឆាប់រហ័សព្រមទាំងមានទំនុកចិត្តដល់ភាគីផងដែរ។

មួយវិញទៀត យើងខ្ញុំសង្ឃឹមថាស្ថាប័នពាក់ពន្ធ័រតែមានវិធានការនូវក្នុងការពន្យល់ប្រាប់ទៅកាន់ភាគី ឱ្យបានច្បាស់លាស់តាមនីតិវិធីច្បាប់ជៀសវាងមានការអនុវត្តខុសនីតិវិធីដោយកន្លងមកក្នុងការអនុវត្តជាក់ស្តែង គឺភាគីមានការភាន់ច្រឡំនៅឡើយ។ ហេតុដូច្នេះហើយ ក្រសួងយុត្តិធម៌ ក៏ដូចជាស្ថាប័នដែលមានការទាក់ទងទៅនឹងវិស័យច្បាប់គួរតែមានប្រធានការបន្តពង្រឹង និងពង្រីកការផ្សព្វផ្សាយអំពីប្រពន្ធ័ច្បាប់ ជាបន្តបន្ទាប់បន្ថែមទៀតទៅតាមរយៈប្រព័ន្ធបច្ចេកវិទ្យា សោតទស្សន៍ ឬបណ្តាញសង្គមផ្សេងៗទៀត ឬតាមរយៈការបង្កើតកម្មវិធីសិក្ខាសាលាក្តី ដើម្បីឱ្យប្រពលរដ្ឋគ្រប់រូបក៏ដូចជាអ្នកច្បាប់គ្រប់គ្នាបានចូលរួមយល់ដឹងច្បាស់លាស់ស៊ីជម្រៅបន្ថែមទៀត ដើម្បីជាផ្នែកជួយដល់ការពង្រឹងវិស័យយុត្តិធម៌ផងដែរ។

ជាចុងក្រោយយើងខ្ញុំជឿកជាក់យ៉ាងមុតមាំថា នៅពេលដែលពលរដ្ឋខ្មែរយើងបានសិក្សា និងស្វែងយល់ពីច្បាប់ ឬជាពិសេសនីតិវិធីរដ្ឋប្បវេណីដែលទាក់ទងទៅនឹងភាគី និងអ្នកតំណាងតាមផ្លូវបណ្តឹង  នោះនឹងនាំឱ្យពលរដ្ឋខ្មែរមានចំណេះដឹងទូលំទូលាយ ដែលអាចជួយឱ្យពួកគាត់អាចយល់បានកាន់តែច្បាស់ពីកាតព្វកិច្ចរបស់ខ្លួនក្នុងការ អនុវត្តសិទ្ធិឲ្យស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

# ឯកសារយោង

# ឯកសារយោង

- **បទដ្ឋានគតិយុត្ត**

  រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។

  ច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០។

  ក្រមរដ្ឋប្បវេណី, លេខ នស/ រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

  ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

  ព្រះរាជាក្រឹត្យស្តីពីការបង្កើតអាជ្ញាធរ អប្សរា អនុម័តនៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៥។

  ក្រមសីលធម៌នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, ២១ កញ្ញា ២០១២។

- **សៀវភៅ និងប្រភពឯកសារផ្សេងៗ**

  អ៊ីវ ប៉ូលី, សៀវភៅភាគី និងអ្នកតំណាងតាមផ្លូវបណ្តឹង, វិភាគទានច្បាប់, វគ្គបណ្តុះបណ្តាលជំនាន់ទី៧

  ក្រមនីតិវិធីរដ្ឋប្បវេណី

  ហ៊ី សោភា, សៀវភៅពន្យល់ស្តីអំពីក្រមនីតិវិធីរដ្ឋប្បវេណី

  សេចក្តីពន្យល់អំពី ក្រមនីតិវិធីរដ្ឋប្បវេណីរៀបចំដោយក្រុមការងារជប៉ុន ដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៨

- **ឯកសារបរទេស**

  UN, (1990). Basic Principle on the Role of Lawyer

- **គេហទំព័រ**

  https://m.facebook.com/media/set/?vanity=legalcodelawfirm&set=a.3135932433163882

( ចូលទស្សនានៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៤ )

# ឧបសម្ព័ន្ធ

# <u>ឧបសម្ព័ន្ធ</u>

- ឧបសម្ព័ន្ធទី១ : ឯកសារទាក់ទងនឹងអ្នកតំណាង
- ឧបសម្ព័ន្ធទី២ : រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ឧបសម្ព័ន្ធទី៣ : ក្រមរដ្ឋប្បវេណី
- ឧបសម្ព័ន្ធទី៤ : ក្រមនីតិវិធីរដ្ឋប្បវេណី
- ឧបសម្ព័ន្ធទី៥ : ច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

# ឧបសម្ព័ន្ធទី១

# ឯកសារទាក់ទងនឹងអ្នកតំណាង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងរដ្ឋប្បវេណីមិនមែនបណ្ដឹងលេខ៥២៩

ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៤

ដីកាសម្រេចលេខ ០៥៧ មមប/ញ

ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤

# ដីកាសម្រេច

**យើង អាត ចំឡជាក ចៅក្រមសាលាដំបូងខេត្តកណ្ដាល**

**មានលោក នៅ ចាន់ថន ជាក្រឡាបញ្ជីអមផង ។**

- បានឃើញ ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០ ។
- បានឃើញ សំណុំរឿងរដ្ឋប្បវេណីមិនមែនបណ្ដឹងលេខ៖ ៥២៩ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៤។
- បានឃើញ ពាក្យសុំដីកាសម្រេចលែងលះដោយស្ម័គ្រចិត្ត ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៤។
- បានឃើញ កិច្ចព្រមព្រៀងលែងលះគ្នាដោយស្ម័គ្រចិត្ត ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤។
- បានឃើញ កំណត់ហេតុសាកសួរ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤ រវាងឈ្មោះ [redacted] ភេទប្រុស និងឈ្មោះ [redacted] ភេទស្រី។

ក. អត្តសញ្ញាណនាគី៖

អ្នកដាក់ពាក្យសុំឈ្មោះ [redacted] ភេទប្រុស កើតឆ្នាំ១៩៩៣ ជនជាតិខ្មែរ មុខរបរនគរបាល មានទីកន្លែងកំណើតនៅភូមិឡូរី សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ ទីលំនៅបច្ចុប្បន្ននៅភូមិច្រាំងចំរេះ សង្កាត់ទួលសង្កែទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]) ម្ដាយឈ្មោះ [redacted]រស់) [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

ភាគីម្ខាងទៀតឈ្មោះ [redacted] ភេទស្រី កើតឆ្នាំ២០០៤ ជនជាតិខ្មែរ មុខរបរលក់ដូរ ទីកន្លែងកំណើតនៅភូមិខ្ពបវែង សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្ដាល និងទីលំនៅបច្ចុប្បន្ននៅភូមិខ្ពបវែង សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted]) ម្ដាយឈ្មោះ [redacted]។

ខ. ខ្លឹមសារនៃដីកាសម្រេចដែលចាមចារឡើតុលាការចេញ៖

១. បង្គាប់ឲ្យឈ្មោះ [redacted]បងលះពីឈ្មោះ [redacted]ាមការព្រមព្រៀងដោយស្របច្បាប់។

២. បង្គាប់ឲ្យប្រគល់សិទ្ធិអំណាចមេបាលើកូនស្រីឈ្មោះ [redacted]អាយុ១ឆ្នាំ ដែលមានសំបុត្រកំណើតលេខ៦៧ នៃសៀវភៅកំណើតលេខ០២/២០២៣ ឆ្នាំ២០២៣ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ឲ្យទៅឈ្មោះ [redacted]ាម្ដាយតាមការព្រមព្រៀង។

៣. បង្គាប់ឱ្យឈ្មោះ [redacted] ភេទប្រុស ជាឪពុកមានសិទ្ធិចូលជួបសុខទុក្ខ និងប្រាស្រ័យទាក់ទងកូនស្រី ឈ្មោះ [redacted] តាមការព្រមព្រៀង។

៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ឈ្មោះ [redacted]។

## អង្គហេតុ

អ្នកដាក់ពាក្យសុំឈ្មោះ [redacted] ភេទប្រុស និងភាគីម្ខាងទៀតឈ្មោះ [redacted] ភេទស្រី បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅអំឡុងឆ្នាំ២០២២ ត្រឹមត្រូវតាមផ្លូវច្បាប់ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ០៨៩ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ០០២/២០២២ ឆ្នាំ២០២២ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ និងមានកូនស្រីម្នាក់ឈ្មោះ [redacted] អាយុ១ឆ្នាំ ដែលមានសំបុត្រកំណើតលេខ០៦៧ នៃសៀវភៅកំណើតលេខ០០២/២០២៣ ឆ្នាំ២០២៣ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ជាចំណងដៃ។ ដោយហេតុថា នៅក្នុងអំឡុងពេលរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ ភាគីទាំងសងខាងមានការមិនចុះសម្រុងនឹងគ្នា ពោលគឺតែងតែមានភាពរកាំរកូសគ្មានសុភមង្គលឈានដល់ការអស់មនោសញ្ចេតនាជាប្តីប្រពន្ធនឹងគ្នា ហើយមិនសង្ឃឹមថាអាចនឹងធ្វើបដិវាទនសាជាថ្មីវិញបានឡើយ។ ហេតុនេះ បន្ទាប់ពីភាគីទាំងពីរនាក់បានពិភាក្សាគ្នារួចមកបានឈានដល់ការព្រមព្រៀងគ្នាលែងលះដោយស្ម័គ្រចិត្ត និងដោយសន្តិវិធីដូចមានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងលែងលះដោយស្ម័គ្រចិត្ត ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤។

ភស្តុតាងមានដូចជា៖

១.សំបុត្រអាពាហ៍ពិពាហ៍លេខ០៨៩ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២។ (ថតចម្លង)

២.សំបុត្រកំណើតលេខ០៦៧ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] ភេទស្រី។

៣.កិច្ចព្រមព្រៀងលែងលះដោយស្ម័គ្រចិត្ត ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤។

## សំអាងហេតុ

១. យោងតាមសំបុត្រអាពាហ៍ពិពាហ៍លេខ០៨៩ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់កំពង់សំណាញ់ អាចបញ្ជាក់បានថាឈ្មោះ [redacted] និងឈ្មោះ [redacted] ពិតជាប្តីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមប្រពៃណី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ប្រាកដមែន។

២. ផ្អែកតាមកំណត់ហេតុសាកសួរលើអ្នកដាក់ពាក្យសុំឈ្មោះ [redacted] ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤ ថា៖ រូបខ្លួន និងភាគីម្ខាងទៀតបានរៀបអាពាហ៍ពិពាហ៍ជាមួយក្នុងកាលពីអំឡុងឆ្នាំ២០២២ ត្រឹមត្រូវតាមប្រពៃណី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ០៨៩ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២។ ក្រោយពេលរៀបអាពាហ៍ពិពាហ៍រួច យើងមានកូនស្រីចំនួន១នាក់ឈ្មោះ [redacted] ភេទស្រី កើតឆ្នាំ២០២៣។ ចំណែកទ្រព្យសម្បត្តិរួម ឬបំណុលរួមមិនមានឡើយ។ សូមបញ្ជាក់ថា ចាប់តាំងពីរៀបអាពាហ៍ពិពាហ៍រួចមក គឺពួកយើងរស់នៅមិនសូវជាចុះសម្រុងនឹងគ្នាឡើយ ជាហេតុធ្វើឱ្យយើងអស់មនោសញ្ចេតនាជាប្តីប្រពន្ធនឹងគ្នាតទៅទៀតហើយ នឹងបានសម្រេចចិត្ត និងព្រមព្រៀងគ្នាលែងលះដោយស្ម័គ្រចិត្តពិតប្រាកដក្នុងការដាក់ពាក្យសុំមកតុលាការឱ្យសម្រេចអំពីការលែងលះរបស់ពួកខ្លួន។ ហេតុដូចនេះ ខ្លួនសូមឱ្យតុលាការសម្រេចតាមពាក្យសុំចេញ

ដីកាសម្រេចលែងលះដោយស្ម័គ្រចិត្ត ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤ ទាំងស្រុង។

៣. ផ្អែកតាមកំណត់ហេតុសាកសួរលើភាគីម្ខាងទៀតឈ្មោះ [redacted] ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤ ថា៖ នៅក្នុងរឿងនេះ ខ្លួនទទួលស្គាល់ការអះអាងរបស់អ្នកដាក់ពាក្យសុំទាំងស្រុង និងសុំឱ្យតុលាការសម្រេចតាមពាក្យសុំចេញដីកាសម្រេចលែងលះដោយស្ម័គ្រចិត្ត ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤ ទាំងស្រុង។

៤. តាមពាក្យសុំដីកាសម្រេចលែងលះដោយស្ម័គ្រចិត្ត ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៤, កិច្ចព្រមព្រៀងលែងលះគ្នាដោយស្ម័គ្រចិត្ត ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤ និងកំណត់ហេតុសាកសួររវាងអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤ អាចបញ្ជាក់បានថា ភាគីទាំងពីរពិតជាបានព្រមព្រៀងគ្នាលែងលះដោយស្ម័គ្រចិត្ត និងមានឆន្ទៈពិតប្រាកដ គ្មានការបង្ខិតបង្ខំពីភាគីណាម្ខាងឡើយ ដោយមានលោកមេធាវី ស៊ាង ពិសិដ្ឋ បានឃើញក្នុងកិច្ចព្រមព្រៀងលែងលះ ប្រាកដមែន។ ឃើញថា ភាគីទាំងពីរមានបំណងពិតប្រាកដក្នុងការរំលាយចំនាក់ចំនងអាពាហ៍ពិពាហ៍ ស្របតាមមាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី និងមាត្រា៣ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដោយផ្អែកលើផ្នែកទី៤ ចំណុចទី៥ ក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់នេះ។ ដូចនេះ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់ភាគី។

៥. យោងតាមសំបុត្រកំណើតលេខ០៦៧ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ របស់ឈ្មោះ[redacted] ភេទស្រី ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់កំពង់សំណាញ់ អាចបញ្ជាក់បានថា អ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត គឺជាឪពុកម្តាយបង្កើតរបស់កូនស្រីឈ្មោះ [redacted] ភេទស្រី ខាងលើប្រាកដមែន។ ឃើញថា ចំពោះការសម្រេចអំពីអ្នកមានអំណាចមេបាលើកូនស្រីខាងលើ គឺភាគីទាំងសងខាងបានព្រមព្រៀងដោយឆន្ទៈពិតប្រាកដរួចរាល់ហើយ ដូចមាននៅក្នុងកិច្ចព្រមព្រៀងលែងលះគ្នាដោយស្ម័គ្រចិត្ត ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤ ឃើញថា មានភាពត្រឹមត្រូវស្របតាមបញ្ញត្តិមាត្រា១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។ ហេតុដូចនេះ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់ភាគី។ ចំណែកអ្នកដែលមិនមានអំណាចមេបាលើកូនអាចចូលជួបប្រាស្រ័យទាក់ទងជាមួយកូនបានស្របតាមមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី។

៦. បន្ទុកនៃប្រាក់ប្រដាប់ក្តី គប្បីអនុវត្តតាមមាត្រា២២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

## ហេតុដូច្នេះ សម្រេច

១. ឱ្យអ្នកដាក់ពាក្យសុំឈ្មោះ [redacted]និងភាគីម្ខាងទៀតឈ្មោះ [redacted]លែងលះគ្នាតាមការព្រមព្រៀង ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ០៨៩ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល។

២. កំណត់ឱ្យភាគីម្ខាងទៀតឈ្មោះ [redacted]មានសិទ្ធិអំណាចមេបាលើកូនតាមការព្រមព្រៀង គឺ៖

-កូនឈ្មោះ [redacted]ទស្រី កើតថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៣ ជនជាតិខ្មែរ ដែលមានសំបុត្រកំណើតលេខ៦៧ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់កំពង់សំណាញ់។ អ្នកដែលមិនមានអំណាចមេបាលើកូនអាចចូលជួបប្រាស្រ័យទាក់ទងជាមួយកូនបានស្របតាមមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី។

៣. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

ថ្ងៃចន្ទ ១០កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

ធ្វើនៅខេត្តកណ្ដាល, ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤

ចៅក្រម

ហត្ថលេខា និងត្រា៖ អាត ច័ន្ទដារា

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃចន្ទ ១០កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

ធ្វើនៅខេត្តកណ្ដាល, ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤

ក្រឡាបញ្ជី

នៅ_ចាន់ថន

បានឃើញ

ចៅក្រម

អាត_ច័ន្ទដារា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>លិខិតប្រគល់សិទ្ធិ</u>

ខ្ញុំបាទឈ្មោះ ........................ ភេទប្រុស កើតឆ្នាំ១៩៩៩ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ................................ មានអាសយដ្ឋាន ភូមិក្បាលជ្រោយ ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល ។

## <u>សូមប្រគល់សិទ្ធិជូន</u>

លោកមេធាវី ......................... និងលោកមេធាវី ......................... ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីនៃក្រុមមេធាវី............................ មានការិយាល័យតាំងនៅបុរីដឹប ម៉ុងលែន ៥០ ម៉ែត្រ ផ្ទះលេខ២៦ ផ្លូវBLV02 ភូមិប្រការ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ដើម្បីធ្វើជាមេធាវីតំណាងក្នុងការ **ចូលរួមចរចារ ដោះស្រាយវិវាទ ឬតាក់តែងលិខិតជូនដំណឹង** ជំនួសខ្ញុំបាទទៅតាមនីតិវិធី ចាប់ពីថ្ងៃផ្តិតស្នាមមេដៃស្តាំនេះតទៅ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកមេធាវី** មេត្តាទទួលនូវការប្រគល់សិទ្ធិជូនរបស់ខ្ញុំបាទ ដោយសេចក្តីអនុគ្រោះបំផុត ។

រាជធានីភ្នំពេញ, ថ្ងៃទី.........ខែ............... ឆ្នាំ២០២៤

**ស្នាមមេដៃស្តាំ**

**បានឃើញ និង យល់ព្រម**
តាមសំណើររបស់សាមីខ្លួន ក្នុងការប្រគល់សិទ្ធិជូនយើងខ្ញុំ ខាងលើនេះ។
រាជធានីភ្នំពេញ, ថ្ងៃទី.......... ខែ............... ឆ្នាំ២០២៤
**ហត្ថលេខា និងត្រា**

................

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

**អាណត្តិទាយក** ៖ ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ........................... កើតឆ្នាំ ១៩៨៨ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិ
ខ្មែរលេខ .............................. ចុះថ្ងៃទី.......ខែ...........ឆ្នាំ......................

**អាសយដ្ឋានបច្ចុប្បន្ន** ផ្ទះលេខ............ ផ្លូវលេខ.................ភូមិ.............. ឃុំ/សង្កាត់............ ស្រុក/ខណ្ឌ.............
រាជធានី/ខេត្ត............................... ។

**សូមប្រគល់សិទ្ធិជូន ក្រុមមេធាវី ...................................... ធ្វើសកម្មភាពទៅតាមផ្លូវច្បាប់:**

លោកមេធាវី .......................... និងមេធាវី ...................... ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីនៃក្រុមមេធាវី **អេស.ធី.អេស និងសហការី** មានការិយាល័យតាំងនៅបុរីជីបម៉ុងលែន៥០ ម៉ែត្រ ផ្ទះលេខ ២៦ ផ្លូវBLVD2 ភូមិប្រការ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ឱ្យធ្វើជាមេធាវីតំណាងដោយអាណត្តិនៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ.....................ចុះថ្ងៃទី........... ខែ.................ឆ្នាំ២០២៣ របស់សាលាដំបូងខេត្ត.................. តាមនីតិវិធី ។

### ដែលអាចធ្វើសកម្មភាពដូចខាងក្រោម៖

១- សិទ្ធិអំណាចពេញលេញក្នុងការធ្វើសកម្មភាពតំណាងឱ្យ ខ្ញុំបាទ/នាងខ្ញុំ/យើងខ្ញុំ ។

២- ការដាក់ពាក្យបណ្ដឹងតប ។

៣- ការដាក់ពាក្យបណ្ដឹង ការផ្សះផ្សា ការបោះបង់ ឬការទទួលស្គាល់ ការទាមទារ ឬការដកពាក្យខ្លួនចេញពីបណ្ដឹង ដែលខ្លួនចូលរួមអន្តរាគមន៍ ឬទទួលបណ្ដឹង ។

៤- ការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ បណ្ដឹងសាទុក្ខ ឬពាក្យបណ្ដឹងទាស់ដោយរួមទាំងការដកពាក្យបណ្ដឹងនេះផង ។

៥- ការដកពាក្យបណ្ដឹងទាស់ចំពោះសាលក្រមចុងក្រោយនៃបណ្ដឹងទាមទារចំពោះទឹកប្រាក់តិច រួមទាំងការយល់ព្រមចំពោះការដកពាក្យទាស់នេះផងដែរ ។

៦- ធ្វើពាក្យសុំរក្សាការពារ និងអនុវត្តដោយបង្ខំ ។

៧- ការតែងតាំងអនុតំណាង ។

៨- រាល់សកម្មភាពរបស់មេធាវីតំណាងដោយអាណត្តិ គឺធ្វើឡើងក្នុងនាមអាណត្តិទាយក ដើម្បីផលប្រយោជន៍របស់អាណត្តិទាយក ។

បញ្ជាក់: *សោហ៊ុយចំណាយលើការបង់ពន្ធផ្សេងៗនៅក្នុងបណ្ដឹងនេះ ជាបន្ទុករបស់ខ្ញុំបាទ/នាងខ្ញុំ/យើងខ្ញុំ ជាអាណត្តិទាយក ។ ក្នុងករណីមិនបានគោរពតាមកាតព្វកិច្ចនេះ ខ្ញុំបាទ/នាងខ្ញុំ/យើងខ្ញុំ សុខចិត្តទទួលខុសត្រូវនូវរាល់ការបាត់បង់ប្រយោជន៍នានាដោយខ្លួនឯងផ្ទាល់ ។*

រាជធានីភ្នំពេញ, ថ្ងៃទី............ ខែមេសា ឆ្នាំ២០២៣

**ស្នាមមេដៃស្ដាំ**

.....................

**បានឃើញ និង យល់ព្រមទទួល**
ធ្វើជាមេធាវីតំណាងដោយអាណត្តិ ។
រាជធានីភ្នំពេញ, ថ្ងៃទី ........... ខែមេសា ឆ្នាំ២០២៣
**ហត្ថលេខា និងត្រា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>លិខិតតំណាងដោយអាណត្តិ</u>

ខ្ញុំមេធាវី................................ ជាមេធាវីនៃក្រុមមេធាវី **អេស.ធី.អេស និងសហការី** មានការិយាល័យតាំងនៅបុរីដីបម៉ុងលែន៥០ម៉ែត្រ ផ្ទះលេខ២៦ ផ្លូវBLVD2 ភូមិប្រការ សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ និងជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ ............................. ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ..................... ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកំពង់ចាម ។

លេខទំនាក់ទំនង ០៣១ ៥៥៥ ៦៦៦៦ ។

**<u>សូមគោរពជូន</u>**

**ឯកឧត្តមប្រធាន សាលាដំបូងខេត្តកំពង់ចាម**

**<u>កម្មវត្ថុ</u>** ៖ ស្នើសុំធ្វើជាមេធាវីតំណាងដោយអាណត្តិក្នុងសំណុំរឿងរដ្ឋប្បវេណីលេខៈ............... ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកំពង់ចាម ។

**<u>យោង</u>** ៖ - ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ។
- ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ។
- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិចុះថ្ងៃទី....... ខែកញ្ញា ឆ្នាំ២០២៣ របស់ឈ្មោះ ..................។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថាៈ កាលពីថ្ងៃទី....... ខែកញ្ញា ឆ្នាំ២០២៣ ឈ្មោះ ......................... បានប្រគល់សិទ្ធិឱ្យខ្ញុំធ្វើជាមេធាវីតំណាងដោយអាណត្តិក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ............ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកំពង់ចាម តាមនីតិវិធី ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាជ្រាបតាមនីតិវិធី ចាប់ពីពេលនេះតទៅ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពអំពីខ្ញុំបាទ ។

ថ្ងៃ.................. ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី......... ខែកញ្ញា ឆ្នាំ២០២៣
**ហត្ថលេខា និងត្រា**

# ឧបសម្ព័ន្ធទី២

# រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

# រដ្ឋធម្មនុញ្ញ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

**រដ្ឋសភា**

# អារម្ភកថា

❖❖❖❖

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានសភាធម្មនុញ្ញអនុម័ត នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ហើយត្រូវបានព្រះមហាក្សត្រ ឡាយព្រះ-ហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ។ រដ្ឋធម្មនុញ្ញ គឺជាច្បាប់កំពូល នៃព្រះរាជាណាចក្រកម្ពុជា ។ ច្បាប់ និងសេចក្តី សម្រេចទាំងឡាយ នៃស្ថាប័ននានា របស់រដ្ឋត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ។

មកដល់ចុងឆ្នាំ២០១៥ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបាន ធ្វើវិសោធនកម្មចំនួន ៨លើក )ដូចមានក្នុងកំណត់សំគាល់ភ្ជាប់ (ដែលមាន ដូចខាងក្រោម៖

**១**-ច្បាប់ស្តីពីការកែប្រែមាត្រា២៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ-កម្ពុជា ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៤ នាសម័យ ប្រជុំរដ្ឋសភាវិសាមញ្ញ នីតិកាលទី១។ ការកែប្រែ នេះដើម្បីផ្តល់សិទ្ធិដល់ ប្រមុខរដ្ឋស្តីទីចុះហត្ថលេខាលើព្រះរាជក្រម ឬព្រះរាជក្រឹត្យ នៅពេល ព្រះមហាក្សត្រអវត្តមាន ដោយព្រះរាជសារប្រគល់សិទ្ធិ ។

**២**-ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភាអនុម័ត នៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៩ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាល ទី២ ។ វិសោធនកម្មនេះ ដើម្បីបង្កើតឱ្យមានស្ថាប័នព្រឹទ្ធសភា ។

**៣**-ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា១៩ និងមាត្រា២៩ នៃរដ្ឋធម្ម-នុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាល ទី២ ចែងអំពី “ ព្រះ-មហាក្សត្រទ្រង់បង្កើត និងប្រទានគ្រឿងឥស្សរិយយសជាតិ ” និងកែតម្រូវកំហុសបច្ចេកទេសនូវមាត្រា១៩ថ្មី ត្រង់លេខមាត្រា យោងពីមាត្រា១០០ចាស់ ទៅមាត្រា១១៩ថ្មី ។

**៤**-ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៤ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាល ទី៣ ។ ច្បាប់ធម្មនុញ្ញបន្ថែមនេះ មានគោលដៅធានាក្នុងគ្រប់កាលៈទេសៈ នូវដំណើការល្អប្រសើរ នៃស្ថាប័នជាតិ ដោយគោរពទៅតាមគោលការណ៍ជាមូលដ្ឋាននៃលទ្ធិប្រជា-ធិបតេយ្យសេរីពហុបក្ស សមស្របតាមតម្រូវការនៃភាពចាំបាច់។

**៥**-ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៨៨ និងមាត្រា១១១ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៥ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី៣ បានកែប្រែកូរ៉ុមនៃការប្រជុំរដ្ឋសភា៖

-កូរ៉ុមប្រាំពីរភាគដប់ សម្រាប់ការអនុម័តយកមតិភាគច្រើន ពីរភាគបី ឬយកមតិភាគច្រើន បីភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

-កូរ៉ុមប្រាំមួយភាគដប់ សម្រាប់ការអនុម័តយកមតិភាគច្រើន ដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**៦**-ច្បាប់ធម្មនុញ្ញ ស្ដីពីវិសោធនកម្មមាត្រា៨២ មាត្រា៨៨ថ្មី មាត្រា៩០ថ្មី មាត្រា៩៨ មាត្រា១០៦ថ្មី មាត្រា១១១ថ្មី)មួយ (មាត្រា១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវ ដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៣។ ច្បាប់ធម្មនុញ្ញនេះសំដៅកែសម្រួលសម្លេង បោះឆ្នោត ពីសម្លេង ពីរភាគបី មកជា មតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល និងកូរ៉ុមប្រជុំដើម្បី ៖

- បោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកគណៈ-កម្មការនានានៃរដ្ឋសភា
- បោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល និងអនុម័តញត្តិបន្ទោសទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាល
- បោះឆ្នោតជ្រើសរើប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកគណៈ-កម្មការនានានៃព្រឹទ្ធសភា
- អនុម័តបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងព្រឹទ្ធសភា ។

**៧**-ច្បាប់ធម្មនុញ្ញស្ដីពី វិសោធនកម្មមាត្រា១៤៥ថ្មី និងមាត្រា១៤៦ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភានៃព្រះរាជាណា-

ចក្រកម្ពុជាអនុម័ត នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៨ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ ចែងអំពីការបែងចែកទឹកដីនៃព្រះរាជាណាចក្រ- កម្ពុជា ជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។

**៨**-ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៧៦ និងមាត្រាទាំងឡាយពីជំពូកទី១៥ថ្មី ដល់ជំពូក ទី១៦ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ ដោយបញ្ញត្តិអំពីអង្គការរៀបចំការបោះឆ្នោតជាស្ថាប័នធម្មនុញ្ញ ។

ច្បាប់រដ្ឋធម្មនុញ្ញដែលបោះពុម្ពផ្សាយលើកនេះ មាន១៦០មាត្រា ដែលចែកចេញជា១៧ ជំពូក មាន បុព្វកថា អំពីអធិបតេយ្យ អំពីព្រះមហាក្សត្រ អំពីសិទ្ធិ និងករណីកិច្ច របស់ប្រជាពលរដ្ឋខ្មែរ អំពីរបបនយោបាយ អំពីសេដ្ឋ-កិច្ច អំពីអប់រំ វប្បធម៌ និងសង្គមកិច្ច អំពីរដ្ឋសភា អំពីព្រឹទ្ធសភា អំពីសមាជរដ្ឋសភា និងព្រឹទ្ធសភា អំពីរាជរដ្ឋាភិបាល អំពីអំណាចតុលាការ អំពីក្រុមប្រឹក្សាធម្មនុញ្ញ អំពីការគ្រប់គ្រងរដ្ឋបាល អំពីសមាជជាតិ អំពីអង្គការរៀបចំការបោះឆ្នោត អំពីអានុភាពការសើរើ និងវិសោធនកម្មរដ្ឋធម្មនុញ្ញ អំពីអន្តរ-ប្បញ្ញត្តិ ភ្ជាប់ដោយឧបសម្ព័ន្ធចំនួន៧ ។

ខ្ញុំសូមថ្លែងអំណរគុណដល់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភាដែលបានចូលរួមខិតខំប្រមូលចងក្រង ធ្វើបច្ចុប្បន្នភាពច្បាប់រដ្ឋធម្មនុញ្ញនេះ និងសូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ និងគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ដែលជួយគាំទ្រនូវការបោះពុម្ពរដ្ឋធម្មនុញ្ញនេះ ។

ខ្ញុំសង្ឃឹម និងជឿជាក់ថា កម្រងរដ្ឋធម្មនុញ្ញនេះ នឹងជួយដល់សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ក្នុងការសិក្សាស្វែងយល់ អំពីកម្រងខ្លឹមសារនៃរដ្ឋធម្មនុញ្ញនេះឲ្យកាន់តែល្អប្រសើរឡើង។

រាជធានីភ្នំពេញ,ថ្ងៃទី១១ខែកញ្ញា ឆ្នាំ២០១៩

**អគ្គលេខាធិការ**

**ឡេង ប៉េងឡុង**

# បុព្វកថា

❖❖❖❖

## យើង ប្រជារាស្ត្រខ្មែរ

*ដែលធ្លាប់មានអារ្យធម៌ឧត្តុង្គឧត្តម ប្រទេសជាតិស្តុកស្តម្ភ ធំទូលាយថ្កុំថ្កើងរុងរឿង កិត្យានុភាពខ្ពង់ខ្ពស់ ភ្លឺចែងចាំងដូចពេជ្រពណ្ណរាយ*

*បានធ្លាក់ខ្លួនដ៏សែនរន្ធត់ ក្នុងអំឡុងពីរទសវត្សរ៍ចុងក្រោយនេះ ឆ្លងកាត់ទុក្ខសោកវិនាសអន្តរាយ ទ្រុឌទ្រោម ឱនថយមហាសោកស្តាយ*

*បានភ្ញាក់រលឹក ក្រោកឈរឡើង ចងបាច់ឆន្ទៈមោះមុត ប្តូរផ្តាច់រួបរួមគ្នា ពង្រឹងឯកភាពជាតិ រក្សាការពារទឹកដីកម្ពុជា អធិបតេយ្យ ថ្លៃថ្លា និងអារ្យធម៌អង្គរដ៏បវរ កសាងប្រទេសជាតិឱ្យទៅជា "កោះសន្តិភាព" ឡើងវិញ ផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ ទទួលខុសត្រូវខ្ពស់ចំពោះវាសនាអនាគតជាតិឱ្យបានឈានឡើងរីកចម្រើន លូតលាស់ សម្បូររុងរឿងជានិច្ចនិរន្តរ៍។*

## ក្នុងឆន្ទៈមោះមុតនេះ

*យើងសរសេរចារឹកក្នុងរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជាដូចតទៅ :*

# ជំពូកទី ១
# អំពីអធិបតេយ្យ

**មាត្រា ១.-**

ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រ ដែលព្រះមហាក្សត្រ ទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ ។

**មាត្រា ២.-**

បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជាមិនអាចរំលោភបានដាច់ខាត ក្នុងព្រំដែនរបស់ខ្លួន ដែលមានកំណត់ក្នុងផែនទីខ្នាត ១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ នៅចន្លោះឆ្នាំ ១៩៦៣-១៩៦៩ ។

**មាត្រា ៣.-**

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋដែលមិនអាចបំបែកបាន ។

**មាត្រា ៤.-**

បាវចនានៃព្រះរាជាណាចក្រកម្ពុជាគឺៈ ជាតិ សាសនា ព្រះមហាក្សត្រ ។

**មាត្រា ៥.-**

ភាសា និងអក្សរដែលប្រើជាផ្លូវការគឺ ភាសា និងអក្សរខ្មែរ ។

# ឧបសម្ព័ន្ធទី៣

# ក្រមរដ្ឋប្បវេណី

# ក្រមរដ្ឋប្បវេណី

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

# គន្ថីទី ១
# បទប្បញ្ញត្តិទូទៅ
## ជំពូកទោល
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–** ច្បាប់ទូទៅនៃនីតិឯកជន

ក្រមនេះ បញ្ញត្តអំពីគោលការណ៍ទូទៅដែលទាក់ទងទៅនឹងទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី ។ បញ្ញត្តិនៃក្រមរដ្ឋប្បវេណីនេះ ត្រូវយកមកអនុវត្ត ចំពោះទំនាក់ទំនងទ្រព្យសម្បត្តិ និង ទំនាក់ទំនងញាតិ លើកលែងតែមានកំណត់ផ្សេង នៅក្នុងច្បាប់ពិសេស ។

**មាត្រា ២.–** គោលការណ៍ជាមូលដ្ឋាន

ក្រមនេះ កំណត់អំពីគោលការណ៍នៃការធានាសេចក្តីថ្លៃថ្នូររបស់បុគ្គល ភាពស្មើគ្នារបស់បុរស នារី និង សិទ្ធិលើទ្រព្យសម្បត្តិ ដែលត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ។

**មាត្រា ៣.–** គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន

ក្រមនេះ គោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គល និង បញ្ញត្តអំពីទំនាក់ទំនងគតិយុត្តប្រកបដោយសមភាពរវាងបុគ្គលឯកជន ដោយរួមបញ្ចូលទាំងនីតិបុគ្គល ។ នីតិបុគ្គលសាធារណៈ ដែលនៅក្នុងទំនាក់ទំនងនៃការជួញដូរ ត្រូវចាត់ទុកថាជាបុគ្គលឯកជន ។

**មាត្រា ៤.–** ការហាមឃាត់មិនឱ្យប្រើប្រាស់សិទ្ធិដោយបំពាន

ទោះបីជាសិទ្ធិក៏ដោយ ក៏ពុំត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ដោយបំពានឡើយ ។ នៅក្នុងករណីដែលបានប្រើប្រាស់សិទ្ធិ ដោយបំពានហួសពីទំហំនៃការការពារ ដែលត្រូវបានបញ្ញត្តទុក មិនអាចទទួលស្គាល់អានុភាពនៃការប្រើសិទ្ធិនោះឡើយ ។

**មាត្រា ៥.–** គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់

ការប្រើសិទ្ធិ និង ការអនុវត្តករណីយកិច្ច ត្រូវធ្វើឡើងដោយសុចរិត ផ្អែកតាមភាពស្មោះត្រង់ ។

# គន្ថីទី ២
# បុគ្គល
## ជំពូកទី ១
## រូបវន្តបុគ្គល
### ផ្នែកទី ១
### សមត្ថភាពទទួលសិទ្ធិ

**មាត្រា ៦.–** គោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិ

រូបវន្តបុគ្គលគ្រប់រូប មានលក្ខណសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ចបាន ។

**មាត្រា ៧.–** ការកម្រិតក្នុងការទទួលសិទ្ធិចំពោះជនបរទេស

ជនជាតិបរទេស មិនអាចទទួលបាន ឬ កាន់កាប់នូវសិទ្ធិមួយចំនួនដែលត្រូវបានកំណត់ឡើយ ក្នុងករណីដែលមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ជាតិ ឬ សន្ធិសញ្ញា ឬ អនុសញ្ញាអន្តរជាតិ ។

**មាត្រា ៨.–** ពេលចាប់ផ្តើម និង បញ្ចប់សមត្ថភាពទទួលសិទ្ធិ

រូបវន្តបុគ្គលម្នាក់ៗ មានសមត្ថភាពទទួលសិទ្ធិនៅពេលចាប់កំណើត ហើយបាត់បង់អស់នូវសមត្ថភាពទទួលសិទ្ធិនេះ នៅពេលទទួលមរណភាព ។

**មាត្រា ៩.–** ទារកនៅក្នុងគភ៌

១-ទារកដែលនៅក្នុងគភ៌នាពេលមានអំពើអនីត្យានុកូល បើទារកនេះមានកំណើតនៅពេលក្រោយ អាចទាមទារនូវសំណងនៃការខូចខាតដែលបានកើតឡើងពេលដែលខ្លួននៅក្នុងគភ៌ ដោយអំពើអនីត្យានុកូលនោះបាន ។

២-ទារកដែលនៅក្នុងគភ៌នាពេលដែលចាប់ផ្តើមសន្តតិកម្ម បើទារកនោះមាន

ខាត ដោយអ្នកដែលបានទទួលរងនូវការរំលោភផលប្រយោជន៍ទាក់ទងនឹងលក្ខណបុគ្គល នោះ ដោយយោងទៅតាមបញ្ញត្តិស្តីពីអំពើអនីត្យានុកូលបានឡើយ ។

## ផ្នែកទី ៣
## សមត្ថភាពខាងឆន្ទៈ

**មាត្រា ១៤.–** ការខ្វះសមត្ថភាពខាងឆន្ទៈ

សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន ។

**មាត្រា ១៥.–** និយមន័យនៃសកម្មភាព

ពាក្យ "សកម្មភាព" ដែលត្រូវបានប្រើនៅក្នុងផ្នែកទី ៣ (សមត្ថភាពខាងឆន្ទៈ) ផ្នែកទី ៤ (សមត្ថភាពក្នុងការធ្វើសកម្មភាព) និង ផ្នែកទី ៦ (ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន និង ការប្រកាសអំពីការបាត់ខ្លួន) នៃជំពូកទី ១ នេះ សំដៅទៅលើកិច្ចសន្យា និង សកម្មភាពឯកតោភាគី ។

## ផ្នែកទី ៤
## សមត្ថភាពក្នុងការធ្វើសកម្មភាព

**មាត្រា ១៦.–** អត្ថន័យនៃជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

ជនដែលត្រូវបានកម្រិតសមត្ថភាព សំដៅទៅលើអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ ។

### កថាភាគទី ១
### អនីតិជន

**មាត្រា ១៧.–** អត្ថន័យនៃអនីតិជន

អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

**មាត្រា ១៨.–** សិទ្ធិលុបចោលសកម្មភាព

សកម្មភាពដែលអនីតិជនបានធ្វើដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលុបចោលបាន ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះសកម្មភាពដែលទទួលសិទ្ធិ ឬ ឱ្យរួចផុតពីកាតព្វកិច្ច ឬ សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។

**មាត្រា ១៩.–** ការចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឱ្យចាត់ចែង

អនីតិជនអាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែង ដោយកំណត់គោលបំណង ក្នុងទំហំនៃគោលបំណងនេះបាន ។ ម្យ៉ាងទៀត អនីតិជនក៏អាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែងដោយមិនបានកំណត់គោលបំណងបានដែរ ។

**មាត្រា ២០.–** អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម

១-អនីតិជនដែលបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មមួយប្រភេទ ឬ ច្រើនប្រភេទ ពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថភាពដូចនីតិជន ចំពោះមុខជំនួញនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើបានដឹងច្បាស់ថា អនីតិជននោះមិនអាចបំពេញកិច្ចការអាជីវកម្មនោះបាន អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោល ឬ កម្រិតនូវការអនុញ្ញាតនៃការប្រកបអាជីវកម្មនោះបាន ។

**មាត្រា ២១.–** ល័ក្ខខ័ណ្ឌនៃអគ្គាធីនភាព

១-ក្នុងករណីដែលអនីតិជនដែលបានដល់អាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំ ទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនូវអគ្គាធីនភាពរបស់អ្នកនោះបាន

**មាត្រា ២៧.-** ការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៤ (ការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅ) នៃក្រមនេះ បានរលាយ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

## កថាភាគទី ៣
## ជននៅក្រោមហិតូបត្ថម្ភ

**មាត្រា ២៨.-** ការប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភ

១-ចំពោះជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភលើជននោះបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

២-ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសាមីខ្លួនជាជននៅក្រោមអាណាព្យាបាលទូទៅ តុលាការត្រូវលុបចោលការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅចំពោះជននោះ ។

**មាត្រា ២៩.-** អត្ថន័យនៃជននៅក្រោមហិតូបត្ថម្ភ និង ការជ្រើសតាំងហិតូបត្ថម្ភកៈ

ជនដែលបានទទួលការប្រកាសចាប់ផ្ដើមហិតូបត្ថម្ភ ត្រូវហៅថា ជននៅក្រោមហិតូបត្ថម្ភ ហើយត្រូវស្ថិតនៅក្រោមការថែរក្សាដោយហិតូបត្ថម្ភកៈ ។

**មាត្រា ៣០.-** សិទ្ធិលុបចោលសកម្មភាព

លើកលែងតែសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ សកម្មភាពដែល

បានធ្វើឡើងដោយជននៅក្រោមហិតូបត្ថម្ភ ដោយគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈដូចខាងក្រោមនេះ អាចលុបចោលបាន ៖

ក-ការទទួល ឬ ការប្រើប្រាស់ទុន ។

ខ-ការខ្ចីទ្រព្យ ឬ ការធានា ។

គ-ការធ្វើសកម្មភាពដែលមានគោលបំណងទទួលបាន ឬ ធ្វើឱ្យបាត់បង់សិទ្ធិដែលទាក់ទងនឹងអចលនវត្ថុ ឬ ទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀត ។

ឃ-ការធ្វើសកម្មភាពបណ្តឹង ។

ង-ការធ្វើប្រទានកម្ម ឬ ធ្វើកិច្ចសន្យាស្រុះស្រួល ឬ កិច្ចសន្យាមជ្ឈត្តកម្ម ។

ច-ការទទួលស្គាល់នូវសន្តតិកម្ម ឬ ការបោះបង់ចោលនូវសិទ្ធិសន្តតិកម្ម ឬ ការបែងចែកនូវមត៌ក ។

ឆ-ការប្រកែកមិនទទួលប្រទានកម្មឬអច្ច័យទាន ឬ ការយល់ព្រមទទួលនូវប្រទានកម្មឬអច្ច័យទានដែលភ្ជាប់នឹងបន្ទុក ។

ជ-ការសាងសង់សំណង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬ ការជួសជុលធំ ។

ឈ-ការធ្វើភតិសន្យា ដែលមានអំឡុងពេលលើសពី ៣ (បី) ឆ្នាំ ចំពោះដីធ្លីលើសពី ២ (ពីរ) ឆ្នាំ ចំពោះអាគារ លើសពី ៦ (ប្រាំមួយ) ខែ ចំពោះចលនវត្ថុ ។

ញ-សកម្មភាពដែលតុលាការបានប្រកាសជាពិសេសថា ចាំបាច់ត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈ តាមពាក្យសុំរបស់ជនដែលបានរៀបរាប់នៅក្នុងមាត្រា ២៨ (ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ) នៃក្រមនេះ ឬ ហិតូបត្ថម្ភកៈ ឬ អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ ។

**មាត្រា ៣១.–** ការលុបចោលការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៨ (ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ) នៃក្រមនេះ បានរលាយ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន

កូន ប្រសិនបើមិនអាចកំណត់ឪពុករបស់កូននោះ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះទេ ត្រូវសន្មតថា កូននោះជាកូនរបស់ប្តីដែលបានរៀបអាពាហ៍-ពិពាហ៍ក្រោយ ។

**មាត្រា ៩៨៩.–** ការបដិសេធបិតុភាព

នៅក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ៩៨៨ (ការសន្មតបិតុភាព) ខាងលើនេះ ជនដែលត្រូវបានសន្មតថាជាឪពុក ឬ កូន អាចបដិសេធបិតុភាពបាន ។

**មាត្រា ៩៩០.–** បណ្តឹងបដិសេធបិតុភាពពីជនដែលត្រូវបានសន្មតថាជាឪពុក

១-សិទ្ធិបដិសេធរបស់ជនដែលត្រូវបានសន្មតថាជាឪពុកដែលបានកំណត់នៅក្នុងមាត្រា ៩៨៩ (ការបដិសេធបិតុភាព) ខាងលើនេះ ត្រូវអនុវត្ត ដោយបណ្តឹងចំពោះកូន ។

២-ជនដែលត្រូវបានសន្មតថាជាឪពុក ត្រូវដាក់ពាក្យបណ្តឹងបដិសេធបិតុភាព ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលខ្លួនបានដឹងអំពីកំណើតរបស់កូន ។

៣-នៅពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បានកន្លងផុត បើជនដែលត្រូវបានសន្មតថាជាឪពុក ជាជនដែលនៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលនោះត្រូវគណនា ដោយគិតចាប់ពីពេលដែលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

**មាត្រា ៩៩១.–** បណ្តឹងបដិសេធបិតុភាព ពីកូន

១-សិទ្ធិបដិសេធរបស់កូន ដែលបានកំណត់នៅក្នុងមាត្រា ៩៨៩ (ការបដិសេធបិតុភាព) នៃក្រមនេះ ត្រូវអនុវត្តដោយបណ្តឹងចំពោះជនដែលត្រូវបានសន្មតថាជាឪពុក ។

២-ក្នុងករណីដែលកូនដែលជាអនីតិជន ប្រើសិទ្ធិបដិសេធ បើកូននោះគ្មានម្តាយដែលអនុវត្តអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនទេ តុលាការត្រូវជ្រើសតាំងអ្នកតំណាងពិសេស ។

៣-កូន មិនអាចអនុវត្តសិទ្ធិបដិសេធបានឡើយ ប្រសិនបើអំឡុងពេល ៦ (ប្រាំមួយ)

# ឧបសម្ព័ន្ធទី៤

# ក្រមនីតិវិធីរដ្ឋប្បវេណី

# ក្រម
# នីតិវិធីរដ្ឋប្បវេណី

# ព្រះរាជក្រម

នស/រកម/០៧០៦/០២១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០០៦នាសម័យប្រជុំពេញអង្គលើកទី១នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# គន្ថីទី ១

# បទប្បញ្ញត្តិទូទៅ

## ជំពូកទី ១

## គោលបំណងនៃក្រមនីតិវិធីរដ្ឋប្បវេណី គោលបំណងនៃបណ្តឹងរដ្ឋប្បវេណី ការទទួលខុសត្រូវរបស់តុលាការ និង គូភាគី

**មាត្រា ១.–** គោលបំណងនៃក្រមនីតិវិធីរដ្ឋប្បវេណី

នីតិវិធីដែលទាក់ទងទៅនឹងបណ្តឹងរដ្ឋប្បវេណី ត្រូវធ្វើតាមបញ្ញត្តិនៃក្រមនេះ លើកលែងតែក្នុងករណីដែលច្បាប់ផ្សេងបានកំណត់ពិសេស ។

**មាត្រា ២.–** គោលបំណងនៃបណ្តឹងរដ្ឋប្បវេណី សិទ្ធិពឹងពាក់តុលាការ

១-បណ្តឹងរដ្ឋប្បវេណីមានគោលបំណងឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណីដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន ។

២-ជនគ្រប់រូបត្រូវបានធានានូវសិទ្ធិពឹងពាក់តុលាការចំពោះវិវាទរដ្ឋប្បវេណី ។

**មាត្រា ៣.–** សិទ្ធិទាមទារឱ្យសាកសួរ គោលការណ៍ចំពោះមុខ

១-ភាគីណាក៏មិនអាចត្រូវបានជម្រះក្តីដោយមិនបានសាកសួរ ឬ កោះហៅឡើយ ។

២-ក្នុងករណីណាក៏ដោយ តុលាការត្រូវគោរពគោលការណ៍ចំពោះមុខ ។

**មាត្រា ៤.–** ការទទួលខុសត្រូវរបស់តុលាការ និង ភាគី

តុលាការត្រូវប្រឹងប្រែង ដើម្បីរ៉ាប់រងបណ្តឹងរដ្ឋប្បវេណីឱ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌និងឆាប់រហ័ស ឯភាគីត្រូវអនុវត្តបណ្តឹងរដ្ឋប្បវេណីដោយសុចរិតនិងស្មោះត្រង់ ។

**មាត្រា ៥.–** ភាសាដែលប្រើក្នុងតុលាការ សិទ្ធិរបស់ភាគីក្នុងការស្នើសុំឱ្យមានអ្នកបកប្រែ

១-នៅក្នុងតុលាការ ត្រូវប្រើភាសាខ្មែរ ។

២-ភាគីដែលមិនអាចយល់ភាសាខ្មែរ អាចស្នើសុំរកអ្នកបកប្រែភាសាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ហើយប្រសិនបើសាមីខ្លួនពុំមានលទ្ធភាពរកខ្លួនឯងបានទេ រដ្ឋ

ត្រូវរកជំនួស ។

**មាត្រា ៦.-** ការចូលរួមរបស់តំណាងអយ្យការ

១-ក្នុងករណីដែលយល់ឃើញថា ចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ តុលាការត្រូវជូនដំណឹងទៅតំណាងអយ្យការថា ពាក្យបណ្ដឹងត្រូវបានទទួល ។

២-ទោះបីជាគ្មានការជូនដំណឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពីតុលាការក៏ដោយ ក៏តំណាងអយ្យការ អាចចូលរួមក្នុងនីតិវិធីនៃបណ្ដឹងរដ្ឋប្បវេណី និង បញ្ចេញយោបល់បានដែរ ប្រសិនបើខ្លួនយល់ឃើញថា ចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ ។

## ជំពូកទី ២

## តុលាការ

### ផ្នែកទី ១

### សមត្ថកិច្ចសាលាជម្រះក្ដី

**មាត្រា ៧.-** និយមន័យនៃតុលាការដែលមានសមត្ថកិច្ច

តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការដែលអាចទទួលដោយស្របច្បាប់នូវពាក្យបណ្ដឹង វិនិច្ឆ័យលើរឿងក្ដី ហើយចេញសាលក្រម ឬ សាលដីកាបាន ។

**មាត្រា ៨.-** សមត្ថកិច្ចសាលាជម្រះក្ដីដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍

បណ្ដឹងចំពោះចុងចម្លើយដែលបានកំណត់ក្នុងចំណុចខាងក្រោមនេះ ត្រូវដាក់ពាក្យបណ្ដឹងទៅសាលាដំបូង ដែលមានសមត្ថកិច្ចជម្រះក្ដីនៅទីកន្លែងដែលបានកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-រូបវន្តបុគ្គល :

-លំនៅឋានរបស់ចុងចម្លើយ ។

-ទីសំណាក់ បើពុំមានលំនៅឋាន ឬ មានលំនៅឋានមិនពិតប្រាកដនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

សមត្ថកិច្ចផ្តាច់មុខចំពោះបណ្តឹង ។

**មាត្រា ១៦.–** ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ

តុលាការអាចពិនិត្យភស្តុតាងចំពោះបញ្ហាដែលទាក់ទងនឹងសមត្ថកិច្ចសាលាជម្រះក្តី ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។

**មាត្រា ១៧.–** មូលដ្ឋាននៃពេលវេលាសម្រាប់កំណត់សមត្ថកិច្ចសាលាជម្រះក្តី

សមត្ថកិច្ចសាលាជម្រះក្តីត្រូវកំណត់តាមពេលដាក់ពាក្យបណ្តឹង ។

**មាត្រា ១៨.–** ការចាត់ចែងបណ្តឹងខុសសមត្ថកិច្ចសាលាជម្រះក្តី

១-ប្រសិនបើតុលាការយល់ឃើញថា បណ្តឹងទាំងមូល ឬ ផ្នែកណាមួយ មិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនទេ តុលាការនេះត្រូវផ្ទេរបណ្តឹងនោះទៅតុលាការដែលមានសមត្ថកិច្ច តាមពាក្យសុំរបស់ភាគី ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

២-ពាក្យសុំផ្ទេរបណ្តឹងត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ លើកលែងតែករណីដែលដាក់ពាក្យសុំនៅកាលបរិច្ឆេទ ។ នៅពេលធ្វើពាក្យសុំនេះ ត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីមូលហេតុនៃពាក្យសុំនោះ ។

**មាត្រា ១៩.–** ការផ្ទេរដើម្បីជៀសវាងពីការយឺតយ៉ាវ ជាអាទិ៍

១-ទោះបីជាបណ្តឹងណាមួយស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនក៏ដោយ ប្រសិនបើតុលាការនៃការជំនុំជម្រះលើកទី ១ យល់ឃើញថាចាំបាច់ដើម្បីជៀសវាងពីការយឺតយ៉ាវហួសហេតុនៃនីតិវិធី ឬ ដើម្បីធ្វើឱ្យមានសមធម៌រវាងគូភាគី ដោយពិចារណាអំពីលំនៅឋានរបស់ភាគីនិងសាក្សីដែលត្រូវសាកសួរ ទីតាំងនៃវត្ថុដែលនឹងត្រូវបានត្រួតពិនិត្យ និង កាលៈទេសៈផ្សេងៗ តុលាការនោះអាចផ្ទេរបណ្តឹងទាំងមូល ឬ ផ្នែកណាមួយ ទៅតុលាការផ្សេងទៀត ដែលមានសមត្ថកិច្ច តាមពាក្យសុំរបស់ភាគី ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។

២-ក្នុងករណីដែលមានពាក្យសុំ ដែលបានកំណត់ក្នុងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវសម្រេច ដោយសួរយោបល់របស់ភាគីម្ខាងទៀត ។ ក្នុងករណីដែលតុលាការសម្រេចនូវការផ្ទេរដែលបានកំណត់ក្នុងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន នោះតុលាការអាចសួរយោបល់គូភាគីបាន ។

**មាត្រា ២០.–** ការកម្រិតនូវការផ្ទេរក្នុងករណីសមត្ថកិច្ចផ្តាច់មុខដែលបានកំណត់ដោយច្បាប់

បញ្ញត្តិនៃមាត្រា ១៩ (ការផ្ទេរដើម្បីជៀសវាងពីការយឺតយ៉ាវ ជាអាទិ៍) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបណ្តឹងស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខដែលបានកំណត់ដោយច្បាប់របស់តុលាការដែលចាត់ការបណ្តឹងនោះ ។

**មាត្រា ២១.–** បណ្តឹងជំទាស់

ចំពោះដីកាសម្រេចផ្ទេរ និង ដីកាសម្រេចលើកចោលពាក្យសុំផ្ទេរ អាចប្តឹងជំទាស់បាន ។

**មាត្រា ២២.–** អានុភាពនៃដីកាសម្រេចផ្ទេរ ជាអាទិ៍

១-ដីកាសម្រេចស្ថាពរនៃការផ្ទេរ ត្រូវមានអានុភាពឱ្យតុលាការដែលទទួលការផ្ទេរប្រតិបត្តិតាម ។

២-តុលាការដែលបានទទួលការផ្ទេរ មិនអាចផ្ទេររឿងក្តីទៅតុលាការផ្សេងទៀតបានទេ ។

៣-នៅពេលដីកាសម្រេចផ្ទេរចូលជាស្ថាពរ បណ្តឹងនោះត្រូវចាត់ទុកថាតុលាការដែលទទួលការផ្ទេរ ចាត់ការតាំងពីដើម ។

៤-នៅពេលដីកាសម្រេចផ្ទេរចូលជាស្ថាពរ តុលាការដែលបានសម្រេចការផ្ទេរត្រូវបញ្ជូនសំណុំរឿងអំពីបណ្តឹងនេះ ទៅតុលាការដែលទទួលការផ្ទេរ ។

## ផ្នែកទី ២
## រចនាសម្ព័ន្ធនៃតុលាការ

**មាត្រា ២៣.–** ការជម្រះក្តីលើកទី ១ ដោយចៅក្រមមួយរូប ឬ ដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម

១-នៅសាលាដំបូង រឿងក្តីត្រូវទទួលបន្ទុកដោះស្រាយដោយចៅក្រមម្នាក់ លើកលែងតែករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ ។

២-ចំពោះរឿងក្តីខាងក្រោមនេះ ត្រូវទទួលបន្ទុកដោះស្រាយដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម :

ក-រឿងក្តីដែលកម្មវត្ថុនៃបណ្តឹងមានតម្លៃមិនតិចជាង ៥.០០០.០០០ (ប្រាំលាន) រៀល ហើយដែលតុលាការទទួលស្គាល់ថា គួរតែត្រូវបានវិនិច្ឆ័យនិងជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដោយគិតពិចារណាអំពីចំនួននៃគូភាគី និង បញ្ហាផ្សេងទៀត ។

ខ-រឿងក្តីដែលច្បាប់កំណត់ថាត្រូវវិនិច្ឆ័យ និង ជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ។

៣-ក្នុងក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដែលបានកំណត់ក្នុងបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវមានចៅក្រម ៣ (បី) នាក់ ហើយចាត់តាំងម្នាក់ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

៤-ដីកាសម្រេចឱ្យវិនិច្ឆ័យ និង ជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមដោយយោងតាមចំណុច ក នៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សា ។

**មាត្រា ២៤.–** ការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះ

១-ការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះមិនត្រូវបានធ្វើជាសាធារណៈទេ ។

២-ការពិភាក្សាត្រូវបានបើក និង ដឹកនាំដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

៣-ចៅក្រមម្នាក់ៗត្រូវបញ្ចេញមតិយោបល់របស់ខ្លួនក្នុងការពិភាក្សានេះ ។

៤-ដំណើរការនៃការពិភាក្សា មតិយោបល់របស់ចៅក្រមម្នាក់ៗ និង ចំនួនសំឡេងនៃមតិ ត្រូវរក្សាទុកជាសម្ងាត់ ។

**មាត្រា ២៥.–** ការសម្រេចនៃក្រុមប្រឹក្សាជំនុំជម្រះ

១-ការសម្រេចត្រូវធ្វើឡើងដោយមតិភាគច្រើនរបស់ចៅក្រមក្នុងក្រុមប្រឹក្សាជំនុំជម្រះ ។

២-ចៅក្រមម្នាក់ៗក្នុងក្រុមប្រឹក្សាជំនុំជម្រះនេះ ត្រូវមានសិទ្ធិសម្រេចស្មើគ្នា ។

ង-កាលណាចៅក្រមបានធ្វើជាសាក្សី ឬ ធ្វើជាអ្នកជំនាញក្នុងរឿងក្តី ។

ច-កាលណាចៅក្រមជាអ្នកតំណាង ឬ ធ្លាប់ជាអ្នកតំណាង ឬ ជាអ្នកជំនួយឱ្យភាគីចំពោះរឿងក្តី ។

ឆ-កាលណាចៅក្រមបានចូលរួមក្នុងការសម្រេចសេចក្តីមជ្ឈត្តករចំពោះរឿងក្តី ឬ បានចូលរួមក្នុងការសម្រេចសេចក្តីនៅក្នុងការជំនុំជម្រះលើកទី ១ ដែលបានឧបាស្រ័យ ឬ ការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ដែលបានឧបាស្រ័យ ឬ បង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ ចំពោះរឿងក្តី ។

២-ក្នុងករណីដូចមានមូលហេតុនៃការដកហូត ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវសម្រេចសេចក្តីអំពីការដកហូតនោះ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

**មាត្រា ២៨.–** បណ្តឹងជំទាស់ចៅក្រម

១-ក្នុងករណីដែលមានកាលៈទេសៈដែលបណ្តាលឱ្យមានការលំអៀងក្នុងការជម្រះក្តី ចំពោះចៅក្រមណាម្នាក់ នោះភាគីអាចប្តឹងជំទាស់ចៅក្រមនោះបាន ។

២-ក្នុងករណីដែលភាគីបានឆ្លើយទាញហេតុផលចំពោះមុខចៅក្រម ឬ បានធ្វើសេចក្តីដោះសានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលចំពោះមុខចៅក្រមរួចហើយ នោះភាគីមិនអាចប្តឹងជំទាស់ចៅក្រមនោះបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីនោះមិនបានដឹងអំពីមូលហេតុដែលអាចប្តឹងជំទាស់ ឬ ករណីដែលមូលហេតុនៃបណ្តឹងជំទាស់បានកើតឡើងនៅពេលក្រោយ ។

**មាត្រា ២៩.–** ការដកខ្លួនរបស់ចៅក្រម

ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៧ (ការដកហូតចៅក្រមពីសមត្ថកិច្ចជំនុំជម្រះ) ឬ កថាខណ្ឌទី ១ នៃមាត្រា ២៨ (បណ្តឹងជំទាស់ចៅក្រម) នៃក្រមនេះ ចៅក្រមអាចដកខ្លួនបាន ដោយទទួលការអនុញ្ញាតពីប្រធានតុលាការដែលខ្លួនស្ថិតនៅក្រោម ។

**មាត្រា ៣០.–** ការសម្រេចសេចក្តីអំពីពាក្យសុំដកហូត ឬ បណ្តឹងជំទាស់

១-ចំពោះការដកហូតចៅក្រម ឬ បណ្តឹងជំទាស់ចំពោះចៅក្រម ក្រុមប្រឹក្សាជំនុំជម្រះ

កំណត់សម្រាប់ជនដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹង

១-បុគ្គលដែលអាចមានសិទ្ធិ និង ករណីយកិច្ច តាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និង ច្បាប់ផ្សេងទៀត អាចជាដើមចោទ ឬ ចុងចម្លើយនៅក្នុងបណ្តឹងរដ្ឋប្បវេណី ។

២-បុគ្គលដែលមានសមត្ថភាពធ្វើសកម្មភាពដោយខ្លួនឯង តាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និង ច្បាប់ផ្សេងទៀត អាចដាក់ពាក្យបណ្តឹងដោយខ្លួនឯងដោយតាំងខ្លួនជាដើមចោទ ឬ អាចឆ្លើយដោះសាចំពោះបណ្តឹង ដោយតាំងខ្លួនជាចុងចម្លើយ ឬ អាចធ្វើសកម្មភាពបណ្តឹងផ្សេងទៀតដែលជាចាំបាច់ ។

៣-អនីតិជន និង ជននៅក្រោមអាណាព្យាបាលទូទៅ អាចធ្វើសកម្មភាពបណ្តឹងសុពលបាន លុះត្រាតែត្រូវបានធ្វើដោយអ្នកតំណាងដែលច្បាប់បានកំណត់។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអនីតិជនអាចធ្វើសកម្មភាពដោយឯករាជ ។

៤-បញ្ញត្តិនៃក្រមរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀត ត្រូវយកមកអនុវត្ត ចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ និង សិទ្ធិតំណាងរបស់អ្នកតំណាងនោះ ។

**មាត្រា ៣៣.—** បញ្ញត្តិពិសេសស្តីពីសកម្មភាពបណ្តឹងរបស់ជននៅក្រោមហិត្តូបត្ថម្ភ និង អ្នកតំណាងដែលច្បាប់បានកំណត់

១-ជននៅក្រោមហិត្តូបត្ថម្ភ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ អាចធ្វើសកម្មភាពបណ្តឹង ចំពោះបណ្តឹង ឬ បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលត្រូវបានធ្វើដោយភាគីម្ខាងទៀត ដោយគ្មានការយល់ព្រមពីហិត្តូបត្ថម្ភកៈ ឬ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល ឬ ការប្រគល់សិទ្ធិផ្សេងទៀត ។

២-ជននៅក្រោមហិត្តូបត្ថម្ភ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ត្រូវមានការប្រគល់សិទ្ធិពិសេសដើម្បីធ្វើសកម្មភាពបណ្តឹងខាងក្រោមនេះ :

ក-ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ ឬ ការទទួលស្គាល់នូវការទាមទារ ។

ខ-ការដកពាក្យបណ្តឹងឧទ្ធរណ៍ ឬ ពាក្យបណ្តឹងសាទុក្ខ ។

**មាត្រា ៣៤.—** បញ្ញត្តិពិសេសស្តីពីសមត្ថភាពក្នុងការធ្វើបណ្តឹងរបស់ជនបរទេស

ជនបរទេសត្រូវទុកជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹង ប្រសិនបើជននោះ

ត្រូវមានសមត្ថភាពក្នុងការធ្វើបណ្តឹងស្របទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ទោះបីជាជននោះគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹងតាមច្បាប់នៃប្រទេសរបស់ខ្លួនក៏ដោយ ។

**មាត្រា ៣៥.-** វិធានការក្នុងករណីដែលខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹង ជាអាទិ៍

១-ក្នុងករណីដែលមានការខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹង ឬ សិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ ការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្តឹង តុលាការត្រូវបង្គាប់ឱ្យកែតម្រូវនូវចំណុចខ្វះនោះ ដោយកំណត់អំឡុងពេល ។ ក្នុងករណីនេះ ប្រសិនបើមានការខូចខាតណាមួយអាចកើតឡើងដោយសារការយឺតយ៉ាវ តុលាការអាចឱ្យបុគ្គលដែលមានការខ្វះនោះ ធ្វើសកម្មភាពបណ្តឹងជាបណ្តោះអាសន្នបាន ។

២-សកម្មភាពបណ្តឹងណាដែលត្រូវបានធ្វើឡើងដោយបុគ្គលដែលខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹង ឬ ខ្វះសិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ ខ្វះការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្តឹង ត្រូវមានអានុភាពប្រតិសកម្មតាំងពីពេលដែលសកម្មភាពនោះបានធ្វើឡើង បើមានការទទួលស្គាល់នៅពេលក្រោយ ដោយភាគីដែលបានទទួលសមត្ថភាពក្នុងការធ្វើបណ្តឹង ឬ ដោយអ្នកតំណាងដែលបានទទួលសិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ ការប្រគល់សិទ្ធិ ។

៣-សិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ ការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្តឹង ត្រូវបានបញ្ជាក់ដោយលិខិតជាលាយល័ក្ខណ៍អក្សរ ។

**មាត្រា ៣៦.-** អ្នកតំណាងពិសេស

១-ក្នុងករណីដែលគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ ឬ ករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ ពុំអាចប្រតិបត្តិនូវសិទ្ធិតំណាងនោះ បុគ្គលដែលមានបំណងធ្វើសកម្មភាពបណ្តឹងចំពោះបុគ្គលដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹង អាចដាក់ពាក្យសុំទៅតុលាការដែលបានទទួលបណ្តឹង ឱ្យជ្រើសតាំងអ្នកតំណាងពិសេស ដោយធ្វើសេចក្តីបញ្ជាក់ដំបូងថា ការខូចខាតអាចនឹងកើតឡើងដោយសារការយឺតយ៉ាវនោះ ។

២-តុលាការអាចផ្លាស់ប្តូរអ្នកតំណាងពិសេស នៅពេលណាក៏បាន ។

៣-ការសម្រេចសេចក្តីអំពីការជ្រើសតាំង ឬ ការផ្លាស់ប្តូរអ្នកតំណាងពិសេសនឹងត្រូវបានជូនដំណឹងឱ្យអ្នកតំណាងពិសេសផងដែរ ។

## ផ្នែកទី ៤
## អ្នកតំណាងដោយអាណត្តិ និង អ្នកជំនួយ

**មាត្រា ៥២.-** សកម្មភាពបណ្ដឹងដែលបានធ្វើដោយអ្នកតំណាងដោយអាណត្តិ

១-ភាគីអាចធ្វើរាល់សកម្មភាពដែលទាក់ទងនឹងបណ្ដឹង ដោយខ្លួនឯងផ្ទាល់ ឬ ឆ្លងតាមរយៈអ្នកតំណាងដោយអាណត្តិដែលខ្លួនបានជ្រើសតាំង ។

២-ទោះបីភាគីបានជ្រើសតាំងអ្នកតំណាងដោយអាណត្តិក៏ដោយ ក៏ភាគីនោះអាចចូលរួមទៅតុលាការ និង ធ្វើយទាញហេតុផលដោយខ្លួនឯងបានដែរ ។

៣-សកម្មភាពបណ្ដឹងដែលអ្នកតំណាងដោយអាណត្តិបានធ្វើ ត្រូវបង្កើតអានុភាពដូចគ្នាជាមួយសកម្មភាពបណ្ដឹងដែលភាគីបានធ្វើដោយផ្ទាល់ខ្លួន ។ ប៉ុន្តែ ការសារភាព និង ចម្លើយដទៃទៀតស្ដីពីអង្គហេតុដែលអ្នកតំណាងដោយអាណត្តិបានធ្វើ ពុំមានអានុភាពឡើយ ប្រសិនបើភាគីលុបចោល ឬ កែតម្រូវភ្លាមៗ ។

**មាត្រា ៥៣.-** លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ

១-អ្នកតំណាងដោយអាណត្តិដែលបានកំណត់ក្នុងបញ្ញត្តិនៃមាត្រា ៥២ (សកម្មភាពបណ្ដឹងដែលបានធ្វើដោយអ្នកតំណាងដោយអាណត្តិ) ខាងលើនេះ ត្រូវតែជាមេធាវី លើកលែងតែករណីដែលបានកំណត់ក្នុងចំណុចនីមួយៗ ដូចខាងក្រោម :

ក-ករណីដែលក្រមនេះ ឬ ច្បាប់ដទៃទៀត អនុញ្ញាតឱ្យតតិយជនដែលមិនមែនជាមេធាវី ធ្វើសកម្មភាពបណ្ដឹងជំនួសភាគី ។

ខ-ករណីដែលភាគីជារដ្ឋ ស្ថាប័ននីតិរដ្ឋបាល ឬ ស្ថាប័នរដ្ឋដទៃទៀត និង ដែលស្ថាប័ននោះ ឬ អ្នកតំណាងនៃស្ថាប័ននោះ តែងតាំងបុគ្គលិកនៃស្ថាប័ននោះជាអ្នកតំណាង ។

គ-ករណីដែលតុលាការអនុញ្ញាតឱ្យមានការតំណាងដោយតតិយជនដែលមិនមែនជាមេធាវី ក្នុងរឿងក្ដីដែលតម្លៃកម្មវត្ថុនៃបណ្ដឹងតិចជាង ១.០០០.០០០ (មួយលាន) រៀល ។

២-សិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិ ត្រូវបញ្ជាក់ជាលាយលក្ខណ៍អក្សរ ។

៣-តុលាការអាចលុបចោលការអនុញ្ញាត ដែលបានកំណត់ក្នុងចំណុច គ នៃកថា-

ខណ្ឌទី ១ ខាងលើនេះ នៅពេលណាក៏បាន ។

**មាត្រា ៥៤.–** សិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិ

១-អ្នកតំណាងដោយអាណត្តិមានសិទ្ធិអំណាចក្នុងការធ្វើរាល់សកម្មភាពបណ្តឹង ព្រមទាំងការដាក់ពាក្យបណ្តឹង ការឆ្លើយដោះសាចំពោះបណ្តឹង ការប្តឹងតប ការចូលរួមអន្តរាគមន៍បណ្តឹង ការប្តឹងទៅតុលាការជាន់ខ្ពស់ ការផ្សះផ្សា ការលះបង់ការទាមទារ និង ការទទួលស្គាល់នូវការទាមទារ ចំពោះរឿងក្តីដែលខ្លួនបានទទួលអាណត្តិ ។

២-សិទ្ធិតំណាងដែលត្រូវបានប្រគល់សម្រាប់បណ្តឹងរាប់បញ្ចូលទាំងសិទ្ធិលើការចាត់ចែងរក្សាការពារ ការអនុវត្តដោយបង្ខំ ការជ្រើសតាំងអនុតំណាង និង ការទទួលនូវការសង ។

៣-ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិជាមេធាវី ភាគីពុំអាចកម្រិតនូវសិទ្ធិតំណាងបានទេ លើកលែងតែករណីទាក់ទងនឹងការដាក់ពាក្យបណ្តឹងតប ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ ការទទួលស្គាល់នូវការទាមទារ ការដកខ្លួនពីបណ្តឹង ការដាក់ពាក្យបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ការដកពាក្យបណ្តឹងឧបាស្រ័យពីតុលាការជាន់ខ្ពស់ និង ការជ្រើសតាំងអនុតំណាង ។

៤-ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិមិនមែនជាមេធាវី ភាគីក៏អាចឱ្យអ្នកតំណាងដោយអាណត្តិនោះ ធ្វើតំណាងចំពោះតែសកម្មភាពបណ្តឹងមួយចំនួនដែលបានកំណត់ដោយឡែកៗដោយភាគីបានដែរ ។

៥-បញ្ញត្តិនៃកថាខណ្ឌទាំងបួនខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះអ្នកតំណាងដែលត្រូវបានអនុញ្ញាតដោយច្បាប់ក្នុងការធ្វើសកម្មភាពបណ្តឹងជំនួសភាគី ។

**មាត្រា ៥៥.–** ករណីដែលសិទ្ធិតំណាងដោយអាណត្តិមិនរលត់

សិទ្ធិអំណាចនៃអ្នកតំណាងដោយអាណត្តិមិនត្រូវរលត់ឡើយ ទោះបីជាមានករណីដែលភាគីទទួលមរណភាព ឬ បាត់បង់សមត្ថភាពក្នុងការធ្វើបណ្តឹង ឬ មានករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវបានប្តូរ ជាអាទិ៍ ក៏ដោយ ។

**មាត្រា ៥៦.–** ហេតុនៃការរលត់នូវសិទ្ធិតំណាងដោយអាណត្តិ

១-សិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិត្រូវរលត់ ដោយហេតុដូចជាមរណ-

ភាពនៃអ្នកតំណាង ការបាត់បង់លក្ខណសម្បត្តិរបស់អ្នកតំណាង ឬ ការបញ្ចប់កិច្ចការអាណត្តិ ជាអាទិ៍ ។

២-ភាគីអាចដកសិទ្ធិតំណាងដោយអាណត្តិនៅពេលណាក៏បាន រីឯអ្នកតំណាងដោយអាណត្តិអាចឈប់ធ្វើជាអ្នកតំណាង នៅពេលណាក៏បានដែរ ។

៣-ការរលត់នូវសិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិ មិនត្រូវមានអានុភាពឡើយ ប្រសិនបើគ្មានការជូនដំណឹងអំពីការរលត់សិទ្ធិនោះ ពីសាមីខ្លួន ឬ អ្នកតំណាងទៅភាគីម្ខាងទៀត ។

**មាត្រា ៥៧.–** វិធានការក្នុងករណីនៃការខ្វះសិទ្ធិតំណាង

១-ក្នុងករណីដែលមានការសង្ស័យនៃការខ្វះសិទ្ធិតំណាងដោយអាណត្តិ តុលាការត្រូវស្រាវជ្រាវអំពីអត្ថិភាពនៃសិទ្ធិតំណាង ដោយឆន្ទានុសិទ្ធិ ទោះបីជាការសង្ស័យនោះកើតឡើង នៅក្នុងដំណាក់កាលណាមួយក្នុងបណ្តឹងក៏ដោយ ។

២-បើមានការខ្វះសិទ្ធិតំណាងដោយអាណត្តិ តុលាការត្រូវណែនាំកែតម្រូវនូវចំណុចខ្វះនោះ ដោយកំណត់អំឡុងពេល ។ ក្នុងករណីនេះ តុលាការអាចអនុញ្ញាតឱ្យបុគ្គលដែលខ្វះសិទ្ធិតំណាងនោះធ្វើសកម្មភាពបណ្តឹងជាបណ្តោះអាសន្នបាន ។

៣-សកម្មភាពបណ្តឹងណាដែលត្រូវបានធ្វើឡើងដោយបុគ្គលដែលមានការខ្វះសិទ្ធិតំណាងដោយអាណត្តិ ត្រូវមានអានុភាពប្រតិសកម្មតាំងពីពេលដែលសកម្មភាពនោះបានធ្វើឡើងដោយយោងទៅតាមសច្ចានុមតិរបស់ភាគី ។

**មាត្រា ៥៨.–** អ្នកជំនួយ

១-បើមានភាពចាំបាច់ដើម្បីឱ្យបំភ្លឺនូវទំនាក់ទំនងនៃបណ្តឹងឱ្យបានច្បាស់លាស់ នោះភាគី ឬ អ្នកតំណាងដោយអាណត្តិ អាចចូលទៅតុលាការជាមួយអ្នកជំនួយ ដោយមានការអនុញ្ញាតពីតុលាការ ។

២-ការអនុញ្ញាតដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចលុបចោលនៅពេលណាក៏បានដែរ ។

៣-សេចក្តីថ្លែងការណ៍របស់អ្នកជំនួយ ត្រូវទុកជាសេចក្តីថ្លែងការណ៍ដែលភាគី ឬតំណាងដោយអាណត្តិ បានធ្វើឡើងដោយខ្លួនឯង លើកលែងតែករណីដែលភាគី ឬ តំណាង

២-កាលបរិច្ឆេទដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្តឹងត្រូវបានដាក់ លើកលែងតែក្នុងករណីដែលមានមូលហេតុពិសេស ។

**មាត្រា ៨១.–** ការលើកបណ្តឹងចោល ដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់

ក្នុងករណីដែលបណ្តឹងមានលក្ខណៈផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះខាតនោះមិនអាចកែតម្រូវបានទេ តុលាការអាចលើកបណ្តឹងនោះចោល ដោយសាលក្រម ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បាន ។

**មាត្រា ៨២.–** ការលើកបណ្តឹងចោលក្នុងករណីដែលមិនបានបង់ជាមុននូវប្រាក់សម្រាប់ធ្វើការកោះហៅ

១-ក្នុងករណីដែលតុលាការបានបង្គាប់ឱ្យដើមចោទបង់ជាមុននូវប្រាក់ ដែលជាចាំបាច់សម្រាប់កោះហៅភាគីឱ្យចូលមកនៅកាលបរិច្ឆេទតាមបញ្ញត្តិនៃក្រមនេះ ដោយកំណត់អំឡុងពេលសមរម្យ តែដើមចោទមិនបានបង់ប្រាក់នោះជាមុនទេ តុលាការអាចលើកចោលបណ្តឹងដោយដីកាសម្រេចបាន លុះត្រាតែចុងចម្លើយគ្មានការតវ៉ា ។

២-ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

**មាត្រា ៨៣.–** ការហាមបណ្តឹងជាន់គ្នា

ចំពោះរឿងក្តីដែលតុលាការកំពុងចាត់ការ ភាគីមិនអាចប្តឹងទៀតបានឡើយ ។

**មាត្រា ៨៤.–** ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង

១-ដើមចោទអាចបន្ថែម ឬ ផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង រហូតដល់ពេលចប់ការទាញហេតុផលដោយផ្ទាល់មាត់បាន លុះត្រាតែមិនមានការប្តូរមូលដ្ឋាននៃការទាមទារ ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលធ្វើឱ្យនីតិវិធីនៃបណ្តឹងមានការយឺតយ៉ាវខ្លាំងដោយសារការបន្ថែម ឬ ការផ្លាស់ប្តូរនោះ ។

២-ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ។

**មាត្រា ២៧៨.–** ទំហំនៃការផ្លាស់ប្តូរសាលក្រមនៃការជំនុំជម្រះលើកទី ១

ការផ្លាស់ប្តូរសាលក្រមនៃការជំនុំជម្រះលើកទី ១ អាចធ្វើបាន ត្រឹមតែកម្រិតនៃឧបាស្រ័យ ដោយបណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំតែប៉ុណ្ណោះ ។

**មាត្រា ២៧៩.–** ការលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១

១-តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវលុបចោលនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ ក្នុងករណីដូចមានខាងក្រោមនេះ :

ក-បើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី ១ មិនត្រឹមត្រូវ ។

ខ-បើនីតិវិធីនៅតុលាការជាន់ទី ១ នោះផ្ទុយនឹងច្បាប់ធ្ងន់ធ្ងរ ។

២-ក្នុងករណីដូចកថាខណ្ឌទី ១ ខាងលើនេះ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវធ្វើការជំនុំជម្រះទៅលើបណ្តឹងនោះ លើកលែងតែករណីដែលបានកំណត់នៅក្នុងមាត្រា ២៨០ (ការបញ្ជូនរឿងក្តីត្រឡប់ទៅវិញ) ឬ មាត្រា ២៨១ (ការផ្ទេរដោយមូលហេតុខុសសមត្ថកិច្ចផ្តាច់មុខរបស់តុលាការនៃការជំនុំជម្រះលើកទី ១) នៃក្រមនេះ ។

**មាត្រា ២៨០.–** ការបញ្ជូនរឿងក្តីត្រឡប់ទៅវិញ

១-ក្នុងករណីដែលតុលាការនៃបណ្តឹងឧទ្ធរណ៍លុបចោលនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ ដែលលើកចោលបណ្តឹង ដោយយល់ឃើញថា បណ្តឹងនោះមិនត្រឹមត្រូវតាមច្បាប់ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវបញ្ជូនរឿងក្តីនោះ ត្រឡប់ទៅសាលាដំបូងវិញ ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលគ្មានការចាំបាច់ត្រូវទាញហេតុផលបន្ថែមទៀតអំពីរឿងក្តីនោះ ។

២-ក្រៅពីករណីដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ក្នុងករណីដែលតុលាការនៃបណ្តឹងឧទ្ធរណ៍លុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ បើមានភាពចាំបាច់ទាញហេតុផលបន្ថែមទៀត អំពីរឿងក្តីនោះ តុលាការនៃបណ្តឹងឧទ្ធរណ៍អាចបញ្ជូនរឿងក្តីនោះត្រឡប់ទៅសាលាដំបូងវិញបាន ។

៣-ប្រសិនបើរឿងក្តីនោះត្រូវបានបញ្ជូនត្រឡប់ទៅវិញ ដោយសារមូលហេតុថា នីតិវិធីបណ្តឹងនៅសាលាដំបូងផ្ទុយនឹងច្បាប់ នីតិវិធីនៃបណ្តឹងនោះត្រូវចាត់ទុកថា បានលុបចោល ដោយសារការបញ្ជូនត្រឡប់ទៅវិញ ។

**មាត្រា ២៨១.–** ការផ្ទេរដោយមូលហេតុខុសសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការនៃការជំនុំជម្រះលើកទី ១

ប្រសិនបើតុលាការនៃបណ្ដឹងឧទ្ធរណ៍លុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ ដោយមូលហេតុថា រឿងក្ដីនោះ ខុសសមត្ថកិច្ចផ្ដាច់មុខ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវចេញសាលដីកាផ្ទេររឿងក្ដីនោះទៅតុលាការដែលមានសមត្ថកិច្ចវិញ ។

**មាត្រា ២៨២.–** ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នក្នុងសាលដីកានៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍

ចំពោះសាលដីកាអំពីការទាមទារសំណងជាប្រាក់ បើមានពាក្យសុំ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវប្រកាសថា សាលដីកាអាចអនុវត្តជាបណ្ដោះអាសន្នបានដោយពុំចាំបាច់ឱ្យដាក់ប្រាតិភោគ លើកលែងតែករណីដែលយល់ឃើញថា ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ននោះមិនមានលក្ខណៈចាំបាច់ ។ ប៉ុន្តែ បើយល់ឃើញថាសមរម្យ តុលាការនៃបណ្ដឹងឧទ្ធរណ៍អាចកំណត់ល័ក្ខខ័ណ្ឌឱ្យដាក់ប្រាតិភោគសម្រាប់ការអនុវត្តជាបណ្ដោះអាសន្ននោះបាន ។

## ជំពូកទី ៣
## បណ្ដឹងសាទុក្ខ

**មាត្រា ២៨៣.–** តុលាការនៃបណ្ដឹងសាទុក្ខ

១-បណ្ដឹងសាទុក្ខអាចធ្វើទៅតុលាការកំពូលបាន ចំពោះសាលដីកាចុងក្រោយដែលត្រូវបានជំនុំជម្រះលើកទី ២ ដោយសាលាឧទ្ធរណ៍ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរចំពោះសាលដីកាចុងក្រោយដែលសាលាឧទ្ធរណ៍បានជំនុំជម្រះលើកទី ១ តាមបញ្ញត្តិនៃច្បាប់ពិសេស។

២-ចំពោះសាលក្រមចុងក្រោយដែលត្រូវបានជំនុំជម្រះលើកទី ១ ដោយសាលាដំបូងនៅក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាមិនប្ដឹងឧទ្ធរណ៍នៅក្រោយពេលដែលតុលាការបានចេញសាលក្រមនោះ ដោយរក្សាទុកនូវសិទ្ធិប្ដឹងសាទុក្ខ បណ្ដឹងសាទុក្ខអាចធ្វើទៅតុលា-ការកំពូលដោយផ្ទាល់បាន ។

## គន្ថីទី ៤
## ការជំនុំជម្រះសាជាថ្មី

## ជំពូកតែមួយ
## ការជំនុំជម្រះសាជាថ្មី

**មាត្រា ៣០៧.–** មូលហេតុនៃការជំនុំជម្រះសាជាថ្មី (មួយ)

១-ភាគីអាចស្នើសុំប្តឹងឧបាស្រ័យ តាមបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន ចំពោះសាលក្រមចុងក្រោយ ឬ សាលដីកាចុងក្រោយដែលបានចូលជាស្ថាពរហើយ ក្នុងករណីដែលមានមូលហេតុណាមួយដូចរៀបរាប់ខាងក្រោមនេះ :

ក-បើពុំបានចាត់តាំងតុលាការដែលបានចេញសាលក្រម ឬ សាលដីកា ទៅតាមច្បាប់កំណត់ ។

ខ-បើចៅក្រមដែលពុំអាចចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកាតាមច្បាប់ បានចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកានោះ ។

គ-បើខ្វះសិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ខ្វះការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្តឹង ឬ ខ្វះសិទ្ធិតំណាងដោយអាណត្តិ ។

ឃ-បើចៅក្រមដែលបានចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកា បានប្រព្រឹត្តអំពើល្មើសដែលពាក់ព័ន្ធនឹងមុខងាររបស់ខ្លួនចំពោះរឿងក្តី ។

ង-បើភាគីបានសារភាព ឬ ត្រូវបានរារាំងក្នុងការដាក់មធ្យោបាយតទល់ ឬ ការ-ពារខ្លួនដែលមានឥទ្ធិពលដល់សាលក្រម ឬ សាលដីកា ដោយសារបទល្មើសរបស់អ្នកដទៃ ។

ច-បើឯកសារ ឬ វត្ថុឯទៀតដែលបានក្លាយជាភស្តុតាងសម្រាប់សាលក្រម ឬ សាលដីកា ត្រូវបានក្លែង ឬ កែប្រែដោយបន្លំ ។

ឆ-បើសេចក្តីថ្លែងការណ៍មិនពិតរបស់សាក្សី អ្នកធ្វើកោសលវិច័យ អ្នកបកប្រែភាគីដែលបានធ្វើសម្បថ ឬ របស់អ្នកតំណាងដែលច្បាប់បានកំណត់ដែលបានធ្វើសម្បថ បានក្លាយជាភស្តុតាងសម្រាប់សាលក្រម ឬ សាលដីកា ។

# ឧបសម្ព័ន្ធទី៥

# ច្បាប់ស្តីពីនីតិវិធីនៃ

# បណ្តឹងទាក់ទងនឹងឋានៈបុគ្គល

# ច្បាប់
# ស្តីពី
# នីតិវិធីបណ្តឹងទាក់ទង
# នឹងឋានៈបុគ្គល

## ព្រះរាជក្រម

នស/រកម/០៦១០/០០៩

## យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

លេខ ១៧៧០
ថ្ងៃទី ... ឆ្នាំ២០១០ ម៉ោង ...
បញ្ជូនទៅ ...

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINIST... ROYAL

**មាត្រា ៦.-** ការផ្ទេរបណ្តឹងដើម្បីចៀសវាងការយឺតយ៉ាវ

ទោះបីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលណាមួយស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនក៏ដោយ ប្រសិនបើតុលាការយល់ឃើញថាចាំបាច់ដើម្បីចៀសវាងការយឺតយ៉ាវហួសហេតុនៃនីតិវិធី ឬ ដើម្បីធ្វើឱ្យមានសមធម៌រវាងគូភាគី ដោយពិចារណាអំពីលំនៅឋានរបស់ភាគី និង សាក្សីដែលត្រូវសាកសួរ និង កាលៈទេសៈផ្សេងៗ តុលាការនោះអាចផ្ទេរបណ្តឹងទាក់ទងនឹងឋានៈបុគ្គលទាំងមូល ឬ ផ្នែកណាមួយ ទៅតុលាការផ្សេងទៀតដែលមានសមត្ថកិច្ចបានតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

## ជំពូកទី ៤
## ភាគី

**មាត្រា ៧.-** ចុងចម្លើយ

១- ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលបានធ្វើឡើងដោយភាគីម្ខាងនៃទំនាក់ទំនងឋានៈបុគ្គលពាក់ព័ន្ធនឹងបណ្តឹងនោះ ភាគីម្ខាងទៀតត្រូវក្លាយជាចុងចម្លើយ លើកលែងតែមានបញ្ញត្តិពិសេស ។

២- ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលបានធ្វើឡើងដោយជនដែលមិនមែនជាភាគីនៃទំនាក់ទំនងឋានៈបុគ្គលពាក់ព័ន្ធនឹងបណ្តឹងនេះ ភាគីទាំងសងខាងនៃទំនាក់ទំនងឋានៈបុគ្គលនេះ ត្រូវក្លាយជាចុងចម្លើយ ហើយនៅក្រោយពេលដែលភាគីណាមួយបានទទួលមរណភាព ភាគីម្ខាងទៀតត្រូវក្លាយជាចុងចម្លើយ លើកលែងតែមានបញ្ញត្តិពិសេស ។

៣- ក្នុងករណីដែលជនដែលត្រូវក្លាយជាចុងចម្លើយនៃបណ្តឹង តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះ ទទួលមរណភាព ហើយគ្មានជនណាត្រូវក្លាយជាចុងចម្លើយទេនោះ តំណាងអយ្យការត្រូវក្លាយជាចុងចម្លើយ ។

**មាត្រា ៨.-** សមត្ថភាពក្នុងការធ្វើបណ្តឹង ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ជាអាទិ៍

១- ចំពោះសកម្មភាពបណ្តឹងក្នុងនីតិវិធីបណ្តឹងនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល បញ្ញត្តិនៃមាត្រា ១៨ (សិទ្ធិលុបចោលសកម្មភាព) មាត្រា ២៦ (សិទ្ធិលុបចោលសកម្មភាព) និង មាត្រា ៣០ (សិទ្ធិលុបចោលសកម្មភាព) នៃក្រមរដ្ឋប្បវេណី និង កថាខណ្ឌទី ៣ នៃមាត្រា ៣២ (សមត្ថភាពភាគី សមត្ថភាពក្នុងការធ្វើបណ្តឹង ការតំណាងដែលច្បាប់បានកំណត់សម្រាប់ជនដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹង) និង មាត្រា ៣៣ (បញ្ញត្តិពិសេសស្តីពីសកម្មភាពបណ្តឹងរបស់ជននៅក្រោមហិតូបត្ថម្ភ និង អ្នកតំណាងដែលច្បាប់បានកំណត់) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ ។

២- ក្នុងករណីជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹង មានបំណងធ្វើសកម្មភាពបណ្តឹងដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថាចាំបាច់ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចជ្រើសតាំងមេធាវីឱ្យធ្វើជាអ្នកតំណាងតាមពាក្យសុំបាន ។

Kol